# ព្រះអភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ៤

ប្រែសម្រួលជាភាសាខ្មែរដោយ

ភិក្ខុវជិរប្បញ្ញោ

សាន-សុជា

សម្រាប់ជាធម្មទាន

# អារម្ភកថា

ក្នុងសៀវភៅ **អភិធម្មត្ថសង្គហៈ** បរិច្ឆេទទី ៤ នេះ គង់នឹងមានឃ្លា ឬប្រយោគខ្លះលំបាកក្នុងការស្ដាប់ ព្រោះខ្ញុំមិនសូវបានសម្រួលន័យសេចក្ដីទេ ត្បិតមិនចង់ឱ្យមានការខុសចាកសភាពដើម ។ តែទោះជាយ៉ាងណាក៏ដោយចុះ ខ្ញុំនឹងទទួលនូវការរិះគន់កែលំអរអំពីលោកអ្នកសប្បុរស នូវរាល់កង្វះខាតដែលអាចមាន ។

សូមថ្លែងអំណរគុណចំពោះក្រុមភិក្ខុ សាមណេរក្នុងមណ្ឌលមណីរត្ន ដែលបានជួយផ្ទៀងផ្ទាត់ខ្ទឹមសារព្រះធម៌ និងជួយកែសម្រួលអក្ខរាវិរុទ្ធ ឱ្យកាន់តែមានសភាពល្អប្រសើរឡើង ។

សូមថ្លែងអំណរគុណចំពោះពុទ្ធបរិស័ទ ដែលបានជួយឧបត្ថម្ភប្រាក់ក្នុងការបោះពុម្ពសៀវភៅនេះ ។

សូមឱ្យប្រយោជន៍ដែលកើតឡើង អំពីការខិតខំប្រឹងប្រែងក្នុងការងារធម្មទាននេះ បានជាបច្ច័យនៃព្រះនិព្វានគ្រប់ៗ ព្រះអង្គ គ្រប់ៗ គ្នា ។

**សូមអនុមោទនា !!!**

មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន ឃុំរលាប ស្រុកសំពៅមាស ខេត្តពោធិ៍សាត់

ថ្ងៃ ១៥ រោច ខែភទ្របទ ឆ្នាំ វក ឆស័ក ព. ស ២៥៤៨

San Schea

**ភិក្ខុវជិរប្បញ្ញោ សាន-សុជា**

# សារបញ្ញ

**ឈ្មោះធម៌** **ទំព័រ**


សង្គហគាថាទី ១-២ .................................................. ១

ពណ៌នាឆក្កៈ ៦ ពួក .................................................. ,,

វិថីមុត្តចិត្ត ៣ យ៉ាង .................................................. ៣

វិថីឆក្កៈ មាន ២ ន័យ .................................................. ៥

វិសយបវត្តិឆក្កៈទី ៦.................................................. ៦

វិសយបវត្តិក្នុងបញ្ចទ្វារ ៤ ន័យ .................................................. ,,

វិសយបវត្តិក្នុងមនោទ្វារមាន ២ ន័យ .................................................. ៧

អាយុរបស់រូបធម៌ .................................................. ,,

វិនិច្ឆ័យខណៈ ៣.................................................. ៨

អធិប្បាយវិថីចិត្ត ២ យ៉ាង .................................................. ១១

កាមវិថី ២ .................................................. ,,

អប្បនាវិថី ២ .................................................. ១២

អធិប្បាយកាមវិថី .................................................. ១៣

បញ្ចទ្វារវិថី ៥ វិថី .................................................. ,,

សង្គហគាថាទី ៣ .................................................. ,,

អតិមហន្តារម្មណ៍ ១ ន័យ .................................................. ១៨

មហន្តារម្មណ៏ ២ ន័យ ........................................ ២០

បរិត្តារម្មណ៏មាន ៦ ន័យ ........................................ ២២

អតិបរិត្តារម្មណ៏ ៦ ន័យ ........................................ ២៨

បញ្ចទ្វារមាន ៤ វារៈ ........................................ ៣០

អធិប្បាយអតិមហន្តារម្មណ៏ជាដើម ........................................ ៣១

ឧបមាភវង្គចិត្តញ័រ ........................................ ៣៦

ឧបមាវិថីចិត្ត ........................................ ៣៧

កិច្ចផ្សេង៧ នៃវិថីមិនច្រឡំគ្នា ........................................ ៣៨

ពោលដោយបញ្ចារម្មណ៏ ........................................ ៣៩

ពោលដោយអារម្មណ៏ដែលជាបរិកប្បៈ ........................................ ៤០

អធិប្បាយមនោទ្វារវិថី ........................................ ៤៥

សង្គហគាថាទី ៤ ........................................ ៤៦

ពោលដោយសុទ្ធមនោទ្វារវិថី ........................................ ៤៨

វិភូតារម្មណ៏មាន ២ យ៉ាង ........................................ ៥៣

អវិភូតារម្មណ៏មាន ២ វិថី ........................................ ៥៤

អតិវិភូតារម្មណ៏មាន ១ វិថី ........................................ ៥៥

អារម្មណ៏ដែលប្រព្រឹត្តទៅក្នុងកាល ៣ ........................................ ,,

អនុពន្ធកមនោទ្វារវិថី ........................................ ៥៦

ទ្វារគូ ........................................ ៥៨

វិញ្ញត្តិគហណវិថី .................................................. ៦២

វចីវិញ្ញត្តិគហណវិថី .................................................. ៦៣

សុបិនវិថី .................................................. ៦៥

ពោលដោយវិថីចិត្តរបស់ទារក .................................................. ៦៨

ប្រៀបធៀបបញ្ចទ្វារនិងមនោទ្វារ .................................................. ៧០

អប្បនាវិថី ឬអប្បនាជវនវារៈ .................................................. ៧៣

អប្បនាវិថីមាន ២ យ៉ាង .................................................. ៧៤

លោកិយអប្បនាវិថី .................................................. ,,

ឈានសមាបត្តិវិថី .................................................. ៧៨

លោកុត្តរអប្បនាវិថី .................................................. ៧៩

លោកុត្តរវិថីមាន ២ យ៉ាង .................................................. ,,

ផលសមាបត្តិមាន ៤ ប្រភេទ .................................................. ៨៣

អប្បនាជវនវារៈមានវេទនា ២ .................................................. ៨៧

សង្គហគាថាទី ៥ .................................................. ,,

អធិប្បាយសង្គហគាថា .................................................. ៨៨

សង្គហគាថាទី ៦ និងសេចក្តីអធិប្បាយ .................................................. ៨៩

ប្រៀបធៀបវិថីទាំង ២ .................................................. ៩១

បច្ចវេក្ខណវិថី .................................................. ៩៥

អប្បនាវិថី ៧ .................................................. ៩៧

បាទកឈានវិថី .................................................. ៩៧
វសី ៥ ប្រការ .................................................. ,,
អភិញ្ញាវិថី .................................................. ៩៨
.អធិប្បាយអភិញ្ញាវិថី .................................................. ១០០
លោកិយអភិញ្ញា ៥ យ៉ាង .................................................. ១០២
និរោធសមាបត្តិវិថី .................................................. ១០៣
អធិដ្ឋានធ្វើបុព្វកិច្ច ៤ .................................................. ១០៦
និរោធសមាបត្តិវិថី .................................................. ,,
មរណាសន្នវិថី .................................................. ១០៨
មរណៈ ៤ យ៉ាង .................................................. ,,
មរណាសន្នវិថី ៩ ប្រភេទ .................................................. ១១១
កាមចុតិមាន ២ យ៉ាង .................................................. ១១២
អធិប្បាយមរណាសន្នវិថី-បដិសន្ធិ .................................................. ១១៣
សភាពមរណាសន្នវិថីទី ២ .................................................. ១១៥
វិថីទី ៣ អាគន្តុកចុតិ .................................................. ១១៦
វិថីតាមបញ្ចទ្វារទី ៤ .................................................. ១១៧
មរណាសន្នវិថីផ្លូវមនោទ្វារ .................................................. ,,
កាមចុតិ-បដិសន្ធិក្នុងរូបព្រហ្ម ១៦ .................................................. ១១៨
ព្រហ្មចុតិ-ព្រហ្មបដិសន្ធិ .................................................. ,,

ព្រហ្មចុតិ-កាមបដិសន្ធិ ........................................ ១១៩

ព្រះអរហន្តចុតិ ៥ ន័យ មិនមានបដិសន្ធិ ........................... ,,

តទាលម្ពណនិយម ........................................ ១២៣

អាគន្តុកភវង្គវិថី ........................................ ១២៥

ជវននិយម ........................................ ១២៧

សង្គហគាថាទី ៨ ........................................ ១២៨

សម្តែងការកើតជវនៈដោយពិស្តារ ........................... ,,

ចែកវិថីចិត្តតាមប្រភេទបុគ្គល ........................................ ១៣១

អធិប្បាយបុគ្គល ១២ ........................................ ,,

សង្គហគាថាទី ៩ ........................................ ១៣៣

ភូមិវិភាគ ........................................ ១៤០

សង្គហគាថាទី ១០ ........................................ ,,

អធិប្បាយសង្គហគាថា ........................................ ,,

អវសានគាថា ........................................ ១៤៣

នាមបរិស័ទអ្នកមានឧបការៈក្នុងការរៀបចំសៀវភៅនេះ .......... ១៤៤

នាមពុទ្ធបរិស័ទអ្នកបរិច្ចាគប្រាក់បោះពុម្ពសៀវភៅនេះ ............ ១៤៥

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ៤ ឈ្មោះ វិថីសង្គហវិភាគ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

### សង្គហគាថា

*១- ចិត្តុប្បាទានមិច្ចេវំ កត្វា សង្គហមុត្តមំ*
*ភូមិបុគ្គលភេទេន បុព្វាបរនិយាមិតំ ។*
*២- បវត្តិសង្គហំ នាម បដិសន្ធិប្បវត្តិយំ*
*បវក្ខាមិ សមាសេនេវ យថាសម្ភវតោ កថំ ។*

ខ្ញុំព្រះអង្គ កាលធ្វើបកិណ្ណកសង្គហៈ នៃចិត្តុប្បាទទាំងឡាយ មានអត្ថន័យដ៏ជ្រាលជ្រៅដោយប្រការដូច្នេះហើយ នឹងពោលបវត្តិសង្គហៈ ដែលកំណត់ដោយចិត្ត ដែលកើតមុននិងក្រោយ ដោយសេចក្ដីផ្សេងគ្នានៃភូមិនិងបុគ្គល ក្នុងបដិសន្ធិកាល តាមគួរដល់ការកើតឡើងរបស់ចិត្តដោយសង្ខេបយ៉ាងណា ។

### ពណ៌នាឆក្កៈ ៦ ពួក

ពាក្យថា បវត្តិសង្គហៈក្នុងព្រះគាថានេះ លោកហៅថា វិថីសង្គហៈ

ជាបរិច្ឆេទទី ៤ ក្នុងព្រះបាលីបានសំដែងឆក្កៈ(ពួក ៦) ទុក ៦ ពួក ដូច្នេះ គឺ ÷

*១-វត្ថុឆក្កៈ* បានដល់ ពួក ៦ នៃវត្ថុ

*២-ទ្វារឆក្កៈ* បានដល់ ពួក ៦ នៃទ្វារ

*៣-អាលម្ពណឆក្កៈ* បានដល់ ពួក ៦ នៃអារម្មណ៍

*៤-វិញ្ញាណឆក្កៈ* បានដល់ ពួក ៦ នៃវិញ្ញាណ

*៥-វិថីឆក្កៈ* បានដល់ ពួក ៦ នៃវិថី

*៦-វិសយបវត្តិឆក្កៈ* បានដល់ ពួក ៦ នៃការប្រព្រឹត្តទៅរបស់អារម្មណ៍ ។

**១-វត្ថុឆក្កៈ ៦ គឺ ÷**

១-ចក្ខុវត្ថុ ៣-ឃានវត្ថុ ៥-កាយវត្ថុ

២-សោតវត្ថុ ៤-ជីវ្ហាវត្ថុ ៦-ហទយវត្ថុ

**២-ទ្វារឆក្កៈ ៦ គឺ ÷**

១-ចក្ខុទ្វារ ៣-ឃានទ្វារ ៥-កាយទ្វារ

២-សោតទ្វារ ៤-ជីវ្ហាទ្វារ ៦-មនោទ្វារ

**៣-អាលម្ពណឆក្កៈ ៦ គឺ ÷**

១-រូបារម្មណ៍ ៣-គន្ធារម្មណ៍ ៥-ផោដ្ឋព្វារម្មណ៍

២-សទ្ទារម្មណ៍ ៤-រសារម្មណ៍ ៦-ធម្មារម្មណ៍

**៤-វិញ្ញាណឆក្កៈ ៦ គឺ ÷**

១-ចក្ខុវិញ្ញាណ ៣-ឃានវិញ្ញាណ ៥-កាយវិញ្ញាណ

២-សោតវិញ្ញាណ ៤-ជីវ្ហាវិញ្ញាណ ៦-មនោវិញ្ញាណ

## ៥.វិថីសង្គ្រះ ៦ មាន ២ន័យ

| ន័យទី ១ | ន័យទី ២ |
|---|---|
| ១- ចក្ខុទ្វារវិថី | ១- ចក្ខុវិញ្ញាណវិថី |
| ២- សោតទ្វារវិថី | ២- សោតវិញ្ញាណវិថី |
| ៣- ឃានទ្វារវិថី | ៣- ឃានវិញ្ញាណវិថី |
| ៤- ជីវ្ហាទ្វារវិថី | ៤- ជីវ្ហាវិញ្ញាណវិថី |
| ៥- កាយទ្វារវិថី | ៥- កាយវិញ្ញាណវិថី |
| ៦- មនោទ្វារវិថី | ៦- មនោវិញ្ញាណវិថី |

## ៦.វិសយប្បវត្តិសង្គ្រះ ២ ន័យ

| ក្នុងបញ្ចទ្វារ ៤ គឺ ÷ | ក្នុងមនោទ្វារមាន ២ គឺ ÷ |
|---|---|
| ១- អតិមហន្តារម្មណ៍ | ១- វិភូតារម្មណ៍ |
| ២- មហន្តារម្មណ៍ | ២- អវិភូតារម្មណ៍ |
| ៣- បរិត្តារម្មណ៍ | |
| ៤- អតិបរិត្តារម្មណ៍ | |

## វិថីមុត្តចិត្តមាន ៣ យ៉ាងគឺ ÷

១- ចិត្តដែលមានកម្មជាអារម្មណ៍ក្នុងភពមុន

២- ចិត្តដែលមានកម្មនិមិត្តជាអារម្មណ៍ក្នុងភពមុន

៣- ចិត្តដែលមានគតិនិមិត្តជាអារម្មណ៍ក្នុងភពមុន

វិថីមុត្តចិត្ត គឺចិត្តដែលផុតចាកវិថី ជាចិត្តដែលបានទទួលអារម្មណ៍ ក្នុងវេលាជិតស្លាប់អំពីភពមុន ក្នុងអារម្មណ៍ណានីមួយតាមសមគួរ ដល់ការប្រព្រឹត្តទៅ បានដល់បដិសន្ធិចិត្ត ១៩ ដួងគឺ ÷

១. ឧបេក្ខាសន្តីរណចិត្ត ២ ដួង

២. មហាវិបាកចិត្ត ៨ ដួង

៣. មហគ្គតវិបាកចិត្ត ៩ ដួង

បណ្តាចិត្ត ១៩ ដួងនេះ ចិត្ត ១០ ដួង គឺ ឧបេក្ខាសន្តីរណចិត្ត ២ ដួង និង មហាវិបាកចិត្ត ៨ ដួងនេះ អាចប្រព្រឹត្តទៅជាវិថីចិត្តផង និងជាវិថីមុត្តចិត្តផង ។ ខណៈណាចិត្ត ១០ ដួងនេះ ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច និងចុតិកិច្ច ខណៈនោះក៏ជាវិថីមុត្តចិត្ត ខណៈណាចិត្ត ១០ ដួងនេះ ទទួលអារម្មណ៍ក្នុង ភពនេះ គឺឧបេក្ខាសន្តីរណចិត្ត ២ ដួងធ្វើសន្តីរណកិច្ច និង តទាលម្ពណកិច្ច និង មហាវិបាកចិត្ត ៨ ដួង ធ្វើតទាលម្ពណកិច្ច ខណៈនោះ ចិត្ត ១០ នេះ ក៏ ជាវិថីចិត្តទៅ ។

បណ្តាឆក្កៈ ៦ ដែលបានពោលហើយទាំងនោះ ឆក្កៈទី ១-៣ បានដល់ វត្ថុឆក្កៈ ទ្វារឆក្កៈ និងអាលម្ពណឆក្កៈ បានពោលទុកហើយក្នុងបរិច្ឆេទទី ៣ ដែលពោលដោយបកិណ្ណកសង្គហវិភាគ, ក្នុងឆក្កៈទី ៤ គឺ វិញ្ញាណឆក្កៈ បានពោលទុកហើយក្នុងបរិច្ឆេទទី ១ ដែលពោលដោយចិត្តសង្គហវិភាគ, តែដែលនាំយកមកពោលក្នុងទីនេះទៀត ក៏ដើម្បីសំដែងបវត្តិសង្គហៈឱ្យបរិបូរណ៌ ដូច្នោះ បន្ទាប់តទៅ នឹងសំដែងចំពោះតែឆក្កៈ

ទី ៥ និងទី ៦ តែប៉ុណ្ណោះ ។

## វិថីឆក្កៈ មាន ២ ន័យ[(១)]

វិថីឆក្កៈ ន័យទី ១ មានពាក្យថា ចក្ខុទ្វារវិថី ប្រែថា វិថីប្រព្រឹត្តទៅក្នុងចក្ខុទ្វារជាដើមនោះ លោកសំដែងការប្រកបវិថីទាំងឡាយ ដោយអំណាចនៃទ្វារ ។ ន័យទី ២ មានពាក្យថា ចក្ខុវិញ្ញាណវិថី ប្រែថា វិថីជាប់ទាក់ទងដោយចក្ខុវិញ្ញាណជាដើម លោកសំដែងការប្រកបវិថីទាំងឡាយដោយអំណាចនៃវិញ្ញាណ ។

ម្យ៉ាងទៀត ក្នុងវិថីឆក្កៈទី ៥ ន័យទី ១ នោះ លោកសំដែងការកើតឡើងនៃចិត្តក្នុងទ្វារ ដូច្នេះគឺ ÷

| | | |
|---|---|---|
| ១-ចក្ខុទ្វារវិថី | មានចិត្តកើតបាន | ៤៦ ដួង |
| ២-សោតទ្វារវិថី | មានចិត្តកើតបាន | ៤៦ ដួង |
| ៣-ឃានទ្វារវិថី | មានចិត្តកើតបាន | ៤៦ ដួង |
| ៤-ជិវ្ហាទ្វារវិថី | មានចិត្តកើតបាន | ៤៦ ដួង |
| ៥-កាយទ្វារវិថី | មានចិត្តកើតបាន | ៤៦ ដួង |
| ៦-មនោទ្វារវិថី | មានចិត្តកើតបាន | ៦៧ ដួង |

ចិត្តទាំងនេះ លោកសំដែងទុកហើយក្នុងបរិច្ឆេទទី ៣ ។

ន័យទី ២ មានពាក្យថា ចក្ខុវិញ្ញាណវិថីជាដើម ដែលហៅថា

---

១-ពាក្យថាវិថី ក្នុងយោជនាបានធ្វើវិគ្រោះថា វីថន្តិ ឯតាយាតិ វីថិ ប្រែថា ចិត្តទាំងឡាយរមែងប្រព្រឹត្តទៅដោយធម្មជាតិនេះ ព្រោះហេតុនោះ ធម្មជាតិនេះ ទើបឈ្មោះថា វីថិ គឺធម្មជាតិដែលជាហេតុប្រព្រឹត្តទៅនៃចិត្តទាំងឡាយ (វី.ធាតុ ក្នុងសេចក្តីថា ប្រព្រឹត្តទៅ ថិ ជាបច្ច័យ) ។

វិញ្ញាណវិថីនេះ ជាប្រភេទដូចគ្នានឹងឆក្កៈទី ៦ គឺ វិសយបវត្តិឆក្កៈនោះឯង ព្រោះមានអត្ថដូចគ្នា គឺមានអត្ថសេចក្ដីដល់វិថីនៃវិញ្ញាណ ដែលប្រព្រឹត្ត-ទៅក្នុងអារម្មណ៍ ៦ ដោយអំណាចនៃអារម្មណ៍ ដែលកើតឡើង ប្រាកដច្បាស់ច្រើន ឬអារម្មណ៍ដែលមានកម្លាំងតិច រហូតជាមោឃវារៈ ។

## វិសយបវត្តិឆក្កៈ ទី ៦

ពាក្យថា វិសយ (វិសយប្ប) ប្រែថា វិស័យ គឺអារម្មណ៍

ពាក្យថា បវត្តិ ប្រែថា សេចក្ដីប្រព្រឹត្តទៅ

ពាក្យថា ឆក្កៈ ប្រែថា ពួក ៦

ពាក្យថា វិសយបវត្តិ ក្នុងយោជនាពោលវិគ្រោះទុក ២ យ៉ាងគឺ ÷

១- *វិសយានំ បវត្តិ វិសយប្បវត្តិ* សេចក្ដីប្រព្រឹត្តទៅនៃអារម្មណ៍ ឈ្មោះថា វិសយបវត្តិ ។

២- *វិសយេសុ បវត្តិ វិសយប្បវត្តិ* សេចក្ដីប្រព្រឹត្តទៅក្នុងអារម្មណ៍ ឈ្មោះថា វិសយបវត្តិ ។

## វិសយបវត្តិក្នុងបញ្ចទ្វារមាន ៤ ន័យ

១- អតិមហន្តារម្មណ៍ បានដល់ អារម្មណ៍មានខណៈចិត្តច្រើនបំផុត ។

២- មហន្តារម្មណ៍ បានដល់ អារម្មណ៍មានខណៈចិត្តច្រើនសមគួរ ។

៣- បរិត្តារម្មណ៍ បានដល់ អារម្មណ៍មានខណៈចិត្តកើត

បានតិច ។

៤- អតិបរិត្តារម្មណ៍ បានដល់ អារម្មណ៍មានខណៈចិត្តកើតតិចបំផុត ។

## វិសយប្បវត្តិក្នុងមនោទ្វារមាន ២ ន័យ

១- វិភូតារម្មណ៍ បានដល់អារម្មណ៍ដែលប្រាកដច្បាស់

២- អវិភូតារម្មណ៍ បានដល់អារម្មណ៍ដែលមិនប្រាកដច្បាស់ ។

## អាយុរបស់រូបធម៌

*ឧប្បាទឋិតិភង្គវសេន ខណត្តយំ ឯកចិត្តក្ខណំ នាម* ប្រែថា ពួក ៣ នៃចិត្ត ប្រព្រឹត្តទៅ ដោយអំណាចនៃ ឧប្បាទៈ ឋិតិ និងភង្គៈ ឈ្មោះថា ខណៈនៃចិត្តមួយដួង ។

ក្នុងទុតិយអត្ថយោជនា សំដែងវចនត្ថៈថា *ខិយតិ ឯត្ថាតិ ខណោ* ចិត្តរមែងអស់ទៅក្នុងកាលនេះ ព្រោះហេតុនោះ កាលនេះទើបឈ្មោះថា ខណៈ ។

ពិតណាស់ ចិត្តរមែងមានអាយុប្រព្រឹត្តទៅត្រឹមតែ ៣ ខណៈតូចនេះប៉ុណ្ណោះ តអំពីនោះក៏ជាចិត្តមួយដួងទៀត ។ ចិត្តគ្រប់ដួងមានអាយុស្មើគ្នា ដោយហេតុនេះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ចិត្តនេះប្រព្រឹត្តទៅលឿនរហ័ស សូម្បីការប្រៀបធៀប ក៏ធ្វើមិនបានងាយឡើយ " ដូច្នេះ ។

*តានិ បន សត្តរស ចិត្តក្ខណានិ រូបធម្មានមាយុ* ប្រែថា ក៏ខណៈនៃ

ចិត្ត ១៧ ទាំងនោះ (ខណៈធំ) ជាអាយុរបស់រូបធម៌ ។

អាយុរបស់រូបធម៌ទាំងឡាយ ដែលប្រៀបនឹងអាយុរបស់ចិត្តនេះ សំដៅយករូបធម៌ ២២ រូប ដោយវៀរវិញ្ញត្តិរូប ២ ព្រោះវិញ្ញត្តិរូប ២ កើតព្រមគ្នាជាមួយចិត្ត រលត់ព្រមគ្នាជាមួយចិត្ត ដែលប្រព្រឹត្តទៅក្នុងខណៈនៃចិត្តទាំង ៣, វៀរលក្ខណៈរូប ៤ ព្រោះបណ្តាលក្ខណៈរូប ៤ នោះ ការកើតនិងការមិនទៀងនេះ មានអាយុប៉ុនគ្នានឹងឧប្បាទខណៈ និងភង្គខណៈនៃអនុខណៈចិត្ត ចំណែកជរតារូបមានអាយុប្រមាណ ៤៩ អនុខណៈនៃចិត្ត ។

ការកើតឡើងរបស់ចិត្ត ហៅថា ចិត្តុប្បាទ, អាយុរបស់ចិត្តុប្បាទមួយដួង មានត្រឹមតែ ៣ អនុខណៈ ដូច្នោះ កាលនឹងរាប់អាយុរបស់រូបធម៌ដោយអនុខណៈរបស់ចិត្តហើយ រូបធម៌នោះក៏មានអាយុដល់ទៅ ៥១ អនុខណៈនៃចិត្ត ។ ក៏អនុខណៈនៃចិត្ត ៣ នេះ អាចារ្យអ្នករចនាគម្ពីរ មានសេចក្តីយល់ឃើញផ្សេងគ្នា គឺអាចារ្យខ្លះពោលថា ចិត្តមានត្រឹមតែ ២ ខណៈប៉ុណ្ណោះ (ឧប្បាទៈភង្គៈ) អាចារ្យខ្លះធ្វើឱ្យប្រាដកន័យថា មាន ៣ ខណៈ, ដើម្បីឱ្យអត្ថសេចក្តីនេះកាន់តែជាក់ច្បាស់ គប្បីជ្រាបពាក្យរបស់លោកដូចតទៅ ÷

## វិនិច្ឆ័យខណៈ ៣

ខណៈនៃចិត្ត តើជាយ៉ាងណា ?

ក្នុងចិត្តមួយដួងៗ មាន ៣ ខណៈ គឺឧប្បាទៈ ឋិតិ និង ភង្គៈ, ការកើតឡើង ឈ្មោះថា ឧប្បាទៈ ការបែកធ្លាយ ឈ្មោះថា ភង្គៈ ការប្រព្រឹត្ត

ទៅដែលសំដៅទៅកាន់ការបែកធ្លាយ គឺក្នុងពាក់កណ្តាលនៃឧប្បាទៈ និង ភង្គៈ ឈ្មោះថា ឋិតិ. ការកើតឡើង ការតាំងនៅ និងការបែកធ្លាយទៅនៃ ចិត្ត ប្រព្រឹត្តទៅដោយអាការដូច្នេះ ។

តែអាចារ្យខ្លះ រមែងបដិសេធខណៈនៃចិត្តដែលតាំងនៅ (ឋិតិ) ដែលលើកយកគម្ពីរដែលពោលទុកក្នុងយមកបករណ៍ហើយពោលថា ក្នុង ការចែកបទមានអាទិ៍យ៉ាងនេះថា "**ឧប្បន្នំ ឧប្បជ្ជមានំ** "(ប្រែថា ចិត្តដែល កើតឡើងហើយ ចិត្តនោះឈ្មោះថាកំពុងកើតឬ?) ក្នុងចិត្តយមកៈព្រះមាន ព្រះភាគត្រាស់ភង្គខណៈ និងឧប្បាទខណៈប៉ុណ្ណោះ ដោយន័យមានជាអាទិ៍ ថា "ក្នុងភង្គខណៈ ចិត្តកើតឡើងហើយ មិនមែនកំពុងកើតឡើង, ក្នុងឧប្បាទខណៈ ចិត្តកំពុងកើតឡើង មិនមែនកើតឡើងហើយទេ" ដូច្នេះ មិនបានត្រាស់ឋិតិខណៈទុកឡើយ ។ ក៏ប្រសិនណាបើឋិតិខណៈនៃចិត្តគប្បី មាន គង់នឹងត្រាស់ថា "ចិត្តក្នុងឋិតិខណៈនិងក្នុងភង្គខណៈ" ដូច្នេះ មិនគួរ នឹងមានមតិរបស់អាចារ្យថា "មានឋិតិខណៈ" ដូច្នេះ ដោយព្រះបាលីក្នុង ព្រះសូត្រថា "សេចក្តីកើតប្រាកដ និងសេចក្តីវិនាសក៏ប្រាកដ សេចក្តីជា យ៉ាងដទៃនៃធម៌ដែលតាំងនៅហើយក៏ប្រាកដ" ដូច្នេះ ក្នុងព្រះសូត្រនោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ព្រះបំណងយកសេចក្តីតាំងនៅ ដោយ សេចក្តីតជាប់គ្នាតែម្យ៉ាង ព្រោះសេចក្តីប្រព្រឹត្តទៅដោយប្រការដទៃរមែង មិនកើតឡើងក្នុងធម៌តែមួយ និងព្រោះការពោលនោះ មិនបានសំដៅយក សេចក្តីតាំងនៅ(នៃ)ជួរខណៈ ។ ក៏ហេតុដែលព្រះមានព្រះភាគជាម្ចាស់

នឹងមិនត្រាស់ដល់ធម៌ ដែលមាននៅក្នុងព្រះអភិធម្ម រមែងមិនមាន ព្រោះហេតុដូច្នោះ សូម្បីការមិនពោលដល់ក្នុងយថាធម្មសាសន៍ ក៏រមែង សំដែងដល់ការដែលមិនមាននៃឋិតិខណៈនោះឯង ។

ក្នុងបញ្ហានេះព្រះដីកាចារ្យទាំងឡាយមិនយល់ឃើញដូចមតិរបស់ អាចារ្យដែលពោលថាចិត្តមាន ២ ខណៈទេ លោកបានពោលថាចិត្តប្រព្រឹត្ត ទៅដោយអំណាចនៃឧប្បាទៈ ឋិតិ និងភង្គៈនេះ ព្រះអនុរុទ្ធាចារ្យបាន ពោលទុកត្រឹមត្រូវល្អហើយ សូម្បីក្នុងអដ្ឋកថាវិភង្គ លោកក៏ពោលថា ចិត្ត មួយដូង១ មាន ៣ ខណៈ ប្រព្រឹត្តទៅដោយអំណាចនៃឧប្បាទខណៈ ឋិតិខណៈ និងភង្គខណៈ ។[១]

វិថីចិត្ត បានដល់ចិត្តដែលមានអារម្មណ៍ណានីមួយ ក្នុងបណ្ដា អារម្មណ៍ ៦ ដោយអាស្រ័យទ្វារណាមួយក្នុងទ្វារ ៦ កើតឡើងប្រព្រឹត្តទៅ លោកហៅថាវិថីចិត្តមួយ ។ ក្នុងវិថីចិត្តនោះ ចិត្តដែលកើតមុន១ ជាបច្ច័យ ឱ្យចិត្តក្រោយ១ កើតឡើង ដោយអំណាចនៃបច្ច័យដែលតាក់តែង រមែង កើតរលត់បន្តគ្នាទៅមិនដាច់ខ្សែ ដូចក្រសែទឹក រមែងប្រព្រឹត្តទៅរហូត ទល់គ្នានឹងចុតិចិត្តរបស់ព្រះអរហន្ត ។ វិថីចិត្តទាំងអស់ រមែងធ្វើកិច្ចដ៏សម គួររបស់ខ្លួនត្រឹមតែ ១១ កិច្ចប៉ុណ្ណោះ ដោយវៀរកិច្ច ៣ គឺបដិសន្ធិកិច្ច ភវង្គកិច្ច និងចុតិកិច្ច ព្រោះជាវិថីមុត្តចិត្ត (ចិត្តផុតចាកវិថី) ។

---

១-ក្នុងចិត្តយមកៈ ទ្រង់សំដែងធម៌ជាគូ១ គឺ កើតនិងរលត់ តែក្នុងព្រះអភិធម្មត្ថសង្គហៈ និងក្នុងអដ្ឋកថាវិភង្គ នេះ សំដែងសភាពធម៌តាមដែលប្រាកដជាក់ស្ដែង ទើបបានជាចិត្តមាន ៣ ខណៈ ព្រោះខណៈដែលចិត្តនៅមិនទាន់ រលត់នោះឯង ហៅថាឋិតិខណៈ ។

# អធិប្បាយវិថីចិត្ត ២ យ៉ាង

- ១. កាមវិថី ២
  - ១. បញ្ចទ្វារវិថី
  - ២. មនោទ្វារវិថី
- ២. អប្បនាវិថី ២
  - ១. លោកិយអប្បនាវិថី
  - ២. លោកុត្តរអប្បនាវិថី

## ១. កាមវិថី ២ គឺ ÷

១. *បញ្ចទ្វារវិថី* មានអារម្មណ៍ ៤ គឺ ÷

| | |
|---|---|
| ១. អតិមហន្តារម្មណវិថីមាន | ១ន័យ |
| ២. មហន្តារម្មណវិថីមាន | ២ន័យ |
| ៣. បរិត្តារម្មណវិថីមាន | ៦ន័យ |
| ៤. អតិបរិត្តារម្មណវិថីមាន | ៦ន័យ |
| រួមវិថីមាន | ១៥ ន័យ ។ |

**ពោលដោយពិស្តារបញ្ចទ្វារវិថី មាន ៧៥ ន័យ គឺ ÷**

| | |
|---|---|
| ១. ចក្ខុទ្វារវិថី | ១៥ ន័យ |
| ២. សោតទ្វារវិថី | ១៥ ន័យ |
| ៣. ឃានទ្វារវិថី | ១៥ ន័យ |
| ៤. ជីវ្ហាទ្វារវិថី | ១៥ ន័យ |
| ៥. កាយទ្វារវិថី | ១៥ ន័យ |
| រួម ៥ ទ្វារមាន | ៧៥ ន័យ ។ |

២. *មនោទ្វារវិថី* មានអារម្មណ៍ ២ គឺ ÷

១. វិភូតារម្មណ៍ ១ន័យ

២. អវិភូតារម្មណ៍ ១ន័យ

កាមវិថីទាំង ២ គឺ បញ្ចទ្វារវិថី ៤ ន័យ និងមនោទ្វារវិថី ២ ន័យ ដែលមាន រូប សំលេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ កើតប្រព្រឹត្តទៅតាមសមគួរដល់ទ្វារ ៦ មានចក្ខុទ្វារជាដើមនោះ បានដល់កាមាវចរចិត្ត ៥៤ ដួង គឺ ÷

១. អកុសលចិត្ត ១២ ដួង

២. អហេតុកចិត្ត ១៨ ដួង

៣. កាមាវចរសោភណចិត្ត ២៤ ដួង

**អប្បនាវិថី ២ គឺ** ÷

១. លោកិយអប្បនាវិថី អប្បនាវិថីដែលជាលោកិយៈ

២. លោកុត្តរអប្បនាវិថី អប្បនាវិថីដែលជាលោកុត្តរៈ

អប្បនាវិថីទាំង ២ នោះ មានអារម្មណ៍តាមមនោទ្វារ ប្រាកដច្បាស់ច្រើន ទើបលោកមិនពោលច្រើនន័យដូចក្នុងកាមវិថី ក្នុងអប្បនាវិថីនេះ ទើបមានតែវិភូតារម្មណ៍ គឺអារម្មណ៍ដែលប្រាកដច្បាស់តែម្យ៉ាង ព្រោះជាចិត្តតាំងណែនក្នុងអារម្មណ៍ និងប្រព្រឹត្តទៅក្នុងការប្រហារកិលេស បានដល់វិថីចិត្ត ដែលជាអប្បនាជវនៈ ២៦ ដួង គឺ ÷

១. មហគ្គតកុសលចិត្ត ៩ ដួង

២. មហគ្គតកិរិយាចិត្ត ៩ ដួង

៣. លោកុត្តរចិត្ត ៨ ឬ ៤០ ដួង ។

## អធិប្បាយកាមវិថី

កាមវិថី គឺវិថីចិត្តដែលមាន រូប សំលេង ក្លិន រស ផោដ្ឋព្វៈ និងធម៌ ជាអារម្មណ៍ ចែកចេញជា ២ ទ្វារ គឺ ÷

កាមវិថីដែលប្រព្រឹត្តទៅតាមបញ្ចទ្វារ ហៅថា បញ្ចទ្វារវិថី ។

កាមវិថីដែលប្រព្រឹត្តទៅតាមមនោទ្វារ ហៅថា មនោទ្វារវិថី ។

## បញ្ចទ្វារវិថី ៥ វិថី

១. ចក្ខុទ្វារវិថី គឺវិថីចិត្តដែលមានរូបជាអារម្មណ៍តាមចក្ខុទ្វារ

២. សោតទ្វារវិថី គឺវិថីចិត្តដែលមានសម្លេងជាអារម្មណ៍តាម សោតទ្វារ

៣. ឃានទ្វារវិថី គឺវិថីចិត្តដែលមានក្លិនជាអារម្មណ៍តាមឃានទ្វារ

៤. ជិវ្ហាទ្វារវិថី គឺវិថីចិត្តដែលមានរសជាអារម្មណ៍តាមជិវ្ហាទ្វារ

៥. កាយទ្វារវិថី គឺវិថីចិត្តដែលមានផោដ្ឋព្វៈជាអារម្មណ៍តាម កាយទ្វារ ។

រួមវិថីចិត្តទាំង ៥ ដែលមានអារម្មណ៍ ៥ នេះ ហៅថា បញ្ចទ្វារវិថី មានសង្គហគាថាពោលទុកថា ÷

## សង្គហគាថា

*៣. វិថីចិត្តានិ សត្តេវ ចិត្តុប្បាទា ចតុទ្ទស*

*ចតុប្បញ្ញាស វិត្ថារា បញ្ចទ្វារេ យថារហំ ។*

ក្នុងបញ្ចទ្វារ មានវិថីចិត្តទាំងឡាយ ៧ យ៉ាង មានចិត្តុប្បាទ ១៤

ដោយពិស្ដារមានចិត្តុប្បាទ ៥៤ តាមសមគួរ ។

**អធិប្បាយសង្គហគាថា** ក្នុងបញ្ចទ្វារវិថីនេះ កាលបើពោលដោយវិថី មានឈ្មោះ ៧ យ៉ាងគឺ ÷

១. អាវជ្ជនវិថី ១ វិថី

២. បញ្ចវិញ្ញាណវិថី ១ វិថី

៣. សម្បដិច្ឆន្នវិថី ១ វិថី

៤. សន្តីរណវិថី ១ វិថី

៥. វោដ្ឋវនវិថី ១ វិថី

៦. ជវនវិថី ១ វិថី

៧. តទាលម្ពណវិថី ១ វិថី

**កាលបើពោលដោយចិត្តុប្បាទ** គឺការកើតឡើងនៃចិត្តមាន ១៤ គឺ

១. បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង

២. ទ្វិបញ្ចវិញ្ញាណចិត្ត ១ ដួង

៣. សម្បដិច្ឆន្នចិត្ត ១ ដួង

៤. សន្តីរណចិត្ត ១ ដួង

៥. វោដ្ឋវនចិត្ត ១ ដួង

៦. ជវនចិត្ត ៧ ដួង

៧. តទាលម្ពណចិត្ត ២ ដួង

**បើពោលដោយពិស្ដារ** មានចិត្តុប្បាទកើតបាន ៥៤ តាមសម

គួរ គឺ ÷

១. បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង

២. ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ដួង

៣. សម្បដិច្ឆន្នចិត្ត ២ ដួង

៤. សន្តីរណចិត្ត ៣ ដួង

៥. វោដ្ឋវនចិត្ត ១ ដួង

៦. កាមជវនចិត្ត ២៩ ដួង

៧. តទាលម្ពណចិត្ត ១១ ដួង

រួមចិត្តុប្បាទ ៥៤ ដួង ដោយវៀរសន្តីរណចិត្ត ៣ ព្រោះ តទាលម្ពណចិត្ត ១១ មានសន្តីរណចិត្ត ៣ រួមនៅជាមួយហើយ ។

វិសយបវត្តិ គឺការប្រព្រឹត្តទៅនៃអារម្មណ៍ ក្នុងបញ្ចទ្វារ តែទ្វារនីមួយៗ មាន ៤ ន័យ គឺ ÷

១. អតិមហន្តារម្មណ៍ បានដល់អារម្មណ៍ដែលមានកម្លាំងច្រើន ។

២. មហន្តារម្មណ៍ បានដល់អារម្មណ៍ដែលមានកម្លាំង ។

៣. បរិត្តារម្មណ៍ បានដល់អារម្មណ៍ដែលមានកម្លាំងតិច ។

៤. អតិបរិត្តារម្មណ៍ បានដល់អារម្មណ៍ដែលមានកម្លាំង តិចតួចបំផុត ។

*អធិប្បាយ* អតិមហន្តារម្មណ៍ ក្នុងអារម្មណ៍ ៥ អារម្មណ៍ណាមួយ

ដែលមានកម្លាំងច្រើន ក៏ព្រោះមានសេចក្ដីប្រព្រឹត្តទៅ ( អាយុ) ច្រើនដល់ទៅ ១៧ ខណៈ ចិត្ត ( ខណៈធំ) គឺថា អារម្មណ៍ ១ ក្នុងអារម្មណ៍ទាំង ៥ នោះ កន្លងអតីតភវង្គទៅ ១ ខណៈ ហើយធ្វើឱ្យភវង្គញ័រ ២ ខណៈ ( ភវង្គចលនៈ ភវង្គុប្បច្ឆេទៈ) ហើយបញ្ចទ្វារាវជ្ជនៈកើតរលត់ ១ ខណៈ បន្ទាប់មកចិត្តមានចក្ខុវិញ្ញាណជាដើម ១ ខណៈ សម្បដិច្ឆន្នៈ ១ ខណៈ សន្តីរណៈ ១ ខណៈ វោដ្ឋវនៈ ១ ខណៈ ជវនៈ ៧ ខណៈ និងតទាលម្ពណៈ ២ ខណៈ កើតរលត់តាមលំដាប់ ហើយអារម្មណ៍ ១ ក្នុងបណ្ដាអារម្មណ៍ទាំង ៥ នោះក៏រលត់ទៅ តអំពីនោះក៏ប្រព្រឹត្តទៅក្នុងភវង្គ នេះហៅថា អតិមហន្តារម្មណ៍ មាន ១ ន័យ ។

រាប់ចាប់តាំងអំពីបញ្ចារម្មណ៍ កន្លងអតីតភវង្គទៅ ២ ឬ ៣ ខណៈ ហើយចិត្តក៏ប្រព្រឹត្តទៅរហូតដល់ជវនៈ អារម្មណ៍នោះក៏រលត់ ហើយចិត្តក៏ប្រព្រឹត្តទៅក្នុងភវង្គ នេះហៅថា មហន្តារម្មណ៍ អារម្មណ៍មានកម្លាំងល្មមប្រមាណ អារម្មណ៍នេះមាន ២ ន័យ ។

រាប់ចាប់តាំងអំពីបញ្ចារម្មណ៍ កន្លងអតីតភវង្គទៅ ៤ ដល់ ៩ ខណៈ ទៅអស់ ( អាយុ) ត្រង់វោដ្ឋវនៈហើយក៏ជាភវង្គ នេះហៅថា បរិត្តារម្មណ៍ មាន ៦ ន័យ ។ រាប់ចាប់តាំងអំពីបញ្ចារម្មណ៍ កន្លងអតីតភវង្គទៅ ១០ ខណៈ រហូតដល់ខណៈទី ១៥ ហើយក៏អស់( អាយុ) ត្រង់ភវង្គចលនៈ អារម្មណ៍នោះក៏រលត់ បន្ទាប់មក ចិត្តក៏ប្រព្រឹត្តទៅក្នុងភវង្គតាមប្រក្រតីដើម នេះហៅថា អតិបរិត្តារម្មណ៍ អារម្មណ៍តូចបំផុត មាន ៦ ន័យ ។

គប្បីជ្រាប បញ្ចារម្មណ៍ទាំង ៤ និងសភាពវិថីចិត្ត តែម្យ៉ាង១ ដូចតទៅនេះ គឺ ÷

១. អតិមហន្តារម្មណ៍ ១ ន័យ

២. មហន្តារម្មណ៍ ២ ន័យ

៣. បរិត្តារម្មណ៍ ៦ ន័យ

៤. អតិបរិត្តារម្មណ៍ ៦ ន័យ



## ១. អតិមហន្តារម្មណ៍ ១ ន័យ

| | | | | |
|---|---|---|---|---|
| ***ចិត្តផុតវិថី*** | ១ | អតីតភវង្គ | បានដល់ កាមបដិសន្ធិ | ១០ ដួង |
| | ២ | ភវង្គចលនៈ | បានដល់ កាមបដិសន្ធិ | ១០ ដួង |
| | ៣ | ភវង្គុបច្ឆេទៈ | បានដល់ កាមបដិសន្ធិ | ១០ ដួង |
| ***វិថីចិត្ត*** | ៤ | បញ្ចទ្វារាវជ្ជនចិត្តបានដល់ | កិរិយាមនោធាតុ | ១ ដួង |
| | ៥ | បញ្ចវិញ្ញាណ | បានដល់ ទ្វិបញ្ចវិញ្ញាណ | ១០ ដួង |
| | ៦ | សម្បដិច្ឆន្នៈ | បានដល់ វិបាកមនោធាតុ | ២ ដួង |
| | ៧ | សន្តីរណៈ បានដល់ សន្តីរណវិបាក | | ៣ ដួង |
| | ៨ | វោដ្ឋវនៈ បានដល់ កិរិយាមនោវិញ្ញាណធាតុ | | ១ ដួង |
| | ៩ | ជវនៈ | | |
| | ១០ | ជវនៈ | គឺកាមជវន ២៩ { អកុសលចិត្ត | ១២ ដួង |
| | ១១ | ជវនៈ | ហសិតុប្បាទចិត្ត | ១ ដួង |
| | ១២ | ជវនៈ | មហាកុសលចិត្ត | ៨ ដួង |
| | ១៣ | ជវនៈ | មហាកិរិយាចិត្ត | ៨ ដួង |
| | ១៤ | ជវនៈ | | |
| | ១៥ | ជវនៈ | | |
| | ១៦ | តទាលម្ពណៈ | គឺ { សន្តីរណវិបាក | ៣ ដួង |
| | ១៧ | តទាលម្ពណៈ | មហាវិបាក | ៨ ដួង |
| ***ចិត្តផុតវិថី*** | ០ | ភវង្គបាតៈ | គឺ ចិត្តប្រព្រឹត្តទៅក្នុងក្រសែភវង្គ ។ | |

## ចំណាំ

អតិមហន្តារម្មណ៍នេះ មានអារម្មណ៍ប៉ះខ្ទប់មួយខណៈ សល់ ១៦ ខណៈទៀត ប្រព្រឹត្តទៅក្នុង

១. ចក្ខុទ្វារវិថី

២. សោតទ្វារវិថី

៣. ឃានទ្វារវិថី

៤. ជីវ្ហាទ្វារវិថី

៥. កាយទ្វារវិថី

# ២. មហន្តារម្មណ៍ ២ន័យ

| មហន្តារម្មណ៍ន័យទី ១ | | | | | | |
|---|---|---|---|---|---|---|
| *ចិត្តផុតវិថី* | ១ | អតីតភវង្គ | កើតឡើង | ១ ខណៈ | | |
| | ២ | អតីតភវង្គ | កើតឡើង | ១ ខណៈ | | |
| | ៣ | ភវង្គចលនៈ | កើតឡើង | ១ ខណៈ | | |
| | ៤ | ភវង្គុបច្ឆេទៈ | កើតឡើង | ១ ខណៈ | | |
| *វិថីចិត្ត* | ៥ | បញ្ចទ្វារាវជ្ជនៈ | កើតឡើង | ១ ខណៈ | ជាវិថីទី ១ | |
| | ៦ | បញ្ចវិញ្ញាណ | .. | ១ ខណៈ | ជាវិថីទី ២ | |
| | ៧ | សម្បដិច្ឆន្នៈ | .. | ១ ខណៈ | ជាវិថីទី ៣ | |
| | ៨ | សន្តីរណៈ | .. | ១ ខណៈ | ជាវិថីទី ៤ | |
| | ៩ | វោដ្ឋវនៈ | .. | ១ ខណៈ | ជាវិថីទី ៥ | |
| | ១០ | ជវនៈ | | | | |
| | ១១ | ជវនៈ | | | | |
| | ១២ | ជវនៈ | | | | |
| | ១៣ | ជវនៈ | ជវនចិត្ត | ៧ ខណៈ | ជាវិថីទី ៦ | |
| | ១៤ | ជវនៈ | | | | |
| | ១៥ | ជវនៈ | | | | |
| | ១៦ | ជវនៈ | | | | |
| *ចិត្តផុតវិថី* | ១៧ | ភវង្គ | | | | |

| មហាទ្វារមួយនំន័យទី ២ | | | | | | |
|---|---|---|---|---|---|---|
| ចិត្តផុតវិថី | ១ | អតីតភវង្គ | | កើត ១ ខណៈ | | |
| | ២ | អតីតភវង្គ | | កើត ១ ខណៈ | | |
| | ៣ | អតីតភវង្គ | | កើត ១ ខណៈ | | |
| | ៤ | ភវង្គចលនៈ | | កើត ១ ខណៈ | | |
| | ៥ | ភវង្គុបច្ឆេទៈ | | កើត ១ ខណៈ | | |
| វិថីចិត្ត | ៦ | បញ្ចទ្វារាវជ្ជនៈ | កើតឡើង | ១ ខណៈ | ជាវិថីទី ១ |
| | ៧ | បញ្ចវិញ្ញាណ | .. | ១ ខណៈ | ជាវិថីទី ២ |
| | ៨ | សម្បដិច្ឆនៈ | .. | ១ ខណៈ | ជាវិថីទី ៣ |
| | ៩ | សន្តីរណៈ | .. | ១ ខណៈ | ជាវិថីទី ៤ |
| | ១០ | វោដ្ឋវនៈ | .. | ១ ខណៈ | ជាវិថីទី ៥ |
| | ១១ | ជវនៈ | | | |
| | ១២ | ជវនៈ | | | |
| | ១៣ | ជវនៈ | | | |
| | ១៤ | ជវនៈ | ជវនចិត្ត | ៧ ខណៈ | ជាវិថីទី ៦ |
| | ១៥ | ជវនៈ | | | |
| | ១៦ | ជវនៈ | | | |
| | ១៧ | ជវនៈ | | | |
| ចិត្តផុតវិថី | ០ | ភវង្គ | ចិត្តប្រព្រឹត្តទៅក្នុងក្រសែភវង្គ | | |

# ៣. បរិត្តារម្មណ៍មាន ៦ ន័យ

| បរិត្តារម្មណ៍ន័យទី ១ | | | | | |
|---|---|---|---|---|---|
| *ចិត្តផុតវិថី* | ១ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ២ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៣ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៤ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៥ | ភវង្គចលនៈ | | កើត ១ ខណៈ | |
| | ៦ | ភវង្គុបច្ឆេទៈ | | កើត ១ ខណៈ | |
| *វិថីចិត្ត* | ៧ | បញ្ចទ្វារាវជ្ជនៈ | កើតឡើង | ១ ខណៈ | ជាវិថីទី ១ |
| | ៨ | បញ្ចវិញ្ញាណ | " | ១ ខណៈ | ជាវិថីទី ២ |
| | ៩ | សម្បដិច្ឆន្នៈ | " | ១ ខណៈ | ជាវិថីទី ៣ |
| | ១០ | សន្តីរណៈ | " | ១ ខណៈ | ជាវិថីទី ៤ |
| | ១១ | វោដ្ឋវនៈ | កើតឡើង | ៣ ខណៈ | ជាវិថីទី ៥ |
| | ១២ | វោដ្ឋវនៈ | | | |
| | ១៣ | វោដ្ឋវនៈ | | | |
| *ចិត្តផុតវិថី* | ១៤ | ភវង្គ | កើតឡើង ផុតចាកវិថី | ៤ ខណៈ | ជាចិត្ត |
| | ១៥ | ភវង្គ | | | |
| | ១៦ | ភវង្គ | | | |
| | ១៧ | ភវង្គ | | | |

| ចរិត្តារម្មណ៍ទំយទី ២ | | | |
|---|---|---|---|
| | ១ | អតីតភវង្គ | កើត ១ ខណៈ |
| | ២ | អតីតភវង្គ | កើត ១ ខណៈ |
| | ៣ | អតីតភវង្គ | កើត ១ ខណៈ |
| ចិត្តផុតវិថី | ៤ | អតីតភវង្គ | កើត ១ ខណៈ |
| | ៥ | អតីតភវង្គ | កើត ១ ខណៈ |
| | ៦ | ភវង្គចលនៈ | កើត ១ ខណៈ |
| | ៧ | ភវង្គុប្បច្ឆេទៈ | កើត ១ ខណៈ |
| | ៨ | បញ្ចទ្វារាវជ្ជនៈ | កើតឡើង ១ ខណៈ ជាវិថីទី ១ |
| | ៩ | បញ្ចវិញ្ញាណ | ,, ១ ខណៈ ជាវិថីទី ២ |
| | ១០ | សម្បដិច្ឆន្នៈ | ,, ១ ខណៈ ជាវិថីទី ៣ |
| វិថីចិត្ត | ១១ | សន្តីរណៈ | ,, ១ ខណៈ ជាវិថីទី ៤ |
| | ១២ | វោដ្ឋវនៈ | |
| | ១៣ | វោដ្ឋវនៈ | } កើតឡើង ៣ ខណៈ ជាវិថីទី ៥ |
| | ១៤ | វោដ្ឋវនៈ | |
| ចិត្តផុត | ១៥ | ភវង្គ | |
| វិថី | ១៦ | ភវង្គ | } កើតឡើង ៣ ខណៈ ជាចិត្ត |
| | ១៧ | ភវង្គ | ផុតចាកវិថី |

| បរិត្តារម្មណ៍នំយទី ៣ | | | | | |
|---|---|---|---|---|---|
| ចិត្តផុតវិថី | ១ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ២ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៣ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៤ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៥ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៦ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៧ | ភវង្គចលនៈ | | កើត ១ ខណៈ | |
| | ៨ | ភវង្គុប្បច្ឆេទៈ | | កើត ១ ខណៈ | |
| វិថីចិត្ត | ៩ | បញ្ចទ្វារាវជ្ជនៈ | កើតឡើង | ១ ខណៈ | ជាវិថីទី ១ |
| | ១០ | បញ្ចវិញ្ញាណ | .. | ១ ខណៈ | ជាវិថីទី ២ |
| | ១១ | សម្បដិច្ឆន្នៈ | .. | ១ ខណៈ | ជាវិថីទី ៣ |
| | ១២ | សន្តីរណៈ | .. | ១ ខណៈ | ជាវិថីទី ៤ |
| | ១៣ | វោដ្ឋវនៈ | | | |
| | ១៤ | វោដ្ឋវនៈ | កើតឡើង | ៣ ខណៈ | ជាវិថីទី ៥ |
| | ១៥ | វោដ្ឋវនៈ | | | |
| ចិត្តផុតវិថី | ១៦ | ភវង្គ | កើតឡើង | ២ ខណៈ | ជាចិត្ត |
| | ១៧ | ភវង្គ | ផុតចាកវិថី | | |

| បរិច្ឆេទរូបធ៌ន៍ទំយទី ៤ | | | | | |
|---|---|---|---|---|---|
| | ១ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ២ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៣ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៤ | អតីតភវង្គ | | កើត ១ ខណៈ | |
| *ចិត្តផុតវិថី* | ៥ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៦ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៧ | អតីតភវង្គ | | កើត ១ ខណៈ | |
| | ៨ | ភវង្គចលនៈ | | កើត ១ ខណៈ | |
| | ៩ | ភវង្គុប្បច្ឆេទៈ | | កើត ១ ខណៈ | |
| | ១០ | បញ្ចទ្វារាវជ្ជនៈ | កើតឡើង | ១ ខណៈ | ជាវិថីទី ១ |
| | ១១ | បញ្ចវិញ្ញាណ | .. | ១ ខណៈ | ជាវិថីទី ២ |
| | ១២ | សម្បដិច្ឆន្នៈ | .. | ១ ខណៈ | ជាវិថីទី ៣ |
| *វិថីចិត្ត* | ១៣ | សន្តីរណៈ | .. | ១ ខណៈ | ជាវិថីទី ៤ |
| | ១៤ | វោដ្ឋវនៈ | | | |
| | ១៥ | វោដ្ឋវនៈ | កើតឡើង | ៣ ខណៈ | ជាវិថីទី ៥ |
| | ១៦ | វោដ្ឋវនៈ | | | |
| *ចិត្តផុតវិថី* | ១៧ | ភវង្គ | ១ ខណៈ ជាចិត្តផុតចាកវិថី | | |

| បរិត្តារម្មណ៍នយទី ៥ | | | | | |
|---|---|---|---|---|---|
| | ១ | អតីតភវង្គ | កើត ១ ខណៈ | | |
| | ២ | អតីតភវង្គ | កើត ១ ខណៈ | | |
| | ៣ | អតីតភវង្គ | កើត ១ ខណៈ | | |
| | ៤ | អតីតភវង្គ | កើត ១ ខណៈ | | |
| ចិត្តផុតវិថី | ៥ | អតីតភវង្គ | កើត ១ ខណៈ | | |
| | ៦ | អតីតភវង្គ | កើត ១ ខណៈ | | |
| | ៧ | អតីតភវង្គ | កើត ១ ខណៈ | | |
| | ៨ | អតីតភវង្គ | កើត ១ ខណៈ | | |
| | ៩ | ភវង្គចលនៈ | កើត ១ ខណៈ | | |
| | ១០ | ភវង្គុបច្ឆេទៈ | កើត ១ ខណៈ | | |
| | ១១ | បញ្ចទ្វារាវជ្ជនៈ | កើតឡើង | ១ ខណៈ | ជាវិថីទី ១ |
| | ១២ | បញ្ចវិញ្ញាណ | .. | ១ ខណៈ | ជាវិថីទី ២ |
| | ១៣ | សម្បដិច្ឆនៈ | .. | ១ ខណៈ | ជាវិថីទី ៣ |
| វិថីចិត្ត | ១៤ | សន្តីរណៈ | .. | ១ ខណៈ | ជាវិថីទី ៤ |
| | ១៥ | វោដ្ឋវនៈ | | | |
| | ១៦ | វោដ្ឋវនៈ | កើតឡើង | ៣ ខណៈ | ជាវិថីទី ៥ |
| | ១៧ | វោដ្ឋវនៈ | | | |
| ចិត្តផុតវិថី | ០ | ភវង្គ | | | |

| បរិត្តារម្មណ៍ន័យទី ៦ | | | |
|---|---|---|---|
| | ១ | អតីតភវង្គ | កើត ១ ខណៈ |
| | ២ | អតីតភវង្គ | កើត ១ ខណៈ |
| | ៣ | អតីតភវង្គ | កើត ១ ខណៈ |
| | ៤ | អតីតភវង្គ | កើត ១ ខណៈ |
| *ចិត្តមុតវិថី* | ៥ | អតីតភវង្គ | កើត ១ ខណៈ |
| | ៦ | អតីតភវង្គ | កើត ១ ខណៈ |
| | ៧ | អតីតភវង្គ | កើត ១ ខណៈ |
| | ៨ | អតីតភវង្គ | កើត ១ ខណៈ |
| | ៩ | អតីតភវង្គ | កើត ១ ខណៈ |
| | ១០ | ភវង្គចលនៈ | កើត ១ ខណៈ |
| | ១១ | ភវង្គុបច្ឆេទៈ | កើត ១ ខណៈ |
| | ១២ | បញ្ចទ្វារាវជ្ជនៈ | កើតឡើង ១ ខណៈ ជាវិថីទី ១ |
| | ១៣ | បញ្ចវិញ្ញាណ | " ១ ខណៈ ជាវិថីទី ២ |
| | ១៤ | សម្បដិច្ឆនៈ | " ១ ខណៈ ជាវិថីទី ៣ |
| *វិថីចិត្ត* | ១៥ | សន្តីរណៈ | " ១ ខណៈ ជាវិថីទី ៤ |
| | ១៦ | វោដ្ឋវនៈ | } កើតឡើង ២ ខណៈ ជាវិថីទី ៥ |
| | ១៧ | វោដ្ឋវនៈ | |
| *ចិត្តមុតវិថី* | ០ | ភវង្គ | |

***អធិប្បាយៈ*** ក្នុងបរិត្តារម្មណ៍ ៦ ន័យ ន័យទី ១ មានអារម្មណ៍កន្លងចិត្តដែលជាអតីតភវង្គ ៤ ខណៈ ហើយភវង្គក៏ញ័រ ២ ខណៈ (ភវង្គចលនៈ ភវង្គុបច្ឆេទៈ) តអំពីនោះ វិថីក៏កើតឡើងប្រព្រឹត្តទៅតាម

លំដាប់ រហូតដល់ខណៈទី ១១ គឺវោដ្ឋវនៈកើត ១ ខណៈ តែអារម្មណ៍ក្នុងវិថីនៅសល់ ៦ ខណៈទៀតក៏រលត់ ទើបជវនៈមិនកើត ព្រោះជវនៈដោយប្រក្រតី កាលកើត រមែងកើត ៧ ខណៈ កាលបើដូច្នោះ ទើបវោដ្ឋវនៈកើត ច្រំដែល ២ ខណៈ គឺខណៈទី ១២ និងទី ១៣ បន្ទាប់ពីនោះចិត្តក៏ប្រព្រឹត្តទៅក្នុងភវង្គ ៤ ខណៈ ។

សួរថា ព្រោះហេតុអ្វីទើបអតិមហន្តារម្មណ៍ និងមហន្តារម្មណ៍វិថីមានវោដ្ឋវនៈកើត ១ ខណៈប៉ុណ្ណោះ ចំណែកក្នុងបរិត្តារម្មណ៍ទាំងនេះ មានវោដ្ឋវនៈ ៣ ខណៈខ្លះ ២ ខណៈខ្លះ ?

ឆ្លើយថា ព្រោះអតិមហន្តារម្មណ៍ជាដើម មានអារម្មណ៍ប្រាកដច្បាស់ វោដ្ឋវនៈរមែងកំណត់កាត់ក្តីអារម្មណ៍បានងាយស្រួល ទើបកើតឡើងតែមួយគ្រា ធ្វើវោដ្ឋវនកិច្ច ដោយយោនិសោមនសិការ ឬអយោនិសោមនសិការ ចំណែកបរិត្តារម្មណ៍វិថីនេះ មានអារម្មណ៍មិនប្រាកដច្បាស់ល្មមនឹងធ្វើវោដ្ឋវនកិច្ចបាន ទើបវោដ្ឋវនៈកើតឡើង ៣ ខណៈ ចំពោះន័យទី ៦ វោដ្ឋវនៈកើតត្រឹមតែ ២ ខណៈ ព្រោះអារម្មណ៍រលត់ចុះត្រឹមប៉ុណ្ណោះ ដែលជាការផុតវិថី ។

## ៤. អតិបរិត្តារម្មណ៍ ៦ ន័យ

អារម្មណ៍ដែលមកកាន់គន្លង មិនល្មមដល់ការកើតឡើងនៃវោដ្ឋវនៈ កន្លងទៅជិតដល់សេចក្តីរលត់ ឈ្មោះថា អតិបរិត្តារម្មណ៍ ។ អារម្មណ៍នេះមានត្រឹមតែភវង្គចលនៈប៉ុណ្ណោះ វិថីចិត្ត គឺចិត្តកើតក្នុងវិថី

មិនមាន ជាមោឃវារៈ (វារៈដែលទទេ) ព្រោះអារម្មណ៍មិនមានវិថីចិត្តកើត ដល់យ៉ាងនោះ លោកក៏ហៅថា វិថី ព្រោះមានអារម្មណ៍កន្លងមកកាន់គន្លង ។

| អតិបរិត្តារម្មណ៍នយទី ១ | | | |
|---|---|---|---|
| *ចិត្តផុតវិថីទាំងអស់* | ១-១០ | អតីតភវង្គ | ១០ ខណៈ |
| | ១១-១២ | ភវង្គចលនៈ | ២ ខណៈ |
| | ១៣-១៧ | ភវង្គុបច្ឆេទៈ | ៥ ខណៈ |

| អតិបរិត្តារម្មណ៍នយទី ២ | | | |
|---|---|---|---|
| *ចិត្តផុតវិថីទាំងអស់* | ១-១១ | អតីតភវង្គ | ១១ ខណៈ |
| | ១២-១៣ | ភវង្គចលនៈ | ២ ខណៈ |
| | ១៤-១៧ | ភវង្គុបច្ឆេទៈ | ៤ ខណៈ |

| អតិបរិត្តារម្មណ៍នយទី ៣ | | | |
|---|---|---|---|
| *ចិត្តផុតវិថីទាំងអស់* | ១-១២ | អតីតភវង្គ | ១២ ខណៈ |
| | ១៣-១៤ | ភវង្គចលនៈ | ២ ខណៈ |
| | ១៥-១៧ | ភវង្គុបច្ឆេទៈ | ៣ ខណៈ |

| អតិបរិត្តារម្មណ៍នយទី ៤ | | | |
|---|---|---|---|
| *ចិត្តផុតវិថីទាំងអស់* | ១-១៣ | អតីតភវង្គ | ១៣ ខណៈ |
| | ១៤-១៥ | ភវង្គចលនៈ | ២ ខណៈ |
| | ១៦-១៧ | ភវង្គុបច្ឆេទៈ | ២ ខណៈ |

| អតិមហន្តារម្មណ៍នំយទី ៥ | | |
|---|---|---|
| ចិត្តជុតវិថីទាំងអស់ | ១-១៤ | អតីតភវង្គ ១៤ ខណៈ |
| | ១៥-១៦ | ភវង្គចលនៈ ២ ខណៈ |
| | ១៧ | ភវង្គុបច្ឆេទៈ ១ ខណៈ |

| អតិមហន្តារម្មណ៍នំយទី ៦ | | |
|---|---|---|
| ចិត្តជុតវិថីទាំងអស់ | ១-១៥ | អតីតភវង្គ ១៥ ខណៈ |
| | ១៦-១៧ | ភវង្គចលនៈ ២ ខណៈ |

## បញ្ចទ្វារមាន ៤ វារៈ

វិសយបវត្តិ គឺសេចក្តីប្រព្រឹត្តទៅនៃអារម្មណ៍ក្នុងទ្វារ ៥ មានចក្ខុទ្វារវិថីជាដើម ចាប់តាំងពីកើតឡើង រហូតអស់អារម្មណ៍មួយគ្រាៗ ហៅ-ថា វារៈ ១ គឺ ÷

១. តទាលម្ពណវារៈ បានដល់ វារៈមានតទាលម្ពណជាទីបំផុត

២. ជវនវារៈ បានដល់ វារៈមានជវនៈជាទីបំផុត

៣. វោដ្ឋវនវារៈ បានដល់ វារៈមានវោដ្ឋវនៈជាទីបំផុត

៤. មោឃវារៈ បានដល់ វារៈដែលសូន្យចាកចិត្តក្នុងវិថី ។

ចបវិសយបវត្តិក្នុងបញ្ចទ្វារ ។

## អធិប្បាយអតិមហន្តារម្មណ៍ជាដើម

អតិមហន្តារម្មណ៍ មានអាយុ ១៧ ខណៈធំ ឬ ៥១ អនុខណៈនោះ ព្រះអនុរុទ្ធាចារ្យពោលទុកថា អារម្មណ៍ ៥ កន្លងទៅ ១ ខណៈចិត្តក្តី កន្លងទៅច្រើនខណៈរបស់ចិត្តក្តី ដល់ឋិតិខណៈហើយនោះ រមែងនឹងមកកាន់គន្លងក្នុងបញ្ចទ្វារ ។ ពាក្យថារមែងមកកាន់គន្លង គឺថា រូបារម្មណ៍ និងសទ្ទារម្មណ៍ តាំងនៅតែក្នុងទីរបស់ខ្លួនៗ រមែងដល់សេចក្តីជាគោចរ ព្រោះហេតុនោះ អារម្មណ៍ទាំង ២ នោះ ប្រព្រឹត្តទៅក្នុងកលាបៈ មិនមែនតិចរមែង មកកាន់គន្លង តាមគួរដល់ការតិតដល់ (អាវជ្ជនៈ)។ ក្នុងអដ្ឋកថាធម្មសង្គណីពោលថា ព្រះអាទិត្យ និងព្រះចន្ទ សូម្បីតាំងនៅក្នុងទីនៅរបស់ខ្លួនឆ្ងាយអំពីលោកនេះច្រើន ក៏ដល់សេចក្តីជាគោចរបានដោយបន្តគ្នាមក ។

ចំណែកគន្ធារម្មណ៍, រសារម្មណ៍ និងផោដ្ឋព្វារម្មណ៍ ជាប់ទាក់ទងក្នុងវត្ថុដែលអាស្រ័យមកខ្ទប់ឃានបសាទជាដើមនោះឯង ទើបជាហេតុនៃការកើតឡើងរបស់វិញ្ញាណ ព្រោះហេតុនោះ អារម្មណ៍ទាំងនេះ សូម្បីប្រព្រឹត្តទៅក្នុងកលាបៈ ១ កលាបៈ ក៏រមែងមកកាន់គន្លង ។ ពិតណាស់បសាទ សូម្បីប្រព្រឹត្តទៅក្នុងកលាបៈតែម្យ៉ាង ក៏រមែងដល់សេចក្តីជាទីតាំងនៃវិញ្ញាណ ។ តែបសាទទាំងនោះ កើតជាមួយភវង្គដែលជាអនន្តរប្បច្ច័យដល់ភវង្គចលនៈ អាចារ្យមួយពួកទៀតពោលថា កើតជាមួយអាវជ្ជនចិត្ត ។

កាលរូបារម្មណ៍កន្លងអតីតភវង្គ ១ ខណៈ ហើយក៏ញ៉ាំងភវង្គឱ្យ

ញ៉ូវ ២ គ្រា គឺគ្រាមុនដំបូងជាភវង្គចលនៈ គ្រាក្រោយជាភវង្គុបច្ឆេទៈ រួមជាភវង្គ ៣ គឺ អតីតភវង្គ ភវង្គចលនៈ និងភវង្គុបច្ឆេទៈ ជាចិត្តផុតវិថី ហៅថា វិថីមុត្តចិត្ត បានដល់កាមចិត្ត (វិបាក) ១០ ដួងគឺ ÷

មហាវិបាកចិត្ត ៨ និងឧបេក្ខាសន្តីរណចិត្ត ២ ។

សួរថា អតីតភវង្គ បានដល់ចិត្តអ្វី ?

ឆ្លើយថា អតីតភវង្គ ញែកជា *អតីតំ ភវង្គំ* ។ *អតីតំ* (កន្លងទៅ) *ភវង្គំ* (អង្គនៃភព) គឺចិត្តដែលតម្រង់ភពជាតិកំណើត កាលអារម្មណ៍ថ្មីមកកាន់គន្លងបញ្ចទ្វារវិថី អារម្មណ៍នោះកន្លងទៅអស់ ១ ខណៈចិត្ត នៅមានអាយុសល់ ១៦ ខណៈចិត្ត ហៅថា អតិមហន្តៈ ។ បើកន្លងទៅអស់ ២-៣ ខណៈចិត្ត អាយុអារម្មណ៍សល់ ១៥-១៤ ខណៈចិត្ត ហៅថា មហន្តៈ ។ កន្លងទៅអស់តាំងអំពី ៤-៩ ខណៈចិត្ត អាយុអារម្មណ៍សល់ពី ១៣-៨ ខណៈចិត្ត ឈ្មោះថា បរិត្តៈ ។ បើកន្លងទៅអស់ ១០-១៥ ខណៈចិត្ត សល់ ៧-២ ខណៈចិត្ត ឈ្មោះថា អតិបរិត្តៈ ។ អារម្មណ៍ដែលប្រាកដច្បាស់ ហៅថា វិភូតៈ ដែលមិនច្បាស់ ហៅថា អវិភូតៈ ។

អារម្មណ៍កន្លងអស់ខណៈចិត្ត ១ ដួងទៅ មានវិគ្រោះថា **តំ អតីតំ ឯតេសំ ឯតានិ វា តំ អតីតានីតិ ឯកចិត្តក្ខណាតីតានិ** ប្រែថា ខណៈចិត្តមួយដួងនោះ កន្លងបញ្ចារម្មណ៍ទាំងនេះទៅហើយ ឬថា អារម្មណ៍ទាំងនេះកន្លងខណៈចិត្ត ១ ដួងនោះទៅហើយ ព្រោះហេតុនោះ អារម្មណ៍នោះទើបឈ្មោះថា កន្លងខណៈចិត្តមួយដួងទៅ ។ បានដល់ អតីតភវង្គចិត្ត ។

សួរថា ភវង្គចលនៈបានដល់ចិត្តអ្វី ?

ឆ្លើយថា ភវង្គចលនៈ បានដល់ការញ៉ូរនៃភវង្គចិត្ត គឺកាលបើបញ្ចារម្មណ៍មកកាន់គន្លង ធ្វើឱ្យភវង្គចិត្តកន្លងទៅ ១ ខណៈហើយធ្វើឱ្យភវង្គចិត្តនោះញ៉ូរ ២ ខណៈទៀត។ ព្រះដីកាចារ្យពោលថា អតីតភវង្គរលត់ហើយក៏ធ្វើឱ្យភវង្គញ៉ូរ ២ គ្រា ដូចវចនត្ថៈថា ÷

**តត្ថ បឋមចិត្តំ ភវង្គសន្តតឹ ចាលេន្តំ វិយ ឧប្បជ្ជតីតិ ភវង្គចលនំ។** ប្រែថា ក្នុងភវង្គចិត្តទាំង ២ នោះ ចិត្តដួងទី ១ កើតឡើង ដូចជាកម្រើកនូវតំណនៃភវង្គ ព្រោះហេតុដូច្នោះ ទើបអាចារ្យទាំងឡាយពោលថា ភវង្គចលនៈ។

**ទុតិយំ តស្សា ឧប្បជ្ជនាការេន ឧប្បជ្ជនតោ ភវង្គុបច្ឆេទោ។** ប្រែថា ចិត្តដួងទី ២ ហៅថា ភវង្គុបច្ឆេទៈ ព្រោះកើតឡើងដោយអាការគឺការចូលទៅកាត់ការជាប់តនៃភវង្គដើមនោះ ឱ្យដាច់ចុះ។ ក្នុងបករណ៍អភិធម្មត្ថសង្គហៈនេះ ព្រះអនុរុទ្ធាចារ្យពោលចិត្តទាំង ២ ដួងនេះទុកដោយមិនប្លែកគ្នាថា "កាលភវង្គចិត្តញ៉ូរ ២ គ្រា" ដូច្នេះ។ កាលពោលដោយលំដាប់ ខណៈចិត្តទី ១ ជាអតីតភវង្គ ទី ២ ជាភវង្គចលនៈ និងទី ៣ ជាភវង្គុបច្ឆេទៈ។

ខណៈចិត្តទី ៤ ជាបញ្ចទ្វារាវជ្ជនៈអហេតុកកិរិយាចិត្ត ហៅថា វិថីបដិបាទកមនសិការ កើតឡើងរំពឹងដល់អារម្មណ៍ ដែលមកប៉ះខ្ទប់ក្នុងបញ្ចទ្វារ ដូចបាលីពោលថា ចក្ខាទិបញ្ចទ្វារេ **អាវជ្ជេតីតិ បញ្ចទ្វារាវជ្ជនំ។**

ប្រែថា ចិត្តណាវមែងរំពឹងដល់បញ្ចារម្មណ៍ ក្នុងបញ្ចទ្វារមានចក្ខុទ្វារជាដើម ព្រោះហេតុនោះ ទើបចិត្តនោះមានឈ្មោះថា បញ្ចទ្វារាវជ្ជនចិត្ត ។

ខណៈចិត្តទី ៥ បញ្ចវិញ្ញាណ បានដល់ចិត្ត ៥ ដួងទាំងនេះ គឺ ÷

១. ចក្ខុវិញ្ញាណ មាន ពណ៌ជាអារម្មណ៍
២. សោតវិញ្ញាណ មាន សម្លេងជាអារម្មណ៍
៣. ឃានវិញ្ញាណ មាន ក្លិនជាអារម្មណ៍
៤. ជីវ្ហាវិញ្ញាណ មាន រសជាអារម្មណ៍
៥. កាយវិញ្ញាណ មាន ផោដ្ឋព្វៈជាអារម្មណ៍ ។

មានវិគ្រោះស័ព្ទថា **ចក្ខាទិបញ្ចបសាទំ និស្សិតំ វិញ្ញាណំ បញ្ចវិញ្ញាណំ** ប្រែថា វិញ្ញាណអាស្រ័យបសាទរូប ៥ មានចក្ខុបសាទជាដើម ឈ្មោះថា បញ្ចវិញ្ញាណ។

ខណៈចិត្តទី ៦ ឈ្មោះថា សម្បដិច្ឆន្នៈ ជាវិបាក។ មានវិគ្រោះថា **រូបាទិបញ្ចារម្មណំ សម្បដិច្ឆតីតិ សម្បដិច្ឆន្នំ** ។ ប្រែថា ចិត្តណាវមែងទទួលបញ្ចារម្មណ៍ មានរូបារម្មណ៍ជាដើម ព្រោះហេតុនោះ ទើបចិត្តនោះឈ្មោះថា សម្បដិច្ឆន្នចិត្ត បានដល់ កុសលវិបាក ១ ដួង អកុសលវិបាក ១ ដួង ។

ខណៈចិត្តទី ៧ សន្តីរណៈ មានវិគ្រោះថា **សម្មា តីរេតីតិ សន្តីរណំ** ។ ប្រែថា ចិត្តណាវមែងពិចារណាអារម្មណ៍ ដោយពេញចិត្ត (ដោយល្អ) ព្រោះហេតុនោះ ចិត្តនោះទើបឈ្មោះថា សន្តីរណចិត្ត បានដល់អកុសលវិបាកចិត្ត ១ ដួងនិងកុសលវិបាកចិត្ត ២ ដួង ។ ក្នុងកុសលវិបាក ២

ដួងនោះ បើទទួលអារម្មណ៍ល្អថ្នាក់កណ្ដាល ឧបេក្ខាសន្តីរណកុសលវិបាក ក៏កើតឡើងធ្វើកិច្ច បើទទួលអតិឥដ្ឋារម្មណ៍ សោមនស្សសន្តីរណកុសលវិបាកកើតឡើងធ្វើកិច្ចពិចារណាអារម្មណ៍នោះ។

ខណៈចិត្តទី ៨ វោដ្ឋវនៈ បានដល់កិរិយាមនោវិញ្ញាណធាតុ (មនោទ្វារាវជ្ជនចិត្ត) ធ្វើកិច្ចកាត់ក្ដីអារម្មណ៍ មានវិគ្គហៈថា **បញ្ចទ្វារេ យថាសន្តីរិតមាលម្ពណំ វវត្ថបេតីតិ វោដ្ឋព្វនំ**។ ប្រែថា ចិត្តណាមែង កំណត់កាត់ក្ដី នូវអារម្មណ៍តាមដែលសន្តីរណចិត្តពិចារណាហើយក្នុងបញ្ចទ្វារវិថី ព្រោះហេតុនោះ ចិត្តនោះឈ្មោះថា វោដ្ឋវនចិត្ត។ បើកើតឡើងតាមមនោទ្វារ ហៅថាមនោទ្វារាវជ្ជនចិត្ត ធ្វើកិច្ចកាត់ក្ដីអារម្មណ៍ ដោយសេចក្ដីជាកុសល អកុសល ឬកិរិយា តាមគួរដល់បុគ្គល ដោយអំណាចយោនិសោមនសិការ ឬអយោនិសោមនសិការ។ ចិត្តនេះលោកហៅថា ជវនបដិបាទកមនសិការ ប្រែថា មនសិការឱ្យសម្រេចជាជវនៈ ឬជាផ្លូវឱ្យជវនៈ។

ខណៈចិត្តទី ៩-១៥ ជវនៈ បានដល់ចិត្តដែលសេព (សោយ) អារម្មណ៍ ឬស្ទុះទៅ មានវិគ្គហៈថា **ជវតីតិ ជវនំ** ប្រែថា ចិត្តណាមែងស្ទុះទៅ ព្រោះហេតុនោះ ចិត្តនោះទើបឈ្មោះថា ជវនចិត្ត។ ក្នុងទុតិយអត្ថយោជនា អធិប្បាយកិច្ចរបស់ជវនៈទុកថា "សេចក្ដីប្រព្រឹត្តទៅនៃចិត្ត ដែលប្រព្រឹត្តទៅលឿន ដូចស្ទុះទៅក្នុងអារម្មណ៍ ដោយអំណាចញ៉ាំងកិច្ចនោះៗ ឱ្យសម្រេចច្រើនគ្រា ឬមួយគ្រា ហៅថាជវនកិច្ច។ ព្រះដីកាចារ្យពោលថា

ដោយច្រើន ចិត្តស្ទុះទៅ ៧ វារៈ ក្នុវេលាសន្លប់ស្ទុះទៅ ៦ វារៈ ក្នុងវេលាជិតស្លាប់ ស្ទុះទៅ ៥ វារៈ ក្នុងកាមវិថីបានដល់ចិត្ត ២៩ ដួងដែលពោលរួចមកហើយ ។

ខណៈចិត្តទី ១៦-១៧ តទាលម្ពណៈ ជាវិបាកចិត្ត មាន ១១ ដួងគឺ សន្តីរណចិត្ត ៣ ដួង មហាវិបាកចិត្ត ៨ ដួង កើតចំពោះក្នុងអតិមហន្តារម្មណ៍ ជាចិត្តកើតតអំពីជវនចិត្ត ដូចវិគ្គហៈថា **តទេវ អាលម្ពណំ តទាលម្ពណំ** ប្រែថា អារម្មណ៍នោះឯង ជាតទាលម្ពណៈ។ កាលតទា- លម្ពណៈកើតរមែងប្រកបដោយអង្គ ៤ គឺ ១. ជាកាមជវនៈ ២. ជាកាម បុគ្គល ៣. ជាកាមអារម្មណ៍ ៤. វិថីជាវិភូតារម្មណ៍ ឬអតិមហន្តារម្មណ៍ ។

## ឧបមាតនចិត្តញ៉ែរ

ក្នុងភវង្គ ៣ មានអតីតភវង្គជាដើមនោះ មានពាក្យសួរថា ក៏កាលរូបជាដើមប៉ះខ្ទប់ត្រង់បសាទហើយ វិញ្ញាណដែលអាស្រ័យក្នុងបសាទប៉ុណ្ណោះនោះ គួរញ៉ែរមិនមែនឬ ? ក៏ភវង្គដែលអាស្រ័យហទយវត្ថុគួរញ៉ែរយ៉ាងណា ?

ឆ្លើយថា ភវង្គនោះគួរញ៉ែរ ព្រោះជាធម្មជាតិទាក់ទងតែជាមួយគ្នាដោយ អំណាចសន្តតិ ដូចជាថា សត្វរុយដែលទុំលើដុំក្រួស ដែលដាក់ទុកលើផ្ទៃស្គរស្បែកម្ខាង កាលយកឈើជាដើម វាយស្បែកស្គរម្ខាងទៀត ពេលដុំក្រួស (ប្រឡាក់ទឹកអំពៅ) ញ៉ែរទៅតាមការញ៉ែរនៃស្បែកស្គរ និងខ្សែជាដើម ដោយលំដាប់ សត្វរុយរមែងហើរទៅយ៉ាងណា កាលអាម្មណ៍មានរូបជាដើមប៉ះខ្ទប់ត្រង់បសាទហើយ ពេលមហាភូតរូបដែលជាទីអាស្រ័យ

នៃបសាទនោះញ័រ សូម្បីកាលហទយវត្ថុញ័រតាមការញ័រនៃរូបដែលសល់ជាប់ទាក់ទងនឹងមហាភូតរូបនោះដោយលំដាប់ ភវង្គដែលអាស្រ័យហទយវត្ថុ ក៏រមែងប្រព្រឹត្តទៅ ដោយអាការៈញ័រដូច្នោះនោះឯង ខនេះសមដូចពាក្យដែលលោកអាចារ្យព្រះធម្មបាលៈពោលទុកថា ÷

កាលអារម្មណ៍ មានរូបារម្មណ៍ជាដើម ប៉ះខ្ទប់បសាទវត្ថុហើយ ភវង្គចិត្តដែលអាស្រ័យហទយវត្ថុ ក៏ញ័រតាម ព្រោះជាប់ទាក់ទងជាមួយគ្នា បណ្ឌិតទើបពោលដោយប្រៀបធៀបនឹងដុំក្រួស ដូច្នេះ ។

## ឧបមាវិថីចិត្ត

ក្នុងអធិការនេះ ព្រះអដ្ឋកថាចារ្យទាំងឡាយ នាំឧបមាដោយផ្លែស្វាយជាដើមមក ដើម្បីឱ្យយល់សេចក្តីប្រព្រឹត្តទៅ នៃវិថីចិត្តបានដោយងាយ ។ បណ្តាឧបមាទាំងនោះ គប្បីជ្រាបឧបមាដោយផ្លែស្វាយដូចតទៅនេះ ÷

បានឮថា បុរសម្នាក់ដេកដណ្តប់ខ្លួនរហូតសីសៈ ដេកលក់នៅនឹងគល់ស្វាយដែលមានផ្លែ ភ្ញាក់ឡើងដោយសម្លេងផ្លែស្វាយ ១ ដែលធ្លាក់ចុះក្នុងទីជិតៗ បើកសំពត់ចេញអំពីសីសៈ បើកភ្នែកឡើងឃើញហើយ ចាប់ផ្លែស្វាយនោះមក ច្របាច់មើល ហិតក្លិន ដឹងថាផ្លែស្វាយទុំហើយ ទើបទទួលទាន លេបសាច់ផ្លែស្វាយ ដែលនៅក្នុងមាត់ចូលទៅព្រមទាំងទឹកមាត់ហើយដេកលក់ទៅក្នុងទីនោះដដែលទៀត ។

បណ្តាកាលទាំងនោះ កាលនៃភវង្គ ដូចវេលាដែលបុរសនោះ ដេក

លក់ ។ កាលដែលអារម្មណ៍ប៉ះខ្ទប់បសាទ ដូចវេលាដែលផ្លែស្វាយជ្រុះ ។ កាលនៃអាវជ្ជនចិត្ត ដូចវេលាដែលភ្ញាក់ឡើងដោយសម្លេងផ្លែស្វាយនោះ ។ វេលានៃចក្ខុវិញ្ញាណប្រព្រឹត្តទៅ ដូចវេលាដែលបើកភ្នែកក្រឡេកមើលហើយ ។ កាលនៃសម្បដិច្ឆន្នចិត្ត ដូចវេលាដែលកាន់យកផ្លែស្វាយ ។ កាលនៃសន្តីរណចិត្ត ដូចវេលាច្របាច់ផ្លែស្វាយ ។ កាលនៃវោដ្ឋវនចិត្ត ដូចវេលាហិតក្លិន ។ កាលនៃជវនចិត្ត ដូចវេលាដែលទទួលទាន ។ កាលនៃតទាលម្ពណចិត្ត ដូចវេលាលេបសាច់ផ្លែស្វាយ ដែលនៅក្នុងមាត់ចូលទៅ ព្រមទាំងទឹកមាត់ ។ កាលនៃភវង្គតទៅ ដូចវេលាដែលបុរសនោះដេកលក់ទៀត ។

## កិច្ចផ្សេងៗ នៃវិថីមិនច្រឡំគ្នា

ឧបមានេះ រមែងសំដែងដល់សេចក្ដីដែលធម៌ទាំងឡាយ មិនច្រឡំគ្នានិងគ្នា ដោយអំណាចនៃកិច្ច ៨ យ៉ាងនេះ គឺ ÷

| | |
|---|---|
| ការប៉ះខ្ទប់បសាទប៉ុណ្ណោះ | ជាកិច្ច នៃអារម្មណ៍ |
| ការរំពឹងដល់អារម្មណ៍ដែលប៉ះខ្ទប់ | ជាកិច្ច នៃអាវជ្ជនៈ |
| ត្រឹមតែការឃើញប៉ុណ្ណោះ | ជាកិច្ច នៃចក្ខុវិញ្ញាណ |
| ត្រឹមតែការទទួលអារម្មណ៍ប៉ុណ្ណោះ | ជាកិច្ច នៃសម្បដិច្ឆន្នៈ |
| ត្រឹមតែការពិចារណាអារម្មណ៍ | ជាកិច្ច នៃសន្តីរណៈ |
| ត្រឹមតែកាត់ក្ដីអារម្មណ៍ប៉ុណ្ណោះ | ជាកិច្ច នៃវោដ្ឋវនៈ |
| ការសោយរសនៃអារម្មណ៍ | ជាកិច្ច នៃជវនៈតែម្យ៉ាង |
| ការទទួលអារម្មណ៍ដូចគ្នានឹងជវនៈ | ជាកិច្ច នៃតទាលម្ពណៈ ។ |

ក៏ចិត្តដែលប្រព្រឹត្តទៅយ៉ាងនេះ សូម្បីមិនមានអ្នកធ្វើ ឬអ្នកប្រើឱ្យធ្វើ ដោយន័យថា អ្នកឯងឈ្មោះថាអាវជ្ជនៈ ចូរនៅក្នុងលំដាប់នៃភវង្គ អ្នកឯងឈ្មោះថា ជាទស្សនៈជាដើម យ៉ាងណាមួយ ចូរនៅក្នុងលំដាប់នៃអាវជ្ជនៈដូច្នេះជាដើម បណ្ឌិតគប្បីជ្រាបថា រមែងប្រព្រឹត្តទៅដោយអំណាចនៃចិត្តនិយាម[១] ប្រៀបដូចឧតុនិយាម ពីជនិយាមជាដើម ។

## ពោលដោយបញ្ចារម្មណ៍

បញ្ចារម្មណ៍ គឺ អារម្មណ៍ ៥ ពួកនោះ វណ្ណរូប ជាឧបាទាយរូបកើតចាកសមុដ្ឋាន ៤ មានកម្មជាដើម ។ សទ្ទរូប ជាឧបាទាយរូប កើតចាកសមុដ្ឋាន ២ គឺមានចិត្ត និងឧតុជាសមុដ្ឋាន គន្ធរូប ជាឧបាទាយរូប កើតចាកសមុដ្ឋាន ៤ ។ រសរូប ជាឧបាទាយរូប កើតចាកសមុដ្ឋាន ៤ ផោដ្ឋព្វរូបបានដល់មហាភូតរូប ៣ (វៀរអាបោធាតុ) កើតចាកសមុដ្ឋាន ៤ ។

ក្នុងកាមភូមិនេះ ការបានបញ្ចារម្មណ៍ដែលល្អ ជាផលរបស់កុសល ការបានបញ្ចារម្មណ៍ដែលមិនល្អ ជាផលរបស់អកុសល ដូចការបានវិមានរបស់ពួកទេវតាជាដើម និងការត្រូវដុតដោយភ្លើងក្នុងនរក របស់ពួកសត្វនរកដូច្នោះ ការចែកផលរបស់កម្មដោយបដិសន្ធិ មានត្រឹមតែ ២ យ៉ាង គឺដោយសុគតិ និងទុគ្គតិ តែកាលចែកផលរបស់កម្ម ដែលប្រព្រឹត្តទៅក្នុងវិថីហើយ រមែងបាន ៣ យ៉ាងគឺ ÷

១. អតិឥដ្ឋារម្មណ៍ អារម្មណ៍ដែលល្អក្រៃលែង

២. ឥដ្ឋមជ្ឈត្តារម្មណ៍ អារម្មណ៍ដែលល្អថ្នាក់កណ្តាល

---

១. និយាម (និយម) ៥ គឺ ១.ពីជនិយាម ២.ឧតុនិយាម ៣.កម្មនិយាម ៤.ធម្មនិយាម ៥.ចិត្តនិយាម ។

៣. អនិដ្ឋារម្មណ៍ អារម្មណ៍ដែលមិនល្អ ។

កាលអតិឥដ្ឋារម្មណ៍ កើតដល់បុគ្គលណា កុសលវិបាកទាំងឡាយ មានបញ្ចវិញ្ញាណ, សម្បដិច្ឆន្នៈ, សន្តីរណៈ និងតទាលម្ពណៈ រមែងកើតដល់បុគ្គលនោះ ដោយចំពោះសន្តីរណៈ និងតទាលម្ពណៈ រមែងកើតព្រមជាមួយសោមនស្សវេទនា តែបើជាឥដ្ឋមជ្ឈត្តារម្មណ៍ និងអនិដ្ឋារម្មណ៍កើតឡើងហើយ ចិត្តមានចក្ខុវិញ្ញាណជាដើម រមែងកើតព្រមជាមួយឧបេក្ខាវេទនា ។

## ពោលដោយអារម្មណ៍ដែលជាបរិកប្បៈ

ពោលដោយបរិកប្បៈ ( ត្រិះរិះ ) នៃឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ២ យ៉ាងគឺ ÷

១. បរិកប្បឥដ្ឋារម្មណ៍

២. បរិកប្បអនិដ្ឋារម្មណ៍

អារម្មណ៍ផ្សេងៗ មានរូបារម្មណ៍ជាដើមដែលមិនល្អ មិនគួរប្រាថ្នាដូចសាកសព ដែលមានក្លិនស្អុយជាដើម ជាអារម្មណ៍ដែលមិនគួរប្រាថ្នាដោយសភាវៈ ( សភាវអនិដ្ឋារម្មណ៍ ) តែអារម្មណ៍នេះ ជាអារម្មណ៍ដែលជាទីពេញចិត្តនៃសត្វត្មាត ក្អែកជាដើម អារម្មណ៍នេះ ហៅថា **បរិកប្ប-ឥដ្ឋារម្មណ៍** ។

អារម្មណ៍ផ្សេងៗ មានរូបារម្មណ៍ជាដើម ដែលល្អ ដែលគួរប្រាថ្នាដោយសភាវៈ ( សភាវឥដ្ឋារម្មណ៍ ) ដូចមនុស្សខ្លះ បានអាហារដែលជន

ទូទៅពេញចិត្ត គួរប្រាថ្នា តែខ្លួនឯងត្រឡប់មិនពេញចិត្ត មិនត្រូវជាមួយអធ្យាស្រ័យរបស់ខ្លួន អារម្មណ៍នេះ ហៅថា **បរិកប្បអនិដ្ឋារម្មណ៍** ។ គប្បីជ្រាបបរិកប្បៈទាំង ២ នោះ ដូចតទៅនេះ គឺ ÷

១. ពិចារណាដោយវិបាកចិត្ត

២. ពិចារណាដោយមជ្ឈត្តបុគ្គល

៣. ពិចារណាដោយទ្វារ

៤. ពិចារណាដោយអារម្មណ៍

៥. ពិចារណាដោយកាល ។

ពិចារណាដោយវិបាកចិត្ត តើយ៉ាងណា ?

កុសលវិបាកចិត្ត កើតឡើងទទួលអារម្មណ៍ ក្នុងវិថីចិត្តណា អារម្មណ៍ក្នុងវិថីចិត្តនោះ ហៅថា ឥដ្ឋារម្មណ៍ បើអកុសលវិបាកកើតឡើងទទួលអារម្មណ៍ ក្នុងវិថីចិត្តណា អារម្មណ៍ក្នុងវិថីចិត្តនោះ ហៅថា អនិដ្ឋារម្មណ៍ ។ ចំណែកជវនចិត្ត ក្នុងវិថីនោះ នឹងជាកុសល ឬអកុសល រមែងប្រព្រឹត្តទៅដោយអំណាចយោនិសោមនសិការៈ ឬអយោនិសោមនសិការៈ ព្រោះគ្រាខ្លះទទួលឥដ្ឋារម្មណ៍ ជវនៈក្នុងវិថីនោះជាអកុសលក៏បាន ឬជាកុសលក៏បាន, ឬទទួលអនិដ្ឋារម្មណ៍ តែក្នុងជវនៈជាកុសលក៏បាន ជាអកុសលក៏បាន ។

ពិចារណាដោយមជ្ឈត្តបុគ្គលតើយ៉ាងណា ?

ពិចារណាដល់បុគ្គលអ្នកនៅជាន់កណ្ដាល មិនមែនពិចារណាដល់

បុគ្គលជាន់ខ្ពស់ ដូចព្រះបាទមន្ធាតុរាជជាដើម ឬបុគ្គលជាន់ទាប ឬសត្តិរច្ឆាន ព្រោះបុគ្គលជាន់ខ្ពស់ និងបុគ្គលជាន់ទាប មិនជាមាត្រដ្ឋានក្នុងទីនេះ។

ពិចារណាដោយទ្វារ តើយ៉ាងណា ?

ពិចារណាចំពោះតែទ្វារនីមួយៗ ដូចចក្ខុទ្វារ (ផ្លូវភ្នែក) ឃើញវត្ថុដែលល្អស្អាតពេញចិត្តក្នុងទ្វារភ្នែកនេះ ក៏ជាឥដ្ឋារម្មណ៍ របស់ទ្វារភ្នែក តែបើវត្ថុនោះមានក្លិនស្អុយ ជាវត្ថុមិនគួរប្រាថ្នា ប៉ះខ្ទប់ច្រមុះ កើតការមិនពេញចិត្ត អារម្មណ៍នោះក៏ជាអនិដ្ឋារម្មណ៍ របស់ទ្វារច្រមុះ។ មួយ៉ាងទៀតម្ទេសមានពណ៌ស្អាត ជាឥដ្ឋារម្មណ៍របស់ទ្វារភ្នែក បើយកម្ទេសនោះមកទទួលទាន ពេញចិត្ត ចូលចិត្តហឹរ ជាឥដ្ឋារម្មណ៍ មិនចូលចិត្តហឹរក៏ជាអនិដ្ឋារម្មណ៍ របស់ទ្វារអណ្តាត, ម្ទេសដែលមានពណ៌ស្អាតនោះឯង កាលយកមកបុកលាយទឹកបន្តក់ចូលភ្នែក ការឈឺផ្សាភ្នែកក៏ជាអនិដ្ឋារម្មណ៍របស់ទ្វារកាយ, ចំណែកមនោទ្វារ បើតាមបញ្ចទ្វារជាឥដ្ឋារម្មណ៍ តាមមនោទ្វារក៏ជាឥដ្ឋារម្មណ៍ បើជាអនិដ្ឋារម្មណ៍ ក៏ជាអនិដ្ឋារម្មណ៍ដូចគ្នា។

ពិចារណាដោយអារម្មណ៍ តើយ៉ាងណា ?

ការពិចារណាដោយអារម្មណ៍ ផ្សេងគ្នាដោយទ្វារ ព្រោះទ្វារជាសភាវធម៌ដែលកើតរលត់ក្នុងខន្ធសន្តានរបស់ខ្លួន ចំណែកអារម្មណ៍ដែលជាបច្ច័យឱ្យចិត្តកើតនោះមកពីសភាវៈដែលជាខន្ធខាងក្នុងខ្លួនឯងក៏បាន មកពីសភាវៈដែលជាខាងក្រៅក៏បាន ការពិចារណាដោយអារម្មណ៍ ទើបតាំង

ចិត្តពោលដល់របស់ដែលមកកាន់គន្លងទ្វាររបស់បុគ្គល ព្រោះថាក្នុងបុគ្គល ឬក្នុងវត្ថុ ១ រមែងជាអារម្មណ៍បានច្រើនអារម្មណ៍ ដូចបុគ្គលម្នាក់មានរូបស្អាត សម្លេងពិរោះ រូបស្អាត សម្លេងពិរោះជាឥដ្ឋារម្មណ៍ តែកាលពោលដល់ធម្មារម្មណ៍ (អារម្មណ៍ផ្លូវចិត្ត) ហើយ បើបុគ្គលអ្នកមានរូបស្អាតសម្លេងពិរោះនោះ មានចិត្តថោកទាប រឹងរូស ប្រកបអកុសលកម្ម អារម្មណ៍ដែលមកប៉ះខ្ទប់ចិត្តនោះ ក៏ជាអនិដ្ឋារម្មណ៍ ឬថាវត្ថុរបស់របរដែលស្អាត តែក្លិនមិនល្អ, ឬវត្ថុស្អាត តែរសមិនល្អ មិនគួរប្រាថ្នាជាដើម ក៏ន័យនេះឯង ។

ពិចារណាដោយកាល តើយ៉ាងណា ?

ពិចារណាដោយកាល (វេលា) នោះ គឺវត្ថុតែមួយ ជួនកាលជាឥដ្ឋារម្មណ៍ ជួនកាលជាអនិដ្ឋារម្មណ៍ ដូចព្រះពុទ្ធជាម្ចាស់របស់យើងទាំងឡាយ ពេលនៅជាព្រះពោធិសត្វ បំពេញទុក្ករកិរិយា មិនសោយព្រះក្រយាហារ រហូតដល់ព្រះវរកាយស្គមស្គាំង ក្នុងកាលនោះអ្នកដែលបានឃើញក៏កើតអនិដ្ឋារម្មណ៍ ឬព្រះអង្គុលិមាល៍ កាលនៅជាចោរអ្នកដែលបានឃើញក៏កើតអនិដ្ឋារម្មណ៍ ។ កាលព្រះពោធិសត្វបានត្រាស់ដឹងព្រះអនុត្តរសម្មាសម្ពោធិញ្ញាណហើយ ក្នុងកាលនោះ ព្រះអង្គបានប្រកាសសច្ចធម៌ ធ្វើឱ្យលោកសន្និវាសទាំងឡាយពេញចិត្តពេញថ្លើម ក្នុងកាលនោះក៏ជាឥដ្ឋារម្មណ៍ ជាទស្សនានុត្តរិយៈ, ព្រះអង្គុលិមាល៍ កាលសម្រេចជាព្រះអរហន្តហើយ បានធ្វើប្រយោជន៍ដល់មហាជនដ៏ច្រើន មានការតាំងសច្ចៈ

ធ្វើឱ្យការប្រសូតិបុត្រងាយ ជាហេតុឱ្យកើតសាធុការច្រើន កាលនោះក៏ជាឥដ្ឋារម្មណ៏ ។

សូម្បីក្នុងវត្ថុទាំងឡាយ មានដី ទឹក ភ្លើង ខ្យល់ ក៏ដូចគ្នា ខណៈណាជាប្រយោជន៏ជាទីពេញចិត្ត ខណៈនោះក៏ជាឥដ្ឋារម្មណ៏ ខណៈណាវត្ថុទាំងនោះឱ្យទោស មិនជាទីពេញចិត្ត ខណៈនោះក៏ជាអនិដ្ឋារម្មណ៏ ។

ចប់បញ្ចទ្វារវិថីដោយសង្ខេប ។

## អធិប្បាយមនោទ្វារវិថី

បណ្ដាកាមវិថីទាំង ២ គឺ បញ្ចទ្វារវិថី និងមនោទ្វារវិថីនោះ បញ្ចទ្វារវិថីតាមដែលពោលហើយ មានអារម្មណ៍ត្រឹមតែ ៥ យ៉ាងប៉ុណ្ណោះ គឺ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ និងផោដ្ឋព្វារម្មណ៍ បានដល់រូបបរមត្ថ ៧ គឺ វណ្ណៈ សទ្ទៈ គន្ធៈ រសៈ បឋវី តេជោ និងវាយោធាតុ។ រូបទាំងនេះ កំពុងនៅមាន គឺជាបច្ចុប្បន្នកាល ទើបជាអារម្មណ៍នៃបញ្ចទ្វារវិថីបាន។

ចំណែកមនោទ្វារវិថី ដែលជាកាមជវនៈ ដែលនឹងពោលតទៅនេះ ដឹងអារម្មណ៍បាន ៦ យ៉ាង គឺ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ ដែលបានដល់បសាទរូប ៥ សុខុមរូប ១៦ ចិត្ត ៨៩ ដួង ចេតសិក ៥២ និព្វាន និងបញ្ញត្តិ។ មនោទ្វារវិថីអាចដឹងអារម្មណ៍បានទាំងអស់ ទាំងបច្ចុប្បន្នអារម្មណ៍ ទាំងអតីតៈ អនាគត និងកាលវិមុត្តអារម្មណ៍។

ក្នុងអភិធម្មត្ថសង្គហៈ សំដែងមនោទ្វារវិថីទុកដោយសង្ខេបត្រឹមតែ ២ ន័យ ហៅថាវិភូតារម្មណ៍ (អារម្មណ៍ដែលជាក់ច្បាស់) និងអវិភូតារម្មណ៍ (អារម្មណ៍ដែលមិនជាក់ច្បាស់) ដូចព្រះបាលីដែលពោលទុកថា **មនោទ្វារេ បន យទិ វិភូតារម្មណំ អាបាថមាគច្ឆតិ** ជាដើម ប្រែជាសេចក្ដីថា ចំណែកក្នុងមនោទ្វារ ថាបើវិភូតារម្មណ៍មកកាន់គន្លងខាងមុខនោះ ក្នុងវេលាអស់ភវង្គចិត្ត មនោទ្វារាវជ្ជនៈ និងជវនៈ តទាលម្ពណវិបាក

ទាំងឡាយ រមែងប្រព្រឹត្តទៅ បន្ទាប់មកក៏ជាភវង្គបាតៈ គឺប្រព្រឹត្តទៅក្នុងក្រសែនៃភវង្គ។ តែក្នុងអវិភូតារម្មណ៍ ក្នុងវេលាអស់ទៅនៃជវនៈ រមែងជាភវង្គបាតៈ មិនមានតទាលម្ពណៈកើតឡើង។

ព្រះដីកាចារ្យពោលថា អារម្មណ៍ដែលប្រព្រឹត្តទៅក្នុងមនោទ្វារ រមែងមានទាំងអតីតៈ ទាំងអនាគតជាដើម ដូច្នោះ បណ្ឌិតទើបមិនអាចដើម្បីកំណត់អារម្មណ៍របស់ចិត្ត ដែលប្រព្រឹត្តទៅក្នុងមនោទ្វារទាំងនោះ ដោយអំណាចនៃអារម្មណ៍ មានអតិមហន្តារម្មណ៍ជាដើមបាន ព្រោះហេតុដូច្នោះ ដើម្បីកំណត់អារម្មណ៍នោះ ដោយអំណាចនៃវិភូតារម្មណ៍ និងអវិភូតារម្មណ៍ប៉ុណ្ណោះ ទើបពោលថា "បើវិភូតារម្មណ៍មកកាន់គន្លងខាងមុខនោះ ក្នុងវេលាអស់ភវង្គចិត្ត មនោទ្វារាវជ្ជនៈ និងជវនៈ តទាលម្ពណ-វិបាកទាំងឡាយ រមែងប្រព្រឹត្តទៅ" ដូច្នេះជាដើម។

មនោទ្វារវិថីនេះ មានវិថីចិត្ត ៣ មានចិត្តុប្បាទ ១០ កាលសម្តែងដោយពិស្តារ មានចិត្តកើតបាន ៤១ ដួង ដូចសង្គហគាថាដែលបានពោលទុកថា.-

**សង្គហគាថា**

*៤. វិថីចិត្តានិ តីណេវ ចិត្តុប្បាទា ទសេរិតា*

*វិត្ថារេន បនេត្ថេក ចត្តាឡីស វិភាវយេ ។*

ក៏ក្នុងមនោទ្វារនេះ បណ្ឌិតពោលវិថីចិត្តទុក ៣ វិថីប៉ុណ្ណោះ ពោលចិត្តុប្បាទ គឺ សេចក្តីកើតឡើងនៃចិត្តក្នុងវិថី ១០ ខណៈ ដោយពិស្តារ

លោកប្រកាសចិត្តទុក ៤១ ដួង។

**អធិប្បាយសង្គហគាថា :** មនោទ្វារដែលជាកាមជវនៈនេះ ពោលដោយអារម្មណ៍មាន ២ យ៉ាង គឺវិភូតារម្មណ៍ និងអវិភូតារម្មណ៍។ កាលបើពោលដោយវិថី មាន ៣ វិថី គឺ ÷

| | |
|---|---|
| ១. មនោទ្វារាវជ្ជនៈ | ១ វិថី |
| ២. ជវនៈទាំង ៧ | ១ វិថី |
| ៣. តទាលម្ពណៈ ២ | ១ វិថី។ |

បើពោលដោយចិត្តុប្បាទ មាន ១០ ខណៈចិត្ត គឺ ÷

| | |
|---|---|
| ភវង្គចលនៈ | ចិត្តផុតវិថី |
| ភវង្គុបច្ឆេទៈ | ចិត្តផុតវិថី |
| ១. មនោទ្វារាវជ្ជនៈ | ១ ខណៈ |
| ២. ជវនៈ ដួងទី ១ | ១ ខណៈ |
| ៣. ជវនៈ ដួងទី ២ | ១ ខណៈ |
| ៤. ជវនៈ ដួងទី ៣ | ១ ខណៈ |
| ៥. ជវនៈ ដួងទី ៤ | ១ ខណៈ |
| ៦. ជវនៈ ដួងទី ៥ | ១ ខណៈ |
| ៧. ជវនៈ ដួងទី ៦ | ១ ខណៈ |
| ៨. ជវនៈ ដួងទី ៧ | ១ ខណៈ |
| ៩. តទាលម្ពណៈ ដួងទី ១ | ១ ខណៈ |

១០. តទាលម្ពណៈ ដួងទី ២ ១ ខណៈ។

កាលបើពោលដោយពិស្តារ ចិត្តដែលកើតក្នុងមនោទ្វារនេះមាន ៤១ ដួង ដោយវៀរទ្វិបញ្ចវិញ្ញាណ ១០ ដួង និងមនោធាតុ ៣ ដួង ចិត្តដែលសល់ ៤១ ដួង គឺ ÷

១. អហេតុកចិត្ត (ដែលសល់) ៥ ដួង

២. អកុសលចិត្ត ១២ ដួង

៣. កាមសោភណចិត្ត ២៤ ដួង។

ក្នុងបរមត្ថទីបនីដីកា[១] ពោលថា ÷

មនោទ្វារវិថី ប្រាកដ ២ ផ្លូវ គឺ **ផ្លូវសុទ្ធមនោទ្វារវិថី** និង **អនុពន្ធកមនោទ្វារវិថី** ដែលនឹងពោលដូចតទៅខាងមុខនេះ។

## ពោលដោយសុទ្ធមនោទ្វារវិថី

សុទ្ធមនោទ្វារវិថី ជាវិថីដែលមានអារម្មណ៍មកប្រាកដតាមផ្លូវចិត្តសុទ្ធៗ ដោយអាស្រ័យហេតុយ៉ាងណានីមួយ តាមដែលព្រះដីកាចារ្យពោលទុកថា **ទិដ្ឋតោ ទិដ្ឋសម្ពន្ធតោ សុតតោ សុតសម្ពន្ធតោ សទ្ធាយ រុចិយា អាការបរិវិតក្កេន ទិដ្ឋិនិជ្ឈានខន្តិយា នានាកម្មពលេន នានាឥទ្ធិពលេន ធាតុក្ខោភវសេន ទេវតោបសំហារវសេន អនុពោធវសេន បដិវេធវសេនាតិឯវមាទីហិ ការណេហិ អារម្មណធម្មា សុទ្ធេ មនោទ្វារេ អាបាថំ អាគច្ឆន្តិ** ប្រែថា ធម្មារម្មណ៍ រមែងមកកាន់គន្លងក្នុងមនោទ្វារសុទ្ធៗ ដោយហេតុទាំងឡាយ ១៤ គឺ ÷

---

១. បើប្រឆាំងគ្នានឹងពាក្យរបស់ព្រះអនុរុទ្ធាចារ្យ ក៏កាត់ចេញ.....

១. ទិដ្ឋតោ ដោយអារម្មណ៍ដែលធ្លាប់ប្រាកដហើយតាមបញ្ចទ្វារ និងមនោទ្វារ ។

២. ទិដ្ឋសម្ពន្ធតោ ដោយទាក់ទងនឹងការឃើញ គឺ ហេតុកើតឡើង ទាក់ទងនឹងអារម្មណ៍ដែលធ្លាប់ប្រាកដ ។

៣.សុតតោ ដោយអារម្មណ៍ដែលធ្លាប់ស្តាប់ ធ្លាប់រៀនមកហើយ ។

៤.សុតសម្ពន្ធតោ ដោយទាក់ទងនឹងអារម្មណ៍ដែលធ្លាប់ស្តាប់ ធ្លាប់រៀន ។

៥. សទ្ធាយ ដោយសេចក្តីជឿតពីអ្នកដទៃ ។

៦. រុចិយា ដោយសេចក្តីពេញចិត្តរបស់ខ្លួន ។

៧. អាការបរិវិតក្កេន ដោយគិតដល់រឿងផ្សេងៗ ។

៨. ទិដ្ឋិនិជ្ឈានខន្តិយា ដោយការប្រកាន់មាំដោយទិដ្ឋិ ។

៩. នានាកម្មពលេន ដោយកម្លាំងនៃកម្មផ្សេងៗ ។

១០. នានាឥទ្ធិពលេន ដោយកម្លាំងនៃឫទ្ធិផ្សេងៗ ។

១១. ធាតុក្ខោភវសេន ដោយធាតុកម្រើក មានទឹកប្រមាត់ និងស្លេសជាដើម ។

១២. ទេវតោបសំហារវសេន ដោយអំណាចទេវតាបណ្តាលចិត្ត ។

១៣. អនុពោធវសេន ដោយការត្រាស់ដឹង ។

**១៤. បដិវេធវសេន** ដោយការចាក់ធ្លុះ។

**សុទ្ធមនោទ្វារវិថី** រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៤ គឺ កាមអារម្មណ៍ ១ មហគ្គតអារម្មណ៍ ១ លោកុត្តរអារម្មណ៍ ១ និងបញ្ញត្តិអារម្មណ៍ ១។

អារម្មណ៍ដែលមកប្រាកដតាមសុទ្ធមនោទ្វារវិថី ៤ គឺ ÷

១. កាមារម្មណ៍ បានដល់កាមចិត្ត ៥៤ ចេតសិក ៥២ រូប ២៨។

២. មហគ្គតអារម្មណ៍ បានដល់មហគ្គតចិត្ត ២៧ ចេតសិក ៣៥។

៣. លោកុត្តរអារម្មណ៍ បានដល់លោកុត្តរចិត្ត ៨ ចេតសិក ៣៦ និងនិព្វាន។

៤. បញ្ញត្តិអារម្មណ៍ បានដល់ បញ្ញត្តិផ្សេងៗ។

បណ្ដាអារម្មណ៍របស់សុទ្ធមនោទ្វារវិថី ៤ ទាំងនេះ កាមអារម្មណ៍ មហគ្គតអារម្មណ៍ និងលោកុត្តរសង្ខតអារម្មណ៍ ជាអារម្មណ៍បានទាំង ៣ កាល គឺបានទាំងអតីតៈ អនាគត និងបច្ចុប្បន្ន តែព្រះនិព្វាន និងបញ្ញត្តិអារម្មណ៍ ជាកាលវិមុត្ត (ផុតចាកកាល)។

ក្នុងបរមត្ថទីបនីដីកានេះ សំដែងអារម្មណ៍របស់សុទ្ធមនោទ្វារវិថីទុក ៤ យ៉ាងគឺ ÷

១. អតិវិភូតារម្មណ៍ ៤ វិថី

២. វិភូតារម្មណ៍ ២ វិថី

៣. អវិភូតារម្មណ៍ ២ វិថី

៤. អតិអវិភូតារម្មណ៍ ១ វិថី ។

បណ្តាអារម្មណ៍ ៤ ទាំងនោះ អតិវិភូតារម្មណ៍ ៤ វិថី គឺ ÷

**វិថីទី ១ អតិវិភូតារម្មណ៍** មានតទាលម្ពណៈ មាន ១ វិថី គឺ ÷

ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. តទា. តទា. ភ.

ចិត្តក្នុងវិថីនេះ ភវង្គដើមវិថី និងចុងវិថី បានដល់កាមភវង្គ ១០ ។ ក្នុងវិថីនេះ រាប់ចាប់ពីមនោទ្វារាវជ្ជនៈ រហូតដល់ទុតិយតទាលម្ពណៈ ទទួលយកបច្ចុប្បន្ននិប្ផន្នរូប និងមានអតីតៈ អនាគតនិប្ផន្នរូប ជាអារម្មណ៍ និងមានកាមចិត្ត ចេតសិក អនិប្ផន្នរូបដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣ ជាអារម្មណ៍ ។

វិថីទី ២ អតិវិភូតារម្មណ៍ ជវនវារៈ ២ វិថី មិនមានអាគន្តុកភវង្គ គឺ ÷

វិថីទី ១ មានសភាពវិថីដូច្នេះ ÷

ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. ភ.

ជវនវារៈវិថីនេះ កើតដល់រូបបុគ្គល និងអរូបបុគ្គល ភវង្គដើមវិថី និងចុងវិថី បានដល់មហគ្គតវិបាកចិត្ត ៩ ដួង ។

វិថីទី ២ មានសភាពវិថីដូច្នេះ ÷

ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. ភ.

វិថីទី ២ នេះ កើតដល់បុគ្គលអ្នកបដិសន្ធិដោយកាមឧបេក្ខា ភវង្គដើមវិថី និងចុងវិថី ជាកាមឧបេក្ខា ៦ ដួង ។

វិថីទី ៣ អតិវិភូតារម្មណ៍ ជវនវារៈដែលមានអាគន្តុកភវង្គ ១ វិថី គឺ ÷

ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. អា. ភ.

វិថីនេះ កើតដល់បុគ្គលអ្នកបដិសន្ធិដោយកាមសោមនស្ស កាលប្រសព្វអតិវិភូតារម្មណ៍ ត្រឡប់កើតទោសជវនៈ ក្នុងវិថីរបៀបនេះ កើតតទាលម្ពណៈមិនបាន ទើបកើតឧបេក្ខាអាគន្តុកភវង្គមកធ្វើកិច្ចមុន ហើយទើបប្រព្រឹត្តទៅក្នុងសោមនស្សភវង្គដើម ។ ភវង្គដើម និងភវង្គចុង ជាកាមសោមនស្សភវង្គ ៤ ដួង ។

វិថីចិត្តតាមមនោទ្វារ ក្នុងអភិធម្មត្ថសង្គហៈ មិនសំដែងអតីតភវង្គ តែក្នុងបរមត្ថទីបនីដីកាសំដែងថា អតីតភវង្គមិនជាក់លាក់ គឺ បើមនោទ្វារវិថីនោះមានអារម្មណ៍ ៦ ដែលជានិប្ផន្នរូប ខណៈនោះ មានអតីតភវង្គបានជាក់លាក់ ដូចគ្នានឹងអារម្មណ៍តាមបញ្ចទ្វារវិថី បើចិត្តក្នុងមនោទ្វារ មានអារម្មណ៍ ៦ យ៉ាងដទៃគឺ មានអារម្មណ៍ ៦ ដែលជាអតីតៈ អនាគតនិប្ផន្នរូប ឬមានធម្មារម្មណ៍ ដែលជាចិត្ត ចេតសិក, អនិប្ផន្នរូបដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣ និព្វាន និងបញ្ញត្តិ ខណៈនោះ មិនមានអតីតភវង្គ កើតឡើងក្នុងមនោទ្វារវិថី ។

ចប់អតិវិភូតារម្មណ៍ ៤វិថី ។

# វិភូតារម្មណ៍មាន ២ យ៉ាង

១. វិភូតារម្មណ៍ ជវនវារៈមិនមានអាគន្តុកភវង្គ ។

២. វិភូតារម្មណ៍ ជវនវារៈដែលមានអាគន្តុកភវង្គ ។

**សភាពវិថីទី ១** នៃវិភូតារម្មណ៍ មិនមានអាគន្តុកភវង្គ គឺ ÷

ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. ភ.

ភវង្គដើមវិថី និងភវង្គចុងវិថី បានដល់ភវង្គចិត្ត ១៩ ដួង ។

**សភាពវិថីទី ២** នៃវិភូតារម្មណ៍ ដែលមានអាគន្តុកភវង្គ គឺ ÷

ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. អា. ភ.

វិថីចិត្តនេះ កើតដល់បុគ្គលអ្នកបដិសន្ធិដោយកាមសោមនស្ស កាលប្រកបនឹងអតិឥដ្ឋារម្មណ៍ គឺអារម្មណ៍ដែលល្អក្រៃលែងហើយ ត្រឡប់ជាមិនពេញចិត្ត កើតទោសជវនៈ កាលបើដូច្នោះ ពេលទោសជវនៈដួងទី ៧ រលត់ហើយ សោមនស្សតទាលម្ពណៈ ឬសោមនស្សភវង្គកើតឡើងមិនបានឡើយ ព្រោះជាតិរបស់សោមនស្សវេទនា និងទោមនស្សវេទនា ជាវិសភាគៈនឹងគ្នា ទើបកើតកាមឧបេក្ខាអាគន្តុកភវង្គធ្វើកិច្ចមុនហើយ ទើបជាសោមនស្សមូលភវង្គ ។

វិថីនេះ ភវង្គដើមនិងចុងវិថី ជាកាមសោមនស្សភវង្គ ៤ ដួង ។

ចប់វិភូតារម្មណ៍ ២ វិថី ។

# អវិភូតារម្មណ៍មាន ២ វិថី

**សភាពវិថីទី ១** គឺ ៖ ភ. ន. ទ. ម. ម. ម. ភ.

**សភាពវិថីទី ២** គឺ ៖ ភ. ន. ទ. ម. ម. ភ.

អវិភូតារម្មណ៍ ជាអារម្មណ៍ដែលមិនប្រាកដជាក់ច្បាស់ផ្លូវចិត្ត គឺវិថីចិត្តនេះ មានអារម្មណ៍កើតឡើងត្រឹមតែមនោទ្វារាវជ្ជនៈ ៣ ខណៈចិត្តខ្លះ ២ ខណៈចិត្តខ្លះ ហើយក៏ប្រព្រឹត្តទៅក្នុងក្រសែនៃភវង្គ ដូចក្នុងវេលាដែលគិតបញ្ហា ឬចាំអ្វីមិនបាន ឬខណៈដែលយល់សុបិន ស្រពិចស្រពិល មិនជាក់ ច្បាស់ ឬក៏ប្រហាក់ប្រហែលនឹងមនុស្សដែលដេកមិនលក់។ ភវង្គដើមវិថី និងចុងវិថី បានដល់ភវង្គចិត្ត ១៩ ដួង។

ចប់អវិភូតារម្មណ៍ ២ វិថី។

## អតិអវិភូតារម្មណ៍មាន ១ វិថី

សភាពអតិអវិភូតារម្មណ៍ គឺ : ភ. ន. ន. ភ.

អតិអវិភូតារម្មណ៍នេះ ជាមោឃវារៈ ។ ភវង្គដើម និងចុង បានដល់ភវង្គ ១៩ ដួង ។

ចប់អតិអវិភូតារម្មណ៍ ១ វិថី ។

## អារម្មណ៍ដែលប្រព្រឹត្តនៅក្នុងកាល ៣

១. បច្ចុប្បន្នបញ្ញារម្មណ៍ ដែលប្រាកដតាមសុទ្ធមនោទ្វារវិថីនេះ ជាអារម្មណ៍ដែលធ្លាប់ប៉ះខ្ទប់ជាមួយនឹងបញ្ចទ្វារមកពីមុនៗ ហើយ កាលត្រឡប់មកជាបច្ចុប្បន្នអារម្មណ៍តាមមនោទ្វារទៀត ដូច្នោះ លោកទើបហៅបញ្ញារម្មណ៍នេះថា បច្ចុប្បន្នបញ្ញារម្មណ៍របស់សុទ្ធមនោទ្វារវិថី ។

២. បញ្ញារម្មណ៍ ដែលប៉ះខ្ទប់នឹងបញ្ចទ្វារ ដែលជាអតីតៈ ក្នុងគ្រាមុននោះ កាលមកប្រាកដតាមមនោទ្វារវិថីដោយសេចក្តីជាអតីតារម្មណ៍ទៀត ដូច្នោះ ទើបលោកហៅអារម្មណ៍នេះថា អតីតបញ្ញារម្មណ៍របស់សុទ្ធមនោទ្វារវិថី ។

៣. បញ្ញារម្មណ៍ ដែលនឹងមកប៉ះខ្ទប់នឹងបញ្ចទ្វារវិថី ក្នុងគ្រាមុនៗ កាលមកប្រាកដតាមមនោទ្វារវិថី ដោយជាអនាគតអារម្មណ៍ទៀត ដូច្នោះ លោកហៅអារម្មណ៍នេះថា អនាគតបញ្ញារម្មណ៍របស់សុទ្ធមនោទ្វារវិថី ។

ចប់សុទ្ធមនោទ្វារវិថី ។

## អនុពន្ធកមនោទ្វារវិថី

អនុពន្ធកៈ ឬតទនុវត្តិកៈ មនោទ្វារវិថី ជាវិថីចិត្តដែលទទួលអារម្មណ៍តាមផ្លូវចិត្តបន្តអំពីបញ្ចទ្វារ មនោទ្វារនេះអាចដឹងអារម្មណ៍បានគ្រប់យ៉ាង កាលបញ្ចារម្មណ៍ គឺ រូប សម្លេង ក្លិន រស និងផោដ្ឋព្វៈប៉ះខ្ទប់ទ្វារ មានចក្ខុទ្វារជាដើម នៅជាបរមត្ថបច្ចុប្បន្នអារម្មណ៍នៅឡើយ មិនអាចដឹងន័យសេចក្តីរបស់អារម្មណ៍នោះៗបាន ពេលអារម្មណ៍តាមបញ្ចទ្វារកើតបន្តទៅក្នុងមនោទ្វារហើយ ទើបអាចដឹងន័យសេចក្តីរបស់អារម្មណ៍នោះៗ បានជាក់ច្បាស់ ដូច្នោះ អារម្មណ៍តាមបញ្ចទ្វារ ទើបកើតជាគូនឹងអារម្មណ៍តាមមនោទ្វារ អារម្មណ៍ដែលកើតបន្តអំពីបញ្ចទ្វារនេះ ហៅថា **អនុពន្ធកមនោទ្វារវិថី** ឬហៅថាតទនុវត្តិកមនោទ្វារវិថី មាន ៤ យ៉ាងគឺ÷

១. អតីតគហណវិថី ជាវិថីដែលមានអារម្មណ៍អតីតៈ

២. សមូហគហណវិថី ជាវិថីដែលរួបរួមអារម្មណ៍

៣. អត្ថគហណវិថី ជាវិថីដែលដឹងរឿងរ៉ាវន័យសេចក្តី

៤. នាមគហណវិថី ជាវិថីដែលដឹងឈ្មោះ។

**អធិប្បាយៈ** កាលបញ្ចទ្វារវិថី ដែលមានបរមត្ថបច្ចុប្បន្នអារម្មណ៍រលត់ហើយ **អនុពន្ធកមនោទ្វារវិថី** ក៏កើតឡើងទទួលអារម្មណ៍នោះភ្លាមតែមានអារម្មណ៍ជាអតីតៈ ដូច្នោះ ទើបហៅថា អតីតគហណវិថី (មនោទ្វារដែលមានអារម្មណ៍ជាអតីតៈ)។ បន្ទាប់មក **សមូហគហណវិថី** កើតឡើងធ្វើនាទីរួបរួមអារម្មណ៍ តាមបញ្ចទ្វារ និងអតីតគហណវិថី ដើម្បីឱ្យ

ដឹងរឿងរ៉ាវន័យសេចក្តី ដូចការមើលតួអក្សរ និងតួស្រៈផ្សេងៗ ទាំងនេះថាគួរ អានយ៉ាងណា មានន័យសេចក្តីយ៉ាងណាជាដើម សមូហគហណវិថីនៅមានបរមត្ថជាអារម្មណ៍ តែជាអតីតារម្មណ៍ ដូចគ្នានឹងអតីតគហណវិថីដែរ ។

បន្ទាប់អំពីនោះ **អត្ថគហណវិថី** ក៏កើតបន្ត ដឹងន័យសេចក្តីរឿងរ៉ាវនៃអារម្មណ៍ វិថីនេះមានអារម្មណ៍ជាបញ្ញត្តិ បើអារម្មណ៍តាមបញ្ចទ្វារមានពណ៌ជាអារម្មណ៍ វិថីទី ៣ ក៏មានរូបរាង ឬសណ្ឋាននៃរូបារម្មណ៍នោះថាជាមនុស្ស ឬជាសត្វជាដើម ។ តមកទៀត មនោទ្វារវិថីទី ៤ គឺ **នាមគហណវិថី** ក៏កើតឡើងមានបញ្ញត្តិជាអារម្មណ៍ គឺ ដឹងឈ្មោះរបស់បញ្ចារម្មណ៍នោះៗ ។

បណ្តាមនោទ្វារវិថីទាំង ៤ នោះ អតីតគហណវិថី និង សមូហគហណវិថី នៅមានបរមត្ថជាអារម្មណ៍ តែអត្ថគហណវិថី និង នាមគហណវិថីទាំង ២ នេះ មានបញ្ញត្តិជាអារម្មណ៍ ។

បណ្តាអារម្មណ៍ ៥ មានរូបារម្មណ៍ជាដើម អារម្មណ៍ណានីមួយដែលកើតឡើងផុតវិថីហើយ មនោទ្វារ ៤ វិថី មានអតីតគហណវិថីជាដើម ក៏កើតឡើងជាវិថីគូដោយលំដាប់ដូចតារាងខាងមុខនេះ.-

| ទ្វារ គូ គី ÷ | |
|---|---|
| បញ្ចទ្វារ អតិមហន្តារម្មណ៍ | មនោទ្វារ វិភូតារម្មណ៍ |
| **ចក្ខុទ្វារវិថី** | **១. អតីតគហណវិថី** |
| ១. អតីតភវង្គ ១ ខណៈ | ១. ភវង្គចលនៈ ១ ខណៈ |
| ២. ភវង្គចលនៈ ១ ខណៈ | ២. ភវង្គុបច្ឆេទៈ ១ ខណៈ |
| ៣. ភវង្គុបច្ឆេទៈ ១ ខណៈ | ៣. មនោទ្វារាវជ្ជនៈ ១ ខណៈ |
| ៤. អាវជ្ជនៈ ១ ខណៈ | ៤. ជវនៈ ១ ខណៈ |
| ៥. ចក្ខុវិញ្ញាណ ១ ខណៈ | ៥. ជវនៈ ១ ខណៈ |
| ៦. សម្បដិច្ឆន្នៈ ១ ខណៈ | ៦. ជវនៈ ១ ខណៈ |
| ៧. សន្តីរណៈ ១ ខណៈ | ៧. ជវនៈ ១ ខណៈ |
| ៨. វោដ្ឋវនៈ ១ ខណៈ | ៨. ជវនៈ ១ ខណៈ |
| ៩. ជវនៈ ១ ខណៈ | ៩. ជវនៈ ១ ខណៈ |
| ១០. ជវនៈ ១ ខណៈ | ១០. ជវនៈ ១ ខណៈ |
| ១១. ជវនៈ ១ ខណៈ | ១១. តទាលម្ពណៈ ១ ខណៈ |
| ១២. ជវនៈ ១ ខណៈ | ១២. តទាលម្ពណៈ ១ ខណៈ |
| ១៣. ជវនៈ ១ ខណៈ | |
| ១៤. ជវនៈ ១ ខណៈ | |
| ១៥. ជវនៈ ១ ខណៈ | |
| ១៦. តទាលម្ពណៈ ១ ខណៈ | |
| ១៧. តទាលម្ពណៈ ១ ខណៈ | |

កាលចក្ខុទ្វារវិថី មានបរមត្ថបច្ចុប្បន្នអារម្មណ៍អស់វិថីហើយ អតីតគហណមនោទ្វារវិថី ក៏កើតឡើងដោយមានរូបបរមត្ថនោះឯងជាអារម្មណ៍តែជាអតីតារម្មណ៍ វិថី ២ នេះកើតឆ្លាស់គ្នាច្រើនខណៈដែលកំពុងមើលរបស់ណាមួយ។ ក្នុងឃានទ្វារវិថី, ជីវ្ហាទ្វារវិថី និងកាយទ្វារវិថី ក៏មានសេចក្តី ប្រព្រឹត្តទៅដូចគ្នា នឹងចក្ខុទ្វារវិថីដែរ។

២.សមូហគហណវិថី កើតឡើងលំដាប់នៃអតីតគហណវិថី ធ្វើកិច្ចរួបរួមអារម្មណ៍គ្រប់ចំណែកនៃអារម្មណ៍របស់ចក្ខុទ្វារវិថីនិងអតីតគហណ-វិថីចូលគ្នា ដើម្បីឱ្យយល់ដល់រូបរាងសណ្ឋាននៃបរមត្ថធម៌ ដោយតភ្ជាប់គ្នាទៅកាន់ភាពជាអត្ថប្បញ្ញត្តិ តាមវោហាររបស់ជនក្នុងលោក វិថីនេះក៏កើតឡើងជាច្រើនខណៈ តែនៅជាបរមត្ថអារម្មណ៍នៅឡើយ។

**សភាពវិថីចិត្តរបស់សមូហគហណវិថី**

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. តទា. តទា.

៣. អត្ថគហណវិថី ជាវិថីតាមមនោទ្វារ ធ្វើនាទីទទួលរូបរាងសណ្ឋាន នៃអារម្មណ៍ដែលសមូហគហណវិថីបានរួបរួមទុក អាចដឹងន័យសេចក្តីក្នុងអត្ថប្បញ្ញត្តិ អារម្មណ៍ក្នុងវិថីនេះទើបជាបញ្ញត្តិអារម្មណ៍ កាលជាបញ្ញត្តិអារម្មណ៍ហើយ តទាលម្ពណចិត្តរមែងមិនកើត វិថីចិត្តនេះក៏កើតឡើងច្រើនដង។

**សភាពវិថីចិត្តរបស់អត្ថគហណវិថីចិត្ត** ( មិនមានតទាលម្ពណៈ)

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ.

៤. នាមគហណវិថី ជាវិថីតាមមនោទ្វារ អាចដឹងឈ្មោះរបស់អារម្មណ៍នោះៗ ដែលគេបញ្ញត្តិទុកតាមវោហាររបស់ជនក្នុងលោក ដែលប្រើសម្រាប់ ហៅ ច្រៀង ពោល ឆ្លើយគ្នា ទើបវិថីនេះមានអារម្មណ៍ជាបញ្ញត្តិ កើតឡើងមានប្រភេទដូចអត្ថគហណវិថីគ្រប់ប្រការ។

**សភាពវិថីចិត្តរបស់នាមគហណវិថីចិត្ត** (មិនមានតទាលម្ពណៈ)

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ.

ចំណែកអនុពន្ធកមនោទ្វារវិថី ដែលកើតតអំពីសោតទ្វារវិថី ដែលមានសម្លេង (សទ្ទ:) ជាអារម្មណ៍ មានសេចក្តីផ្សេងគ្នាខ្លះ គឺ កាលវិថីចិត្តកើតតាមសោតទ្វារអស់វិថីហើយ អតីតគហណវិថីក៏មានសម្លេង ដែលរលត់ហើយជាអារម្មណ៍បន្ត រួចហើយនាមគហណវិថីរមែងកើតមុនអត្ថ-គហណវិថី ព្រោះសម្លេងដែលបន្លឺចេញមកនោះ មនោទ្វារវិថីរមែងដឹងឈ្មោះរបស់អារម្មណ៍នោះៗ មុនពេលដឹងន័យសេចក្តី អត្ថគហណវិថី តែបើសម្លេងនោះមានព្យាង្គតែមួយ ឬពាក្យតែមួយម៉ាត់ សមូហគហណវិថីក៏មិនកើត ព្រោះមិនត្រូវការរួបរួមនឹងអ្វីទៀត ប្រសិនបើសម្លេងដែលបានឮនោះ ជាសម្លេងដែលខ្លួនមិនដឹងន័យសេចក្តី ដូចសម្លេងភាសាប្រទេសផ្សេង ឬសម្លេងរបស់សត្វតិរច្ឆានដែលខ្លួនមិនដឹង អត្ថគហណវិថីក៏មិនកើត គង់មានមនោទ្វារវិថីត្រឹមតែ ៣ ប៉ុណ្ណោះ គឺ អតីតគហណវិថី សមូហគហណវិថី និងនាមគហណវិថី។ គប្បីជ្រាបដូច្នេះ គឺ ÷

១. អតីតគហណវិថី មានបរមត្ថសទ្ទារម្មណ៍ ដែលជាអតីតារម្មណ៍

កើតផ្លាស់គ្នា សោតទ្វារវិថីដែលជាវិថីដើមច្រើនខណៈ ។ សភាពអតីត-គហណវិថីមានដូចតទៅនេះ ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. តទា. តទា.

២. សមូហគហណវិថី ទទួលអារម្មណ៍តអំពីអតីតគហណវិថី វិថីនេះ ក៏នៅជាបរមត្ថសទ្ទារម្មណ៍ ដែលជាអតីតនោះឯង ធ្វើនាទីរួបរួមសំឡេងដែលច្រើនជាង ១ ព្យាង្គ ដែលសោតទ្វារវិថី និងអតីតគហណវិថីទទួលមកនោះ រមែងកើតឡើងច្រើនខណៈដូចគ្នា បើសំឡេងមាន ១ ព្យាង្គវិថីនេះក៏មិនកើត ។ មានសភាពវិថីដូច្នេះ :

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. តទា. តទា.

៣. នាមគហណវិថីកើតតអំពីសមូហគហណវិថី បើសមូហគហ-ណវិថីមិនកើត នាមគហណវិថីនេះក៏កើតតអំពីអតីតគហណវិថី នាមគហ-ណវិថីនេះមានបញ្ញត្តិ គឺ សទ្ទប្បញ្ញត្តិជាអារម្មណ៍ សភាពវិថីទើបមិនមានតទាលម្ពណចិត្ត កើតដូច្នេះ ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ.

៤. អត្ថគហណវិថី ទទួលអារម្មណ៍តអំពីនាមគហណវិថី ធ្វើកិច្ចដឹងន័យសេចក្តីរបស់សទ្ទារម្មណ៍ ឬដឹងឈ្មោះផ្សេងៗ តែបើជាសំឡេងដែលខ្លួនមិនដឹងន័យសេចក្តី អត្ថគហណវិថីនេះក៏មិនកើត ។ មានសភាពដូច្នេះ ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ

# វិញ្ញត្តិគហណវិថី

វិញ្ញត្តិគហណវិថីមាន ២ គឺ ÷

១. កាយវិញ្ញត្តិគហណវិថី   វិថីដែលដឹងសកម្មភាពតាមផ្លូវកាយ

២. វចីវិញ្ញត្តិគហណវិថី   វិថីដែលដឹងសកម្មភាពតាមផ្លូវវាចា

កាយវិញ្ញត្តិគហណវិថីនេះ   មានដើមវិថីមកអំពីការឃើញពណ៌ដែលប្រាកដតាមចក្ខុទ្វារវិថីមុនហើយ   អនុពន្ធកមនោទ្វារវិថី   នឹងរមែងកើតដូចតទៅនេះ គឺ ÷

១.   ចក្ខុទ្វារវិថី   ឃើញការបក់ដៃ   គឺឃើញរូបារម្មណ៍ដែលជាបរមត្ថបច្ចុប្បន្ន នឹងមានវិថីចិត្តកើតដូច្នេះ គឺ ÷

តី. ន. ទ. ប. ច. ស. ណ. វ. ជ .ជ .ជ .ជ .ជ .ជ .ជ . តទា. តទា.

២. អតីតគហណវិថី ទទួលរូបារម្មណ៍តអំពីចក្ខុទ្វារវិថី ជាបរមត្ថ-អារម្មណ៍ តែជាអតីតអារម្មណ៍ វិថីនេះនឹងកើតរលត់ឆ្លាស់គ្នានឹងចក្ខុទ្វារវិថីច្រើនខណៈ វិថីចិត្តមនោទ្វារ ដូច្នេះ គឺ ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. តទា. តទា.

៣. សមូហគហណវិថី កើតតអំពីអតីតគហណវិថី រូបរួមរូបារម្មណ៍ដែលចក្ខុទ្វារវិថីនិងអតីតគហណវិថីទទួលមក   សមូហគហណវិថីនេះនឹងកើតឡើងច្រើនដុំ តែនៅជាបរមត្ថអារម្មណ៍ដែលជាអតីតៈ។ មានសភាពវិថីកើតដូច្នេះ គឺ ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. តទា. តទា.

៤. អត្ថគហណវិថី កើតតអំពីសមូហគហណវិថី ជាការដឹងន័យសេចក្តីថា ជាការបក់ដៃ ជាការទទួលបញ្ញត្តិជាអារម្មណ៍ មានវិថីចិត្តដូច្នេះ គឺ ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. ( មិនមានតទា. ) ។

៥. កាយវិញ្ញត្តិគហណវិថី កើតតអំពីអត្ថគហណវិថី មានការបក់ដៃដែលមានបញ្ញត្តិជាអារម្មណ៍ ដោយដឹងន័យសេចក្តីថា បក់ដៃហៅយើង មានវិថីចិត្តកើតដូច្នេះ គឺ ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ.

៦. អធិប្បាយគហណវិថី ជាវិថីកើតតអំពីកាយវិញ្ញត្តិគហណវិថី មានបញ្ញត្តិក្នុងការបក់ដៃជាអារម្មណ៍ ដោយដឹងសេចក្តីបំណងថា ហៅយើងឱ្យចូលទៅរក មានវិថីចិត្តដូច្នេះ គឺ ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ.

## វចីវិញ្ញត្តិគហណវិថី

វចីវិញ្ញត្តិគហណវិថី អាស្រ័យសោតទ្វារវិថី មានសម្លេងជាអារម្មណ៍ កាលសោតទ្វារវិថីផុតវិថីហើយ ក៏មានអនុពន្ធកមនោទ្វារវិថីកើតតទៅ មានវិថីកើតឡើងដោយលំដាប់យ៉ាងនេះ.-

១. សោតទ្វារវិថី កើតឡើងមានសម្លេងជាអារម្មណ៍ គឺបានឮសម្លេងជាបរមត្ថអារម្មណ៍ និងជាអារម្មណ៍បច្ចុប្បន្នផង នៅមិនទាន់ដឹងអារម្មណ៍បញ្ញត្តិថាយ៉ាងណា មានវិថីចិត្តដូច្នេះ គឺ ÷

តី. ន. ទ. ប. សោ. ស. ណ. វ. ជ .ជ .ជ .ជ .ជ .ជ .ជ . តទា. តទា.

២. អតីតគហណវិថី កើតបន្ទាប់សម្លេងជាបរមត្ថអារម្មណ៍ ជាអារម្មណ៍អតីតៈ ទាំង ២ វិថីនេះ កើតឆ្លាស់គ្នាច្រើនដង មានវិថីចិត្តកើតដូច្នេះ គឺ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. តទា. តទា.

៣. សមូហគហណវិថី កើតតអំពីអតីតគហណវិថី នៅជាបរមត្ថ-សទ្ទារម្មណ៍ តែជាអតីតារម្មណ៍ ធ្វើនាទីរួបរួមសម្លេងដែលជាពាក្យពោលដែលមានច្រើនជាង ១ ព្យាង្គ ដែលសោតទ្វារវិថី និងអតីតគហណវិថីទទួលមក វិថីនេះក៏កើតឡើងច្រើនដុំ មានវិថីចិត្តកើតឡើងដូច្នេះ គឺ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. តទា. តទា.

៤. នាមគហណវិថី កើតតអំពីសមូហគហណវិថី ដើម្បីទទួលនាមបញ្ញត្តិជាអារម្មណ៍ គឺឈ្មោះរបស់យើង មានវិថីចិត្តកើតដូច្នេះ គឺ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. (មិនមាន តទា.) ។

៥. អត្ថគហណវិថី កើតតអំពីនាមគហណវិថី ទទួលនាមបញ្ញត្តិជាអារម្មណ៍ដឹងសេចក្ដីថាជាឈ្មោះរបស់យើង មានវិថីចិត្តកើតដូច្នេះ គឺ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. (មិនមាន តទា.) ។

៦. វចីវិញ្ញត្តិគហណវិថី កើតតអំពីអត្ថគហណវិថី ដឹងន័យសេចក្ដីរបស់សទ្ទារម្មណ៍ គឺសម្លេងដែលបានឮនោះថា "គេហៅយើង" ជាបញ្ញត្តិ-អារម្មណ៍ មានវិថីចិត្តកើតដូច្នេះ គឺ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. (មិនមាន តទា.)។

៧. អធិប្បាយគហាណវិថី កើតបន្តអំពីវចីវិញ្ញត្តិគហាណវិថី រមែង ទទួលបញ្ញត្តិអារម្មណ៍នោះ គឺដឹងសេចក្តីថា អ្នកនោះ "ហៅយើងឱ្យចូល ទៅរក" ជាបញ្ញត្តិអាម្មរណ៍ មានវិថីចិត្តដូច្នេះគឺ ÷

ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. (មិនមាន តទា.)។

ចប់បរមត្ថទីបនីដីកា (តាមច្បាប់ភូមា)។

## សុបិនវិថី

សុបិនវិថី គឺវិថីនៃការយល់សប្តិ កើតឡើងក្នុងខណៈដែលដេកលក់ មិនស៊ប់ វិថីនេះជាកាមជវនៈ ប្រព្រឹត្តទៅតាមមនោទ្វារប៉ុណ្ណោះ មិនកើត ឡើងតាមបញ្ចទ្វារឡើយ ព្រោះព្រះបាលីក្នុងតេរសកណ្ឌដីកាថា "**សុបិនំ ហិ បស្សន្តោ មនោទ្វារិកេនេវ បស្សតិ ន បញ្ចទ្វារិកេន**" ប្រែថា កាល បុគ្គល យល់សប្តិឃើញ រមែងឃើញដោយចិត្តប្រព្រឹត្តទៅតាមមនោទ្វារ ប៉ុណ្ណោះ មិនឃើញដោយចិត្តតាមបញ្ចទ្វារ។ ក្នុងព្រះបាលី សម្តែងហេតុ នៃការយល់សប្តិទុក ៤ យ៉ាង គឺ ÷

១. ធាតុខោភតោ ព្រោះសេចក្តីកម្រើកនៃធាតុ។

២.អនុភូតបុព្វតោ ព្រោះធ្លាប់ជួបប្រទះមកហើយ។

៣. ទេវតោបសំហារតោ ព្រោះទេវតាបណ្តាលចិត្ត។

៤.បុព្វនិមិត្តតោ ព្រោះបុព្វនិមិត្ត។

ក្នុងការយល់សប្តិទាំង ៤ យ៉ាងនោះ ការយល់សប្តិព្រោះធាតុក្នុង

រាងកាយកម្រើកមិនប្រក្រតី មានការឈឺថ្កាត់ជាដើម ធ្វើឱ្យឃើញសភាពផ្សេងៗ មានការដើរ-រត់ទៅជិតពប់ដួល ឬធ្លាក់អំពីទីខ្ពស់ជាដើម យល់សប្តិនេះមិនពិតប្រាកដទេ។ យល់សប្តិកើតអំពីការនឹកគិត ខ្វល់ខ្វាយដល់អារម្មណ៍ដែលធ្លាប់ប្រសព្វមក ក៏យល់សប្តិទៅដោយចិត្តដែលរាយមាយផ្សេងៗ យល់សប្តិនេះក៏មិនពិតប្រាកដ។ ការយល់សប្តិកើតអំពីទេវតាចូលទៅបណ្តាលចិត្ត គឺទេវតាមកប្រាប់ហេតុល្អ ឬហេតុអាក្រក់ ឱ្យដឹងទុកជាមុន ក៏បណ្តាលចិត្តឱ្យយល់សប្តិ យល់សប្តិបែបនេះ ពិតខ្លះមិនពិតខ្លះ បើទេវតាសម្មាទិដ្ឋិមានសេចក្តីស្រឡាញ់ ប្រាថ្នានឹងសង្គ្រោះ ក៏ប្រាប់វត្ថុដែលពិតប្រាកដ បើទេវតាមិច្ឆាទិដ្ឋិ មានសេចក្តីស្អប់ ប្រាថ្នានឹងឱ្យបានទទួលទុក្ខភ័យ ក៏កុហកក្នុងរបស់ដែលមិនពិត។ ការយល់សប្តិព្រោះបុព្វនិមិត្តនោះរមែងប្រព្រឹត្តទៅដោយអំណាចកុសលកម្ម ឬអកុសលកម្មដែលធ្វើទុកពីអតីតៈ ពេលដែលនឹងឱ្យជ្រាបដល់សេចក្តីសុខ ឬទុក្ខ ក៏នឹងប្រាកដជានិមិត្តឱ្យជ្រាប ហៅថាបុព្វនិមិត្ត យល់សប្តិនេះរមែងពិតប្រាកដ ដូចសេចក្តីយល់សប្តិ (សុបិននិមិត្ត) របស់ព្រះនាងសិរិមហាមាយា ទ្រង់សុបិននិមិត្តឃើញដំរីស ដែលជានិមិត្តច្រើនក្នុងការបានព្រះឱរសជាដើម។

សេចក្តីយល់សប្តិ តើប្រព្រឹត្តទៅយ៉ាងណា ?

បុគ្គលអ្នកយល់សប្តិនោះ ដេកលក់ហើយយល់សប្តិ ឬភ្ញាក់ហើយក៏យល់សប្តិ ឬថាមិនលក់មិនភ្ញាក់ក៏នៅយល់សប្តិ តើយ៉ាងណា ? ក្នុងសេចក្តីនេះ មានអធិប្បាយថា បើបុគ្គលដេកលក់ក៏នៅយល់សប្តិ ក៏ខុសចាក

ព្រះអភិធម្ម ព្រោះសត្វរមែងដេកលក់ដោយភវង្គចិត្ត ហើយភវង្គចិត្តនោះ មិនមានរូបនិមិត្តជាអារម្មណ៍ ទាំងមិនមានចិត្តសម្បយុត្តដោយរាគៈ ជាដើម បើសិនជាបុគ្គលភ្ញាក់មានយល់សប្តិក៏ខុសចាកព្រះវិន័យ ព្រោះធ្វើ ខុសក្នុងខណៈភ្ញាក់រមែងត្រូវអាបត្តិ ក្នុងព្រះវិន័យ ខទី ២ នៃសង្ឃា-ទិសេស ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចេតនា (ក្នុង សេចក្តីយល់សប្តិ) នោះមានមែន ប៉ុន្តែចេតនានោះជា អព្វោហារិកា[១] ។ កាលបើដូច្នេះ សេចក្តីយល់សប្តិមិនមានឬ ?

សេចក្តីយល់សប្តិមាន តែប្រព្រឹត្តទៅឆាប់រហ័ស ក្នុងខណៈដែល ប្រាកដ ដូចការដេកលក់របស់ស្វា សេចក្តីនេះសមដូចពាក្យដែលព្រះ នាគសេនត្ថេរពោលថា មហាបពិត្រ អ្នកដេកលក់ដូចស្វានោះឯង រមែង យល់សប្តិ ។ ពិតមែនហើយ សេចក្តីយល់សប្តិនោះ ប្រព្រឹត្តទៅរហ័ស ដូច ការដេកលក់របស់ស្វា ព្រោះមានការជ្រៀតជ្រែកដោយចិត្ត មាន អកុសលចិត្តជាដើមរឿយៗ ទើបចិត្តរបស់គេឡើងចាកភវង្គរឿយៗ អ្នក ដេកលក់ដូច្នេះ ទើបយល់សប្តិដោយហេតុនោះ សេចក្តីយល់សប្តិ ទើបជា កុសលខ្លះ ជាអកុសលខ្លះ ជាអព្យាកតខ្លះ ក្នុងខណៈណាដែលយល់សប្តិថា បានសំពះព្រះចេតិយជាដើម ខណៈនោះក៏ជាកុសល ហៅថា **កុសលសុបិ-នវិធី** វិធីចិត្តនេះ នឹងអស់ត្រង់ជវនវារៈ ឬតទាលម្ពណវារៈ ។ បើយល់សប្តិ ធ្វើបាណាតិបាតជាដើម ជា **អកុសលសុបិនវិធី** សុបិនវិធីនេះ នឹងធ្លាក់ចុះ ត្រង់ជវនៈ ឬតទាលម្ពណៈនោះឯង ។ ចំណែកយល់សប្តិដែលជាអព្យាកត-

---

១. បើចង់ជ្រាបច្បាស់ សូមបើកមើលក្នុងគម្ពីរវិន័យបិដកភាសាខ្មែរភាគ ២ ចាប់ពីទំព័រទី ៧ ទៅ ។

វិថីនោះ អារម្មណ៍ដែលយល់សប្តិ នឹងធ្លាក់ចុះត្រង់វោដ្ឋវនវារៈ ឬជាមោឃវារៈ។

ក៏ការយល់សប្តិនោះ ព្រោះមានវត្ថុទុព្វល ទើបមិនអាចហួតយកបដិសន្ធិរបស់ចេតនាមកបាន កាលបើដូច្នេះ សេចក្តីយល់សប្តិដែលកុសលនិងអកុសលដទៃឧបត្ថម្ភទុក រមែងឱ្យវិបាកបានក៏ពិត ដូច្នេះចេតនាក្នុងយល់សប្តិក៏ជាអព្វោហារិកា (ពោលអាងមិនបាន) ព្រោះកើតក្នុងទីដែលមិនមែនជាវិស័យ។

អដ្ឋកថាពោលថា បុគ្គលអ្នកយល់សប្តិមាន ២ ពួកគឺ ពួកបុថុជ្ជននិងពួកសេក្ខបុគ្គលប៉ុណ្ណោះ ព្រោះលះវិបល្លាសមិនទាន់បាន ចំណែកព្រះអសេក្ខបុគ្គល មិនមានវិបល្លាសទើបមិនយល់សប្តិ អាចារ្យពួកខ្លះពោលថា សត្វនរកក៏មិនយល់សប្តិដែរ ព្រោះមានតែសោយទុក្ខវេទនា។

## ពោលដោយវិថីចិត្តរបស់ឧារក

ការកើតបដិសន្ធិរបស់សត្វក្នុងគភ៌គ្រាដំបូងនោះ ចិត្តុប្បាទ និងកលលរូបរមែងកើតព្រមគ្នា ក្រោយពីនោះ បឋមភវង្គក៏កើតឡើង គ្រាបឋមភវង្គរលត់ហើយ ភវង្គចិត្តនឹងកើតរលត់តគ្នាទៅដោយអនន្តរប្បច្ច័យរហូតដល់ភវង្គចលនៈ ភវង្គុប្បច្ឆេទៈ តពីនោះ មនោទ្វារាវជ្ជនៈ ដែលជាចិត្តពិចារណាអារម្មណ៍តាមមនោទ្វារ ក៏កើតឡើងពិចារណាអារម្មណ៍ ដែលប្រព្រឹត្តទៅដោយអំណាចតណ្ហា សេចក្តីពេញចិត្តក្នុងភព ស្ទុះទៅក្នុងអារម្មណ៍នៃជវនៈរហូតផុតវិថី នេះជាវិថីដំបូងរបស់សត្វដែលមានតណ្ហា

នាំទៅកើតក្នុងភពថ្មី ( **បោនោព្ភវិកា តណ្ហា**) ប្រព្រឹត្តទៅតាមមនោទ្វារតែម្យ៉ាង ។

ចំណែកបញ្ចទ្វារវិថី គឺ ចក្ខុទ្វារវិថី, សោតទ្វារវិថី, ឃានទ្វារវិថី, ជីវ្ហាទ្វារវិថី និងកាយទ្វារវិថីនោះ កាយទ្វារវិថីកើតឡើងមុន ព្រោះកាយ-បសាទកើត ឡើងព្រមជាមួយនឹងបដិសន្ធិ តែសោតទ្វារវិថី និងជីវ្ហាទ្វារ-វិថីដែលនឹង កើតឡើងបាននោះ យ៉ាងតិចត្រូវកន្លងសប្តាហ៍ទី ១១ របស់បដិសន្ធិកាលទៅហើយ ចំណែកចក្ខុទ្វារវិថី និងឃានទ្វារវិថី នឹងកើតឡើងក្នុងពេលដែល សត្វនោះចេញចាកគភ៌ហើយ និងមានសេចក្តីទាក់ចិត្តក្នុងអារម្មណ៍នោះហើយ ។

ចប់មនោទ្វារកាមវិថី ។

## ប្រៀបធៀបបញ្ចទ្វារនិងមនោទ្វារ

បញ្ចទ្វារវិថីនិងមនោទ្វារវិថីតាមដែលពោលហើយនោះ សុទ្ធតែជាវិថីដែលមានកាមធម៌ជាអារម្មណ៍ មានសេចក្ដីប្លែកពីគ្នា គួរនឹងសរុបបាន ១៥ ខ តាមន័យរបស់កេចិអាចារ្យ ដូចតទៅនេះគឺ ÷

| បញ្ចទ្វារវិថី | មនោទ្វារវិថី |
|---|---|
| ១. មានអតីតភវង្គ | តអំពីបញ្ចទ្វារមិនមានអតីតភវង្គ |
| ២. មានវិសយប្បវត្តិ ៤ គឺ.- | មានវិសយប្បវត្តិ ២ គឺ.- |
| អតិមហន្តារម្មណ៍ | វិភូតារម្មណ៍ និងអវិភូតារម្មណ៍ |
| មហន្តារម្មណ៍ | - |
| បរិត្តារម្មណ៍ | - |
| អតិបរិត្តារម្មណ៍ | - |
| ៣. កើតក្នុងទ្វារ ៥ | កើតចំពោះមនោទ្វារ |
| ៤. អាស្រ័យវត្ថុ ៥ | អាស្រ័យហទយវត្ថុក្នុងបញ្ចវោការភូមិ |
| ៥. ដឹងអារម្មណ៍ ៥ យ៉ាង | ដឹងអារម្មណ៍ ៦ យ៉ាង |
| ៦. មានរូបធម៌ជាអារម្មណ៍ | មានរូប, នាម និងបញ្ញត្តិជាអារម្មណ៍ |
| ៧. មានបរមត្ថជាអារម្មណ៍ | មានបរមត្ថ និងបញ្ញត្តិជាអារម្មណ៍ |
| ៨. មានអារម្មណ៍ជាបច្ចុប្បន្ន | មានទាំងបច្ចុប្បន្ន អតីតៈ អនាគត និងកាលវិមុត្តជាអារម្មណ៍ |
| ៩. កើតក្នុងកាមបុគ្គល និង | កើតក្នុងកាមបុគ្គល រូបបុគ្គល និង |

| | |
|---|---|
| រូបបុគ្គល តាមសមគួរ | អរូបបុគ្គល |
| ១០. កើតក្នុងកាមភូមិ និង រូបភូមិ តាមសមគួរ | កើតបានទាំងកាមភូមិ ទាំងរូបភូមិ និង អរូបភូមិ តាមសមគួរ |
| ១១.មានវិថីចិត្តមិនលើស ៧ | មានវិថីចិត្ត មិនច្រើនជាង ៣វិថី គឺ.- |
| គឺ អាវជ្ជនវិថី ១ | មនោទ្វារាវជ្ជនវិថី ១ |
| បញ្ចវិញ្ញាណវិថី ១ | ជវនវិថី ១ |
| សម្បដិច្ឆន្នវិថី ១ | តទាលម្ពណវិថី ១ |
| សន្តីរណវិថី ១ | - |
| វោដ្ឋវនវិថី ១ | - |
| ជវនវិថី ១ | - |
| តទាលម្ពណវិថី ១ | - |
| ១២.មានចិត្តកើតក្នុងវិថី ១៤ ខណៈ | មានចិត្តកើតក្នុងវិថី ១០ ខណៈ |
| ១៣. មានកាមចិត្តកើត ៥៤ ដួង | មានកាមចិត្តកើត ៤១ ដួង ( វៀរទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ៣) |
| ១៤. កើតតអំពីភវង្គចិត្ត ១៥ | កើតតអំពីភវង្គចិត្ត ១៩ ដួង |
| គឺ ឧបេក្ខាសន្តីរណៈ ២ | ដោយបន្ថែមអរូបាវចរចិត្ត ៤ ដួង |
| មហាវិបាក ៨ | - |
| រូបាវចរវិបាកចិត្ត ៥ | - |

| ១៥. មានវេទនា ៥ គឺ.- | | មានវេទនា ៣ គឺ.- | |
|---|---|---|---|
| សុខវេទនា | ១ | សោមនស្សវេទនា | ១ |
| ទុក្ខវេទនា | ១ | ទោមនស្សវេទនា | ១ |
| សោមនស្សវេទនា | ១ | ឧបេក្ខាវេទនា | ១ |
| ទោមនស្សវេទនា | ១ | - | |
| ឧបេក្ខាវេទនា | ១ | - | |

ចប់កាមវិថីនៃបញ្ចទ្វារនិងមនោទ្វារ ។

## អប្បនាវិថី ឬអប្បនាជវនវារៈ[១]

ចិត្តដែលតាំងមាំនៅក្នុងអារម្មណ៍តែមួយ ហៅថាអប្បនាចិត្ត បានដល់មហគ្គតចិត្ត ២៧ និងលោកុត្តរចិត្ត ៨ គឺ÷

១. មហគ្គតកុសលចិត្ត ៩ ដួង

២. មហគ្គតវិបាកចិត្ត ៩ ដួង

៣. មហគ្គតកិរិយាចិត្ត ៩ ដួង

៤. លោកុត្តរចិត្ត ៨ ឬ ៤០ ដួង ។

អប្បនាចិត្តដែលឡើងកាន់វិថីតាមមនោទ្វារ (វៀរមហគ្គតវិបាក ៩) ហៅថា អប្បនាវិថី ឬហៅថា អប្បនាជវនវារៈ ។ ដែលឈ្មោះថា អប្បនាជវនវារៈ ព្រោះវិថីនៃអប្បនានោះធ្លាក់ចុះត្រង់ជវនៈ មិនមានតទាលម្ពណៈកើត ព្រោះមិនមែនជាវិស័យរបស់ខ្លួន។ អប្បនាវិថី ឬ អប្បនាជវនវិថី បានដល់ចិត្តទាំងនេះគឺ÷

១. មហគ្គតកុសលចិត្ត ៩ ដួង

២. មហគ្គតកិរិយាចិត្ត ៩ ដួង

---

*១.* វិថីនៃអប្បនា ឈ្មោះថា អប្បនាវិថី។ មានវិគ្គហៈថា.-

*អារម្មណេ អប្បេតិ បវិសតិ អារម្មណករណវសេនាតិ អប្បនាឈានំ ។* ប្រែថា ឈ្មោះថា អប្បនាឈាន ព្រោះអត្ថថា តាំងមាំក្នុងអារម្មណ៍ គឺចូលទៅក្នុងអារម្មណ៍ដោយអំណាចនៃកិរិយាធ្វើឱ្យជាគ្រឿងត្រេកអររបស់ចិត្ត។ ន័យម្យ៉ាងទៀតថា.-

*សម្បយុត្តធម្មេ អារម្មណំ អប្បេតិ អភិនិរោបេតីតិ អប្បនា ។* ប្រែថា វិតក្កៈណាតែងតាំងមាំ គឺ រមែងគ្រប់អារម្មណ៍ទុកក្នុងសម្បយុត្តធម៌ ព្រោះហេតុនោះ វិតក្កៈនោះ ទើបឈ្មោះថា អប្បនា បានដល់ ឈានដែលមានវិតក្កៈជាប្រធាន។ (អប ធាតុ. ចុះយុបច្ច័យហើយ ក្លាយជា អន: តម្រួត ប សម្រេចរូបជាអប្បនា។ ក្នុងអត្ថយោជនាបឋមភាគ) ។

៣. លោកុត្តរចិត្ត ៨ ឬ ៤០ ដួង ។

អប្បនាវិថីនេះ កើតឡើងចំពោះតែមនោទ្វារប៉ុណ្ណោះ មិនមានការចែកជាវិភូតារម្មណ៍ ឬអវិភូតារម្មណ៍ដូចជាមនោទ្វារកាមវិថីទេ ព្រោះមានអារម្មណ៍ជាក់ច្បាស់តែម្យ៉ាងទើបកើតឡើង បើអារម្មណ៍មិនជាក់ច្បាស់ក៏មិនកើតឡើងឡើយ ។

## អប្បនាវិថីមាន ២ យ៉ាង

១. លោកិយអប្បនាវិថី បានដល់ អប្បនាវិថីដែលជាលោកិយៈ

២. លោកុត្តរអប្បនាវិថី បានដល់ អប្បនាវិថីដែលជាលោកុត្តរៈ ។

## លោកិយអប្បនាវិថី[(១)]

លោកិយអប្បនាវិថី បានដល់វិថីដែលមានមហគ្គតចិត្ត ១៨ គឺ មហគ្គតកុសលចិត្ត ៩ ដួង និងមហគ្គតកិរិយាចិត្ត ៩ ដួង ដែលកើតក្នុងអប្បនាវិថី ។ បណ្ដាមហគ្គតកុសលចិត្តទាំង ៩ ដួងនោះដួងណាមួយ កាលកើតឡើងរមែងអាស្រ័យ មហាកុសលញ្ញាណសម្បយុត្តចិត្តកើតឡើងមុន ៣-៤ ខណៈធ្វើកិច្ចដូច្នេះគឺ ១. បរិកម្ម ២. ឧបចារៈ ៣. អនុលោម ៤. គោត្រភូ បន្ទាប់មក មហគ្គតកុសលចិត្តដួងណាមួយទើបកើតឡើង ។ បណ្ដាមហគ្គតកិរិយាទាំង ៩ ដួងនោះ មួយដួងៗ កាលកើតឡើង ក៏ត្រូវអាស្រ័យមហាកិរិយាញ្ញាណសម្បយុត្តកើតឡើងមុន ៣-៤ ខណៈ មានសភាពដូចគ្នា ហើយមហគ្គតកិរិយាចិត្តដួងណាមួយក៏កើតឡើង ។

---

(១) *មិស្សកអប្បនាវិថីមាន ៧ គឺ ១. អាទិកម្មិកឈានវិថី, ២. ឈានសមាបត្តិវិថី, ៣. បាទកឈានវិថី, ៤. អភិញ្ញាវិថី, ៥. មគ្គវិថី, ៦. ផលសមាបត្តិវិថី, ៧. និរោធសមាបត្តិវិថី ។*

លោកិយអប្បនាវិថីមាន ២ គឺ អាទិកម្មិកឈានវិថី ១ ឈានសមាបត្តិវិថី ១ ។ ក្នុងអប្បនាវិថីទាំង ២ នោះ ព្រះយោគាវចរ ចម្រើនសមថកម្មដ្ឋាន ដែលអាចឱ្យកើតឈានបានមាន ៣០ មានបឋវីកសិណជាដើម[១] ឈានដែលលោកធ្វើឱ្យកើតឡើងក្នុងគ្រាដំបូង មានត្រឹមតែមួយខណៈចិត្តប៉ុណ្ណោះ ហៅថា អាទិកម្មិកឈានវិថី សូម្បីលោកិយអប្បនាដែលសល់មានទុតិយឈានជាដើម រហូតដល់នេវសញ្ញានាសញ្ញាយតនជ្ឈានដែលបានគ្រាដំបូង ក៏ហៅថា អាទិកម្មិកឈានវិថី ។ ចំណែកព្រះយោគីអ្នកជំនាញក្នុងឈានដោយវសី ៥ អាចចូលក្នុងឈានតាមដែលកំណត់ទុក ហៅថា ឈានសមាបត្តិវិថី ។

ក្នុងអប្បនាវិថីទាំង ២ នោះ អាទិកម្មិកឈានវិថីមាន ២ គឺ.-

១. អាទិកម្មិកឈានវិថី របស់មន្ទបុគ្គល (អ្នកមានបញ្ញាតិច)

២. អាទិកម្មិកឈានវិថី របស់តិក្ខបុគ្គល(អ្នកមានបញ្ញាក្លៀវក្លា)

សភាពអាទិកម្មិកឈានវិថីរបស់មន្ទបុគ្គល ដែលជាទន្ធាភិញ្ញា (អ្នកត្រាស់ដឹងយឺត) មានកាមជវនៈកើត ៤ ខណៈ មាន ៦ វិថីដូចតទៅនេះ គឺ ÷

| | | |
|---|---|---|
| ១. ភវង្គចលនៈ | ១ ខណៈ | ចិត្តផុតវិថី |
| ២. ភវង្គុបច្ឆេទៈ | ១ ខណៈ | |
| ៣. មនោទ្វារាវជ្ជនៈ | ១ ខណៈ | ជាវិថីទី ១ |
| ៤. បរិកម្ម | ១ ខណៈ | ជាវិថីទី ២ |

១. កសិណ ១០. អសុភ ១០. អានាបានស្សតិ ១. កាយគតាសតិ ១. អប្បមញ្ញា ៤. អរូបជ្ឈាន ៤ ។

៥. ឧបចារៈ ១ ខណៈ ជាវិថីទី ៣

៦. អនុលោម ១ ខណៈ ជាវិថីទី ៤

៧. គោត្រភូ ១ ខណៈ ជាវិថីទី ៥

៨. ឈាន ១ ខណៈ ជាវិថីទី ៦

- ភវង្គបាតៈ ចិត្តប្រព្រឹត្តទៅក្នុងក្រសែនៃភវង្គ។

សភាពអាទិកម្មិកឈានវិថី របស់តិក្ខបុគ្គលដែលជាខិប្បាភិញ្ញា (អ្នកត្រាស់ដឹងរហ័ស) មានកាមជវនៈកើត ៣ ខណៈ (មិនមានបរិកម្ម) មានវិថីកើតបាន ៥ វិថីដូច្នេះ គឺ÷

១. ភវង្គចលនៈ ១ ខណៈ } ចិត្តផុតវិថី

២. ភវង្គុបច្ឆេទៈ ១ ខណៈ

៣. មនោទ្វារាវជ្ជនៈ ១ ខណៈ ជាវិថីទី ១

៤. ឧបចារៈ ១ ខណៈ ជាវិថីទី ២

៥. អនុលោម ១ ខណៈ ជាវិថីទី ៣

៦. គោត្រភូ ១ ខណៈ ជាវិថីទី ៤

៧. ឈាន ១ ខណៈ ជាវិថីទី ៥

- ភវង្គបាតៈ ចិត្តប្រព្រឹត្តទៅក្នុងក្រសែនៃភវង្គ។

**អធិប្បាយ** សភាពវិថីចិត្តមុននឹងឈានចិត្តកើតឡើងនោះ ព្រះយោគាវចរ រមែងចម្រើនសមថភាវនា រហូតចិត្តមានកម្លាំងក្សៀវក្លា ដែលអាចធ្វើឱ្យភវង្គតាំងនៅមិនបាន ញ៉ាំងទៅដោយអំណាចនៃឈានភាវនាដាច់

ចាកអារម្មណ៍ដើម (ភវង្គុប្បច្ឆេទៈ) បន្ទាប់មក មនោទ្វារាវជ្ជនៈកើតឡើង ធ្វើអាវជ្ជនកិច្ច រួចហើយចិត្ត ៨ ដួង គឺមហាកុសល ៤ មហាកិរិយា ៤ ដែលជាញាណសម្បយុត្តដួងណាមួយ ធ្វើកាមជវនៈ ៤ ខណៈ ឬ ៣ ខណៈ តាមសមគួរដល់បុគ្គល ដូច្នេះគឺ.-

ខណៈទី ១ ឈ្មោះថា បរិកម្ម ព្រោះជាភាវនាធ្វើដោយជុំវិញរបស់អប្បនា គឺតាក់តែងអប្បនា បានដល់ចិត្ត ៨ ដួង ដែលកើតឡើងមុនដូចដែលពោលហើយនោះ។

ខណៈទី ២ ឈ្មោះថា ឧបចារៈ ព្រោះត្រាច់ទៅជិតអប្បនា ឬឈ្មោះថា ឧបចារៈ ព្រោះអត្ថថា ត្រាច់ទៅដល់អប្បនា។

ខណៈទី ៣ ឈ្មោះថា អនុលោម ព្រោះអនុកូល (គាំទ្រ) ដល់បរិកម្មក្នុងកាលខាងដើម និងដល់អប្បនាក្នុងផ្នែកខាងលើ។

ខណៈទី ៤ ឈ្មោះថា គោត្រភូ ព្រោះគ្របសង្កត់បរិត្តគោត្រ (គោត្រកាម) និងព្រោះញុំាងមហគ្គតគោត្រឱ្យកើតឡើង។

ខណៈទី ៥ ឈាន គឺពេលគោត្រភូរលត់ហើយ ឈានចិត្តក៏កើតឡើង សោយរសអារម្មណ៍ត្រឹមតែ ១ ខណៈ ហើយក៏ប្រព្រឹត្តទៅក្នុងគន្លងនៃភវង្គ (ភវង្គបាតៈ)។ ឈានស័ព្ទ មានវិគ្គហៈថា **អាលម្ពណំ ឈាយតីតិ ឈានំ**។ ប្រែថា ធម្មជាតិណា រមែងសម្លឹងអារម្មណ៍ ព្រោះហេតុនោះធម្មជាតិនោះ ឈ្មោះថា ឈាន បានដល់ការសម្លឹងអារម្មណ៍ មានវិតក្កៈជាដើម។ ន័យម្យ៉ាងទៀតថា បច្ចនិកេ ឈាបេតីតិ ឈានំ។ ប្រែថា ដែល

ឈ្មោះថា ឈាន ព្រោះអត្ថថា ដុតធម៌ដែលជាសត្រូវ ។

## ឈានសមាបត្តិវិថី

ឈានសមាបត្តិវិថី បានដល់ វិថីចិត្តរបស់ព្រះយោគីបុគ្គលអ្នកចូលឈានសមាបត្តិ ដើម្បីសោយសេចក្ដីសុខដែលកើតអំពីឈានដែលខ្លួនបានហើយ ឈានសមាបត្តិវិថីនេះ មានប្រភេទដូចគ្នានឹងអាទិកម្មិកឈានវិថីដែរ ផ្សេងគ្នាត្រង់អាទិកម្មិកឈានវិថី កើតឡើងត្រឹមតែ ១ ខណៈចិត្តហើយចិត្តក៏ប្រព្រឹត្តទៅក្នុងក្រសែនៃភវង្គ ចំណែកឈានសមាបត្តិវិថីនេះ ឈានចិត្តអាចកើតឡើងច្រើន ឬតិច អាស្រ័យទៅលើសមត្ថភាពរបស់អ្នកបន្ទុះ និងតាមកម្លាំងដែលបានអធិដ្ឋានទុក មិនអាចកំណត់បាន ព្រោះឈានសមាបត្តិវិថីនេះ អាចកើតបានច្រើន ។

ចប់លោកិយអប្បនាវិថី ។



## លោកុត្តរអប្បនាវិថី

លោកុត្តរអប្បនាវិថី បានដល់វិថីចិត្តដែលជាលោកុត្តរឈាន ជាវិថីចិត្តរបស់ព្រះអរិយបុគ្គលអ្នកបានឈាន ចំណែកវិថីចិត្តរបស់ព្រះអរិយ-បុគ្គលអ្នកមិនបានឈាន ហៅថាលោកុត្តរវិថី ។

លោកុត្តរចិត្ត គឺចិត្តដែលជាលោកុត្តរៈ មាន ៨ បានដល់មគ្គចិត្ត ៤ ផលចិត្ត ៤ ។ ដោយពិស្តារ លោកុត្តរចិត្តមាន ៤០ គឺ មគ្គចិត្ត ២០ ផលចិត្ត ២០ ។ ចិត្តទាំង ៤០ ដូងនេះ ជារបស់ព្រះអរិយៈអ្នកបានឈាន ។ លោកុត្តរចិត្ត មានវចនត្ថៈថា **លោកុត្តរញ្ច តំ ចិត្តញ្ចាតិ លោកុត្តរចិត្តំ** ។ ប្រែថា លោកុត្តរៈនោះ ជាចិត្ត ទើបឈ្មោះថា លោកុត្តរចិត្ត ។

## លោកុត្តរវិថីមាន ២ យ៉ាង

១. មគ្គវិថី បានដល់ វិថីចិត្តដែលចូលដល់មគ្គចិត្ត ។

២. ផលសមាបត្តិវិថី បានដល់វិថីចិត្តរបស់ព្រះអរិយៈ អ្នកចូលផលសមាបត្តិ ។

បណ្តាវិថីចិត្តទាំង ២ នោះ មគ្គវិថីមាន ២ ប្រភេទ គឺមគ្គវិថីរបស់មន្ទបុគ្គល និងមគ្គវិថីរបស់តិក្ខបុគ្គល ។ មគ្គវិថីរបស់មន្ទបុគ្គល មានវិថីកើតបាន ៧ វិថី ។

**សភាពវិថីរបស់មន្ទបុគ្គល** អ្នកត្រាស់ដឹងយឺត កើតដូច្នេះ ÷

| | | |
|---|---|---|
| ១. ភវង្គចលនៈ | ១ ខណៈ | ចិត្តផុតវិថី ២ ខណៈ |
| ២. ភវង្គុប្បច្ឆេទៈ | ១ ខណៈ | |

៣. មនោទ្វារាវជ្ជនៈ ១ ខណៈ ជាវិថីទី ១

៤. បរិកម្ម ១ ខណៈ ជាវិថីទី ២

៥. ឧបចារៈ ១ ខណៈ ជាវិថីទី ៣

៦. អនុលោម ១ ខណៈ ជាវិថីទី ៤

៧. គោត្រភូ ១ ខណៈ ជាវិថីទី ៥

៨. មគ្គ ១ ខណៈ ជាវិថីទី ៦

៩-១០ ផល ២ ខណៈ ជាវិថីទី ៧

- ភវង្គបាតៈ ចិត្តប្រព្រឹត្តទៅក្នុងភវង្គ។

**សភាពវិថីចិត្តរបស់តិក្ខបុគ្គល អ្នកត្រាស់ដឹងរហ័ស កើតដូច្នេះ÷**

១. ភវង្គចលនៈ ១ ខណៈ } ចិត្តផុតវិថី ២ ខណៈ

២. ភវង្គុបច្ឆេទៈ ១ ខណៈ }

៣. មនោទ្វារាវជ្ជនៈ ១ ខណៈ ជាវិថីទី ១

៤. ឧបចារៈ ១ ខណៈ ជាវិថីទី ២

៥. អនុលោម ១ ខណៈ ជាវិថីទី ៣

៦. គោត្រភូ ១ ខណៈ ជាវិថីទី ៤

៧. មគ្គ ១ ខណៈ ជាវិថីទី ៥

៨-១០ ផល ៣ ខណៈ ជាវិថីទី ៦

- ភវង្គបាតៈ ចិត្តប្រព្រឹត្តទៅក្នុងភវង្គ។

**អធិប្បាយមគ្គវិថី** កាលព្រះយោគាវចរចម្រើនវិបស្សនា មាន

កម្លាំងតាំងអំពីឧទយព្យានុបស្សនាញាណ រហូតដល់សង្ខារុបេក្ខាញាណ គឺញាណដែលព្រងើយចំពោះសង្ខារ ។ ញាណដែលឈ្មោះថា សង្ខារុបេក្ខា ព្រោះឃើញនាមរូបមិនទៀងបង្គាប់បញ្ជាមិនបានថា ជាទុក្ខ, ឃើញការសន្សំកម្មឱ្យកើតទៀតថា ជាទុក្ខ, ឃើញការកើតឡើងនៃខន្ធជាទុក្ខ ឃើញការកើតឡើងនៃផលរបស់កម្ម... ឃើញជាតិ... និងឃើញជរាជាដើមថា ជាទុក្ខទើបកើតការនឿយណាយ ជាអ្នកប្រាថ្នាដើម្បីនឹងរួចផុត (ទុក្ខ) ទើបធ្វើមនសិការក្នុងត្រៃលក្ខណ៍នោះជារឿយៗ ក្នុងញាណដែលព្រងើយចំពោះសង្ខារទាំងឡាយ មុនពេលដែលមគ្គវិថីកើតឡើងនោះ ភវង្គក៏ញ័រតាំងនៅមិនបានដោយអំណាចនៃមគ្គភាវនា កាលភវង្គដាច់ចាកភវង្គដើមហើយ តពីនោះ មនោទ្វារាវជ្ជនៈក៏ឡើងកាន់មគ្គវិថី ធ្វើអាវជ្ជនកិច្ចពិចារណាត្រៃលក្ខណ៍ជាអារម្មណ៍ ពេលដែលមនោទ្វារាវជ្ជនៈរលត់ហើយ មហាកុសល ៤ ដួងៗ ណាមួយ ធ្វើកាមជវនៈ ៤ ស្ទុះទៅ ៤ ខណៈខ្លះ ៣ ខណៈខ្លះ តាមសមគួរដល់អ្នកដែលនឹងត្រាស់ដឹងដូច្នេះគឺ ÷

ខណៈទី ១ បរិកម្ម ដែលហៅថា បរិកម្ម ព្រោះជាបរិកម្មរបស់មគ្គ ឬតាក់តែងមគ្គឱ្យកើត ដែលមានត្រៃលក្ខណ៍ជាអារម្មណ៍ ។

ខណៈទី ២ ឧបចារៈ ដែលហៅថា ឧបចារៈ ព្រោះអត្ថថា ត្រាច់ទៅជិត, ត្បិតថា សូម្បីធម៌ដែលមិនជិត ឬមិនប្រព្រឹត្តទៅឆ្ងាយ ក៏ឈ្មោះថា ត្រាច់ទៅជិតដូចគ្នា ។

ខណៈទី ៣ អនុលោម ដែលហៅថា អនុលោម ព្រោះស្រប

តាម គឺជាធម៌តាំទ្រដល់សច្ចៈទាំងខាងដើមនិងខាងចុង ដោយមានត្រៃលក្ខណ៍នោះឯងជាអារម្មណ៍។

ខណៈទី ៤ គោត្រភូ ដែលហៅថា គោត្រភូ ព្រោះជាញាណគ្រប់គ្រងរក្សាគោត្របុថុជ្ជន ឱ្យកើតលោកុត្តរគោត្រ ដូចវចនត្ថៈថា *បុថុជ្ជនគោត្តំ អភិភវតិ លោកុត្តរគោត្តំ ភាវេតីតិ គោត្រភូ* ។ ប្រែថា ញាណណា រមែងគ្រប់គ្រងគោត្របុថុជ្ជន ឱ្យលោកុត្តរគោត្រកើត ព្រោះហេតុនោះ ញាណនោះឈ្មោះថាគោត្រភូ(១) ។ គោត្រភូញាណនេះ មានព្រះនិព្វានជាអារម្មណ៍ រមែងមានសភាពដូចអាវជ្ជនៈនៃមគ្គ ទើបមិនមានការប្រហារកិលេស ព្រោះនៅមិនទាន់បានធ្វើកិច្ចរបស់មគ្គ។

ខណៈទី ៥ មគ្គ កាលគោត្រភូរលត់ហើយ មគ្គចិត្ត ១ ដួងក៏កើតឡើងដោយតោងយកព្រះនិព្វានជាអារម្មណ៍ ធ្វើកិច្ចក្នុងអរិយសច្ចៈ ៤ ក្នុងខណៈជាមួយគ្នា គឺកំណត់ដឹងទុក្ខ លះសមុទយៈ ធ្វើនិរោធឱ្យជាក់ច្បាស់ ញុំាងមគ្គឱ្យកើត ទម្លាយអនុស័យកិលេសដែលដេកត្រាំនៅក្នុងខន្ធសន្តានឱ្យអស់ទៅតាមកម្លាំងរបស់ខ្លួន។ ក្នុងដីកាពោលថា ញាណមានសង្ខតៈជាអារម្មណ៍ក្តី មានបញ្ញត្តិជាអារម្មណ៍ក្តី មិនអាចកាត់កិលេសដាច់បាន។

ខណៈទី ៦ ផល កាលមគ្គចិត្តនោះរលត់ហើយ ផលចិត្ត គឺលោកុត្តរវិបាក មានព្រះនិព្វានជាអារម្មណ៍ កើតឡើងសោយលោកុត្តរផលមិនមានរវាងខ័ណ្ឌ មានសេចក្តីស្ងប់ត្រជាក់ជាសន្តិសុខ សម្រេចជា

---

១. ក្នុងបុគ្គលបញ្ញត្តិពោលថា ឈ្មោះថាគោត្រភូបុគ្គល ព្រោះឈានកន្លងញាណរបស់បុថុជ្ជនជាដើម។

ព្រះសោតាបន្ន។ ក្នុងគាថាធម្មបទភាគ ៦ សរសើរព្រះសោតាបន្នទុកថា.-

បឋព្យា ឯករជ្ជេន សគ្គស្ស គមនេន វា

សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ ។

សោតាបត្តិផល ជាគុណជាតដ៏ប្រសើរ ជាងភាពនៃឯករាជ្យលើផែនដីផង ជាងដំណើរទៅកាន់ឋានសួគ៌ផង ជាងភាពជាធំក្នុងលោកទាំងមូលផង ។

មគ្គវិថី ដែលនឹងបន្ទុះជាព្រះសកទាគាមី ជាព្រះអនាគាមី និងជាព្រះអរហន្ត ដូចគ្នាជាមួយបឋមមគ្គវិថី ផ្សេងគ្នាចំពោះគោត្រភូ មគ្គ ៣ ដែលសល់លោកហៅចិត្តដែលកើតមុនមគ្គនោះថា វោទានៈ។ ពាក្យថា វោទានៈ ក្នុងអត្ថយោជនា ទុតិយភាគពោលថា *វោទាយតីតិ វោទានំ* ប្រែថា ចិត្តណា រមែងផូរផង់គឺ បរិសុទ្ធ ព្រោះហេតុនោះ ចិត្តនោះ ទើបឈ្មោះថា *វោទានៈ* ។

## ផលសមាបត្តិមាន ៤ ប្រភេទ

១. ផលសមាបត្តិរបស់ព្រះសោតាបន្ន

២. ផលសមាបត្តិរបស់ព្រះសកទាគាមី

៣. ផលសមាបត្តិរបស់ព្រះអនាគាមី

៤. ផលសមាបត្តិរបស់ព្រះអរហន្ត

មួយប្រភេទៗ ក៏មាន ៥ យ៉ាងដោយអំណាចឈាន ៥ មានបឋមជ្ឈានជាដើម ទើបជាផលចិត្តរួម ២០ ដួង។ ផលសមាបត្តិវិថីទាំង-

អស់នេះ កើតបានក្នុងកាមភូមិ រូបភូមិ តែក្នុងអរូបភូមិមិនមានសោតា-បត្តិផលវិថី ក្នុងសុទ្ធាវាសភូមិមិនមានសោតាបត្តិផលវិថី និងមិនមានសកទាគាមិផលវិថីកើតឡើង ព្រោះជាភូមិរបស់ព្រះអនាគាមី ។

ក្នុងផលសមាបត្តិវិថីនោះ ឧបចារសមាធិជវនៈ ដែលកើតឡើង ៣ ឬ ៤ ខណៈ ហៅថា អនុលោមញាណរបស់ផលសមាបត្តិ មិនហៅថាគោត្រភូទេ សូម្បីក្នុងគម្ពីរមហាបដ្ឋាន ព្រះពុទ្ធអង្គក៏ត្រាស់ថា "អនុលោមរបស់ព្រះអរហន្ត ជាបច្ច័យដល់សមាបត្តិ ដោយអំណាចអនន្តរប្បច្ច័យ អនុលោម នៃព្រះសេក្ខៈ ជាបច្ច័យដល់ផលសមាបត្តិ ដោយអំណាចនៃអនន្តរប្បច្ច័យដូច្នេះ។ អនុលោម ៣ ឬ ៤ ជវនៈនោះ មានសង្ខារជាអារម្មណ៍ ផ្សេងអំពីមគ្គវិថី អាវជ្ជនៈរបស់មគ្គចិត្ត គឺគោត្រភូ មាននិព្វានជាអារម្មណ៍ ព្រោះក្នុងមគ្គវិថី ជាវិថីដែលធ្វើឱ្យសត្វរួចផុតទុក្ខ ចំណែកផលសមាបត្តិវិថី ជាវិថីរបស់ព្រះអរិយៈអ្នកគេចចេញដើម្បីនៅជាសុខក្នុងបច្ចុប្បន្នភពនេះប៉ុណ្ណោះ ។ **ផលចិត្តក្នុងមគ្គវិថីនោះ មិនហៅថាផលសមាបត្តិ ព្រោះមិនមានបរិកម្ម ក៏ផលចិត្តនោះកើតឡើង ២ ឬ ៣ ខណៈ ដោយអានុភាពនៃមគ្គ តែផលសមាបត្តិនេះ មិនទាក់ទងនឹងអរិយមគ្គ ព្រោះមានបរិកម្មដោយចំពោះទើបកើតឡើង ផលសមាបត្តិក៏គឺផលជវនៈ ដែលកើតជាប់បន្តគ្នានោះឯង ។**

ក្នុងវិសុទ្ធិមគ្គ ពោលថា ព្រះអរិយសាវ័កអ្នកប្រាថ្នាចូលផល-សមាបត្តិ ទៅកាន់ទីស្ងប់ស្ងាត់ហើយទើបពិចារណាសង្ខារទាំងឡាយដោយ

អំណាចវិបស្សនាញាណ ៩ មានឧទយព្វយានុបស្សនាជាដើម ក្នុងលំដាប់នៃវោទានៈ ដែលមានសង្ខារជាអារម្មណ៍ ចិត្តរបស់ព្រះអរិយសាវ័កអ្នកមានវិបស្សនាញាណដែលប្រព្រឹត្តទៅដោយលំដាប់នោះ ក៏ដល់និរោធ គឺមាននិព្វានជាអារម្មណ៍ ដោយអំណាចនៃផលសមាបត្តិ។ ដល់និរោធ គឺដល់ និព្វាន ៣ និព្វានណាមួយ គឺ អនិមិត្តនិព្វាន អប្បណិហិតនិព្វាន និងសុញ្ញតនិព្វាន។

មុនពេលដែលនឹងចូលផលសមាបត្តិ ត្រូវអធិដ្ឋានឱ្យផលសមាបត្តិតាំងនៅតាមប្រាថ្នាជាមុន។ ផលសមាបត្តិវិថីប្រព្រឹត្តទៅដូច្នេះ គឺ.-

ភ. ន. ទ. ម. អនុ. អនុ. អនុ. អនុ. ផល. ផល. ផល. ផល. ភ.

**អធិប្បាយៈ** ក្នុងផលសមាបត្តិនេះ ភវង្គដើម និងភវង្គចុងបានដល់ តិហេតុកភវង្គ ១៣ ដួង។ វិថីចិត្តរាប់ចាប់អំពី មនោទ្វារាវជ្ជនៈរហូតដល់អនុលោមដួងចុងបំផុត អនុលោម ៤ ខណៈ (គឺ ឧបចារៈសមាធិ ៤ ខណៈ នេះ ក្នុងវិសុទ្ធិមគ្គ ហៅថា គោត្រភូ) ដែលមានសង្ខារជាអារម្មណ៍ខ្លះ ហៅថា អនុលោមញាណខ្លះ ដែលផ្សេងអំពីគោត្រភូរបស់មគ្គដែលមានព្រះនិព្វានជាអារម្មណ៍ អនុលោមនេះមានត្រៃលក្ខណ៍ណានីមួយជាអារម្មណ៍។

ចំណែកផលជវនៈ (ផលសមាបត្តិ) មានព្រះនិព្វានជាអារម្មណ៍រមែងកើតបន្តគ្នាទៅច្រើនសន្ទឹកសន្ធាប់ ប្រមាណមិនបាន ។ សម្រាប់ព្រះអរិយបុគ្គលអ្នកត្រាស់ដឹងយឺត (មន្ទបុគ្គល) អនុលោមកើតឡើង ៤

ខណៈ សម្រាប់អរិយបុគ្គលអ្នកត្រាស់ដឹងឆាប់ (តិក្ខបុគ្គល) អនុលោមកើតឡើង ៣ ខណៈ បន្ទាប់មក ក៏ជាផលជវនៈកើតបន្តគ្នាទៅរហូតដល់វេលាដែលបានអធិដ្ឋានទុក រួចចិត្តក៏ប្រព្រឹត្តទៅក្នុងភវង្គដើម ។

ចប់លោកុត្តរវិថី ។

## អប្បនាជវនវារៈមានវេទនា ២

១. សោមនស្សអប្បនា បានដល់ អប្បនាជវនៈដែលកើតព្រម ជាមួយសោមនស្សវេទនា។

២. ឧបេក្ខាអប្បនា បានដល់ អប្បនាជវនៈដែលកើតព្រម ជាមួយឧបេក្ខាវេទនា។

អប្បនាវិថីទាំង ២ គឺ លោកិយអប្បនាវិថី (ឬហៅថា អប្បនា-ជវនវារៈ) ១ និងលោកុត្តរអប្បនាវិថី (ឬហៅថា លោកុត្តរអប្បនាជវន-វារៈ) ១។ វិថីទាំង ២ នេះ កាលបើចែកដោយវេទនា រមែងបានដល់ សោមនស្សវេទនា និងឧបេក្ខាវេទនា ដូចសង្គហគាថាទី ៥ ពោលថា.-

## សង្គហគាថា

៥. ទ្វត្តឹស សុខបុញ្ញម្ហា ទ្វាទសោបេក្ខា បរំ
សុខិតក្រិយាតោ អដ្ឋ ឆ សម្ភោន្តិ ឧបេក្ខា។

សោមនស្សអប្បនាជវនៈ ៣២ កើតអំពីមហាកុសលសោមនស្ស-ញាណសម្បយុត្ត ២, ឧបេក្ខាអប្បនាជវនៈ ១២ កើតអំពីមហា-កុសលឧបេក្ខាញាណសម្បយុត្ត ២។

សោមនស្សអប្បនាកិរិយាចិត្ត ៨ កើតអំពីមហាកិរិយាសោ-មនស្សញាណសម្បយុត្ត ២, ឧបេក្ខាអប្បនាជវនៈ ៦ កើតអំពីមហា-កិរិយាញាណសម្បយុត្ត ២។

# អធិប្បាយសង្គហគាថា

១. កាលមហាកុសលសោមនស្សញ្ញាណសម្បយុត្ត ២ ដួង កើតឡើងធ្វើកិច្ច បរិកម្ម ឧបចារៈ អនុលោម គោត្រភូ (ឬវោទានៈ) តាមលំដាប់ហើយ សោមនស្សអប្បនាជវនចិត្ត ៣២ ដួង រមែងកើតបន្ត។

សោមនស្សអប្បនាជវនចិត្ត ៣២ ដួង គឺ.-

បឋម, ទុតិយ, តតិយ, ចតុត្ថជ្ឈានកុសល (លោកិយអប្បនា) ៤ ដួង

មគ្គចិត្ត ៤ ប្រកបដោយសោមនស្សឈាន ៤ (លោកុត្តរៈ) ១៦ ដួង

ផលចិត្ត ៣ ខាងក្រោមប្រកបដោយសោមនស្សឈាន ៤ ជា ១២ ដួង

២. កាលមហាកុសលឧបេក្ខា ញាណសម្បយុត្តជវនៈ ២ ដួង ធ្វើកិច្ចហើយ ឧបេក្ខាអប្បនាជវនចិត្ត ១២ ដួង រមែងកើតបន្ត។ ឧបេក្ខាអប្បនាជវនចិត្ត ១២ ដួង គឺ.-

រូបាវចរកុសល ក្នុងបញ្ចមជ្ឈាន (លោកិយអប្បនា) ១ ដួង

អរូបាវចរកុសលចិត្ត (លោកិយអប្បនា) ៤ ដួង

មគ្គចិត្ត ៤ ក្នុងបញ្ចមជ្ឈាន (លោកុត្តរអប្បនា) ៤ ដួង

ផលចិត្តខាងក្រោម ៣ ក្នុងបញ្ចមជ្ឈាន (លោកុត្តរអប្បនា) ៣ ដួង

៣. ពេលមហាកិរិយា សោមនស្សញ្ញាណសម្បយុត្តជវនៈ ២ ដួង ធ្វើកិច្ចហើយ សោមនស្សអប្បនាជវនៈដែលជាកិរិយាចិត្ត ៨ ដួង រមែងកើតបន្ត។ សោមនស្សអប្បនាជវនៈដែលជាកិរិយាចិត្ត គឺ.-

រូបាវចរកិរិយាជវនៈក្នុងសោមនស្សឈាន (លោកិយអប្បនា) ៤ ដួង

អរហត្តផលក្នុងសោមនស្សឈាន ៤ (លោកុត្តរអប្បនា) ៤ ដួង

៤. កាលមហាកិរិយាឧបេក្ខាញាណសម្បយុត្តជវនៈ ២ ដួង ធ្វើកិច្ច ហើយ ឧបេក្ខាអប្បនាជវនៈ ៦ ដួង រមែងកើតបន្ត។ ឧបេក្ខាអប្បនាជវនៈ ៦ ដួង គឺ.-

| | | |
|---|---|---|
| រូបាវចរកិរិយាក្នុងបញ្ចមជ្ឈាន | (លោកិយអប្បនា) | ១ ដួង |
| អរូបាវចរកិរិយា | (លោកិយអប្បនា) | ៤ ដួង |
| អរហត្តផលក្នុងបញ្ចមជ្ឈាន | (លោកុត្តរអប្បនា) | ១ ដួង |

* កាលព្រះអនុរុទ្ធាចារ្យចែកអប្បនាជវនចិត្ត ៥៨ ដួង (មហគ្គត កុសលកិរិយា ១៨ លោកុត្តរៈ ៤០) តាមសង្គហគាថាទី ៥ នោះ ហើយ ដើម្បីឱ្យអត្ថនោះកាន់តែវិចិត្រឡើង ទើបចែកអប្បនាជវនចិត្ត ៥៨ ដួង នេះឯងដោយបុគ្គល ដូចសង្គហគាថាទី ៦ ថា.-

១. បុថុជ្ជនានំ សេក្ខានំ កាមបុញ្ញតិហេតុតោ
តិហេតុកាមក្រិយាតោ វីតរាគានមប្បនា។

អប្បនាជវនៈ (៤៤ ដួង) របស់ពួកតិហេតុកបុថុជ្ជន និងរបស់ផលសេក្ខបុគ្គល ៣ ពួក កើតបន្តអំពីតិហេតុកកាមាវចរកុសល ៤ ដួង។ អប្បនាជវនៈរបស់លោកអ្នកប្រាសចាករាគៈ រមែងកើតបន្តអំពីតិហេតុក-កាមាវចរកិរិយា ១៤ ដួង។

## អធិប្បាយសង្គហគាថាទី ៦

ពេលតិហេតុកបុគ្គលអ្នកបានឈាន និងផលសេក្ខបុគ្គ ៣ (គឺ ព្រះ

សោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី អ្នកនៅត្រូវការសិក្សា) ចម្រើនសមថកម្មដ្ឋាន មុនពេលដែលអប្បនាឈានកើតឡើងនោះ រមែងមានមហាកុសលញ្ញាណសម្បយុត្ត ៤ ដួង១ណាមួយកើតឡើងមុន គឺកើតឡើងធ្វើកិច្ចមានបរិកម្មជាដើមមុន បន្ទាប់មកអប្បនាជវនៈ ៤៤ ដួង១ណាមួយរមែងកើតបន្ត។ អប្បនាជវនៈ ៤៤ គឺ.-

១. មហគ្គតកុសលចិត្ត (លោកិយអប្បនា) ៩ ដួង

២. មគ្គចិត្ត (លោកុត្តរអប្បនា) ២០ ដួង

៣. ផលចិត្ត ៣ ផ្នែកខាងក្រោម (លោកុត្តរអប្បនា) ១៥ ដួង

អប្បនាជវនចិត្ត ១៤ ដួង របស់ព្រះខីណាស្រពអ្នកប្រាសចាករាគៈនោះ កាលនឹងកើតឡើង រមែងមានមហាកិរិយាញ្ញាណសម្បយុត្ត ៤ ដួង១ណាមួយកើតឡើងធ្វើកិច្ច មានបរិកម្មជាដើមមុន បន្ទាប់មក អប្បនាជវនៈ ១៤ របស់លោក ដួងណាមួយ ទើបកើតឡើង។ អប្បនាជវនចិត្ត ១៤ ដួងគឺ.-

១. មហគ្គតកិរិយាចិត្ត (លោកិយអប្បនា) ៩ ដួង

២. អរហត្តផលចិត្ត (លោកុត្តរអប្បនា) ៥ ដួង។

ចប់អប្បនាជវនវិថី។

# ប្រៀបធៀបវិថីនាំង ២

| កាមវិថី | អប្បនាវិថី |
|---|---|
| ១. ចិត្តមិនតាំងមាំក្នុងអារម្មណ៍ | មានចិត្តតាំងមាំក្នុងអារម្មណ៍ |
| ២. មានទាំងបញ្ចទ្វារវិថីទាំងមនោទ្វារវិថី | មានចំពោះតែមនោទ្វារវិថីប៉ុណ្ណោះ |
| ៣. មានអារម្មណ៍ ៦ គឺ.- រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ | មានចំពោះធម្មារម្មណ៍ទាំងនេះ គឺ.- អាកាសានញ្ចាយតនកុសល ១ កិរិយា ១ អាកិញ្ចញ្ញាយតនកុសល ១ កិរិយា ១ សមថនិមិត្ត បញ្ញត្តិអារម្មណ៍ និងមាននិព្វានជាអារម្មណ៍ |
| ៤. មានអតីតៈ, អនាគត, បច្ចុប្បន្ន និងកាលវិមុត្តជាអារម្មណ៍ | មានចំពោះអតីតៈជាអារម្មណ៍ និងកាលវិមុត្ត ជាអារម្មណ៍ ។ |
| ៥. អាស្រ័យវត្ថុ ៦ | អាស្រ័យហទយវត្ថុ និងមិនអាស្រ័យហទយវត្ថុក៏កើតឡើងបាន |
| ៦. មនោទ្វារវិថី មានអារម្មណ៍ ២ គឺវិភូតារម្មណ៍ អវិភូ- | មានវិភូតារម្មណ៍តែម្យ៉ាង ។ |
| - | - |
| ៧. មានតទាលម្ពណៈកើតបាន | មិនមានតទាលម្ពណៈកើត |
| ៨. មានជវនៈកើតមិនលើសពី | មានជវនៈកើតបានច្រើនតាំងតែ |

| | |
|---|---|
| ៧ ខណៈ | ១ ខណៈឡើងទៅ |
| ៩. មានវេទនាទាំង ៥ | មានសោមនស្ស និងឧបេក្ខាប៉ុណ្ណោះ |
| ១០. មានកុសល,អកុសល,វិបាក និងកិរិយា កើតបាន | មិនមានអកុសលចិត្តកើតឡើងទេ - |
| ១១. មានទាំងសសង្ខារ ទាំងអសង្ខារ | មានតែសសង្ខារិកៈប៉ុណ្ណោះ |
| ១២. មានសម្បយុត្ត ៥ យ៉ាងគឺ.- ទិដ្ឋិសម្បយុត្ត, បដិឃ-សម្បយុត្ត, វិចិកិច្ឆាសម្ប-យុត្ត, ឧទ្ធច្ចសម្បយុត្ត និងញាណសម្បយុត្ត | មានតែញាណសម្បយុត្តប៉ុណ្ណោះ - - - |
| ១៣. មានទាំងសោភណចិត្ត ទាំងអសោភណចិត្ត | មានតែសោភណចិត្តប៉ុណ្ណោះ |
| ១៤. មានតែលោកិយចិត្តម្យ៉ាង | មានទាំងលោកិយចិត្ត( មហគ្គតចិត្ត) ទាំងលោកុត្តរចិត្ត |
| ១៥. មានការសន្សំកិលេស និងមានតទង្គបហានតែម្យ៉ាង | មិនមានការសន្សំកិលេស មានវិក្ខ-ម្ភនបហាន និងសមុច្ឆេទបហាន |
| ១៦. កើតដល់ ទុគ្គតិ សុគតិបុគ្គល ទ្វិហេតុកៈ, តិហេតុកបុគ្គល | កើតដល់ តិហេតុកបុគ្គលប៉ុណ្ណោះ - |
| ១៧. កើតបាន ៣០ ភូមិ ( វៀរ | កើតបាន ២៦ ភូមិ វៀរអបាយ- |

| | |
|---|---|
| អសញ្ញសត្វ) | ភូមិ ៤ និងអសញ្ញសត្វភូមិ ១ |
| ១៨. មានវិថីចិត្តមិនលើស ៧ គឺ.- | មានវិថីចិត្តកើតបាន ២ គឺ.- |
| អាវជ្ជនវិថី ១ | អាវជ្ជនវិថី ១ |
| បញ្ចវិញ្ញាណវិថី ១ | ជវនវិថី ១ |
| សម្បដិច្ឆន្នវិថី ១ | - |
| សន្តីរណវិថី ១ | - |
| វោដ្ឋវនវិថី ១ | - |
| ជវនវិថី ១ | - |
| តទាលម្ពណវិថី ១ | - |
| ១៩. កើតតអំពីភវង្គចិត្ត ១៩ គឺ.- | កើតតអំពីភវង្គចិត្ត ១៣ គឺ.- |
| ឧបេក្ខាសន្តីរណវិបាក ២ | តិហេតុកវិបាក ៤ |
| មហាវិបាក ៨ | មហគ្គតវិបាក ៩ |
| មហគ្គតវិបាក ៩ | - |
| ២០. មានកាមចិត្តទាំងអស់កើត បាន ៥៤ គឺ.- | មានអប្បនាជវនចិត្តកើតបាន ៥៨ គឺ.- |
| អសោភណចិត្ត ៣០ ដួង | មហគ្គតកុសលចិត្ត ៩ ដួង |
| កាមសោភណចិត្ត ២៤ ដួង | មហគ្គតកិរិយាចិត្ត ៩ ដួង |
| | លោកុត្តរចិត្ត ៤០ ដួង |
| ២១. ក្នុងវិថីជាមួយគ្នា មាន | ក្នុងវិថីជាមួយគ្នា មានអារម្មណ៍ |

| | |
|---|---|
| តែម្យ៉ាង | អារម្មណ៍ច្រើនជាង ១ យ៉ាង |
| ២២. មានកាមជវនៈតែម្យ៉ាង | ក្នុងជវនៈ មានកាមជវនៈ មហគ្គត-ជវនៈ និងលោកុត្តរជវនៈ ។ |

ចប់ការប្រៀបធៀបកាមវិធីជាមួយនឹងអប្បនាវិធី ។



## បច្ចវេក្ខណវិថី[១]

បច្ចវេក្ខណវិថី ជាវិថីចិត្តដែលពិចារណា បើពោលដោយសភាវៈមាន ៣ ប្រភេទ គឺការពិចារណាធម៌របស់កល្យាណបុថុជ្ជន ១ ការពិចារណាអង្គឈានរបស់អ្នកបានឈាន ១ ការពិចារណាមគ្គ ផល និព្វានជាដើមរបស់ព្រះអរិយបុគ្គល ១។ ក្នុងទីនេះនឹងពោលដល់ការពិចារណារបស់ព្រះអរិយបុគ្គល។ កាលព្រះអរិយបុគ្គលបានបន្ទុះមគ្គណានីមួយហើយ តអំពីនោះញាណពិចារណា ក៏កើតឡើងពិចារណាមគ្គ ផល និព្វានជាដើម ដែលខ្លួនបន្ទុះហើយ សេចក្តីនេះសមគ្នានឹងព្រះតម្រាស់ដែលត្រាស់ទុកថា **វិមុត្តស្មឹ វិមុត្តមីតិ ញាណំ ហោតិ** ប្រែថា កាលចិត្តរួចស្រឡះហើយ សេចក្តីដឹង (ញាណ) ថា ចិត្តរួចស្រឡះហើយ រមែងមាន។ ញាណនេះបានដល់ញាណដែលជាកាមាវចរៈ ពោលគឺមហាកុសលញាណសម្បយុត្ត និង មហាកិរិយាញាណសម្បយុត្ត ធ្វើកិច្ចពិចារណាតាមមនោទ្វារ។

នៅក្នុងព្រះអភិធម្មត្ថសង្គហៈពោលយ៉ាងនេះថា ព្រះអរិយបុគ្គលរមែងពិចារណាមគ្គ ផល និព្វានយ៉ាងជាក់លាក់ តែការពិចារណាដល់កិលេសដែលលះហើយ និងកិលេសដែលនៅ សល់នោះ ព្រះអរិយបុគ្គលខ្លះក៏ពិចារណា ខ្លះក៏មិនពិចារណា, ក្នុងអដ្ឋកថា មជ្ឈិមនិកាយ មូលបណ្ណាសកៈ កែថា ព្រោះភាពជាអ្នកមិនឆ្លាតក្នុង កិលេសបញ្ញត្តិ ដែលគប្បីសម្លាប់ដោយមគ្គ ដូចក្នុងសង្គហគាថាពោលថា.-

---

១. បច្ចវេក្ខណវិថី មិនបានពោលទុកក្នុងវិថីសង្គហៈនេះទេ តែដែលនាំមកពោលទុកនេះ ក៏ព្រោះកាលមគ្គចិត្ត ផលចិត្តកើតឡើងហើយ បច្ចវេក្ខណវិថីរមែងកើតឡើង។

**មគ្គំ ផលញ្ច និព្វានំ បច្ចវេក្ខតិ បណ្ឌិតោ**
**បហីនេ កេ្លសេ សេសេ ច បច្ចវេក្ខតិ វា ន វា ។**

ប្រែថា បណ្ឌិតរមែងពិចារណាមគ្គ ផល និងនិព្វាន, លោកខ្លះ (ព្រះអរិយបុគ្គល) រមែងពិចារណាកិលេសដែលលះបានហើយ និងកិលេសដែលនៅសល់ ខ្លះទៀតលោកក៏មិនពិចារណា ។

ក្នុងអធិការនេះ ព្រះចៅសក្យព្រះនាមមហានាម ជាព្រះអនាគាមីបានទូលសួរព្រះដ៏មានព្រះភាគអំពីកិលេស ដែលនៅលះមិនទាន់បានថា "បពិត្រព្រះអង្គដ៏ចម្រើន ធម៌អ្វីទៅហ្ន៎ នៅផ្នែកខាងក្នុង ដែលខ្ញុំព្រះអង្គលះមិនបាន" ជាដើម[១] ។

ចំណែកព្រះអរហន្ត មិនមានការពិចារណាកិលេសដែលនៅសល់ទេ ព្រោះលោកលះកិលេសទាំងអស់បានហើយ ដូច្នោះបច្ចវេក្ខណញ្ញាណទាំងអស់ ទើបមាន ១៩ វារៈគឺ បច្ចវេក្ខណវិថី ១៥ វារៈរបស់ព្រះសេក្ខបុគ្គលអ្នកពិចារណា មគ្គ, ផល, និព្វាន, កិលេសដែលលះហើយ, កិលេសដែលនៅសល់ និងរបស់ព្រះអរហន្តអ្នកពិចារណា មគ្គ, ផល, និព្វាន និងកិលេសដែលលះបានហើយ ៤ វារៈទៀត រួមជា ១៩ វារៈ ។

ចប់បច្ចវេក្ខណវិថី ។

១. មជ្ឈិមនិកាយ មូលបណ្ណាសកៈ ។

## អប្បនាវិថី ៧

អប្បនាវិថី គឺវិថីចិត្តដែលសំដែងលោកិយអប្បនា ៥ និងលោកុត្តរអប្បនា ២ យ៉ាងរួមគ្នា។ ក្នុងអប្បនាវិថីទាំង ២ នោះ លោកិយអប្បនាវិថី ៥ គឺ អាទិកម្មិកឈានវិថី ១, ឈានសមាបត្តិវិថី ១, បាទកឈានវិថី ១, អភិញ្ញាវិថី ១ និងនិរោធសមាបត្តិវិថី ១។ លោកុត្តរអប្បនា ២ យ៉ាង គឺ មគ្គវិថី ១ និងផលសមាបត្តិវិថី ១។ បណ្ដាអប្បនាវិថីទាំង ៧ នោះ អាទិកម្មិកឈានវិថី, ឈានសមាបត្តិវិថី, មគ្គវិថី និងផលសមាបត្តិវិថី រួម ៥ វិថីនេះ បានសំដែងហើយដោយសង្ខេប នៅសល់អប្បនាវិថីទៀត ដែលនឹងសំដែង តទៅ គឺ បាទកឈានវិថី ១ អភិញ្ញាវិថី ១ និងនិរោធ-សមាបត្តិវិថី ១។

## ១. បាទកឈានវិថី

បាទកឈានវិថី គឺជាវិថីដែលជាបាទឱ្យអភិញ្ញាកើត ហៅថា អភិញ្ញាបាទកឈានវិថី។ ឈានដែលបានគ្រាដំបូង ហៅថា អាទិកម្មិក-ឈានវិថី។ កាលហ្វឹកហាត់ឈានដែលខ្លួនបាននេះរហូតកើតសេចក្ដីជំនាញដោយវសី ៥ ប្រការ ហៅថា ឈានសមាបត្តិ[១]។

## វសី ៥ ប្រការគឺ ÷

១. **អាវជ្ជនវសី** ជាអ្នកជំនាញក្នុងការនឹករក គឺនឹករកដល់ឈានដែលខ្លួនបានកាលណា ក៏នឹករកបានយ៉ាងឆាប់រហ័ស។

---

*១. ពាក្យថា សមាបត្តិ មានពាក្យកំណត់ថា សមាបជ្ជិតព្វាតិ សមាបត្តិ. ប្រែថា ធម្មជាតិណាដែលព្រះយោគីគប្បីបន្ទុះបានដោយល្អ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សមាបត្តិ។ បានដល់សមាបត្តិ ៣ គឺឈាន-សមាបត្តិ ១ ផលសមាបត្តិ ១ និងនិរោធសមាបត្តិ ១។*

**២. សមាបជ្ជនវសី** ជាអ្នកជំនាញក្នុងការចូលឈាន គឺអាចចូលឈានដែលខ្លួននឹកបានដោយឆាប់រហ័សតែមួយពព្រិចភ្នែក ។

**៣. អធិដ្ឋានវសី** ជាអ្នកជំនាញក្នុងការឱ្យឈានតាំងនៅ គឺប្រាថ្នានឹងចូលនៅក្នុងឈានយូរប៉ុណ្ណា ក៏អធិដ្ឋានឱ្យឈានតាំងនៅយូរប៉ុណ្ណោះ ។

**៤. វុដ្ឋានវសី** ជាអ្នកជំនាញក្នុងការចេញចាកឈាន គឺត្រូវការនឹងចេញចាកឈានក្នុងវេលាណា ដែលខ្លួនអធិដ្ឋានទុក ក៏ចេញបានក្នុងវេលានោះភ្លាម ។

**៥. បច្ចវេក្ខណវសី** ជាអ្នកជំនាញក្នុងការពិចារណាអង្គឈាន គឺ កាលចូលឈានណា មានអង្គឈានប៉ុន្មាន ក៏អាចពិចារណាបានយ៉ាងឆាប់រហ័សក្នុងឈាននោះ ។

## ២~អភិញ្ញាវិធី

ព្រះយោគាវចរ អ្នកបានសមាបត្តិ ៨ ប្រាថ្នានឹងញ៉ាំងអភិញ្ញាចិត្ត (ចិត្តដែលដឹងពិសេស) ឱ្យកើតឡើង នឹងត្រូវហ្វឹកហាត់ចិត្តឱ្យកើតសេចក្តីជំនាញ ១៤ យ៉ាងទៀត (ដោយសង្ខេប) គឺ ÷

**១. កសិណានុលោមតោ** គឺ ចូលឈានដោយផ្សាយកសិណតាមលំដាប់ ច្រើនរយដង ។

**២. កសិណបដិលោមតោ** គឺ ចូលឈានដោយផ្សាយកសិណបញ្ច្រាសច្រើនរយដង ។

៣. **កសិណានុលោមបដិលោមតោ** គឺ ចូលឈានដោយផ្សាយកសិណទាំងតាមលំដាប់ និងបញ្ច្រាសលំដាប់ ។

៤. **ឈានានុលោមតោ** គឺ ចូលឈានដោយលំដាប់នៃឈានសមាបត្តិ ៩ ។

៥. **ឈានបដិលោមតោ** គឺ ចូលឈានដោយបញ្ច្រាសលំដាប់នៃឈានសមាបត្តិ ៩ ។

៦. **ឈានានុលោមបដិលោមតោ**គឺ ចូលឈានទាំងតាមលំដាប់ទាំងបញ្ច្រាសលំដាប់នៃឈានសមាបត្តិ ៩ ។

៧. **ឈានានុក្កន្តកតោ** គឺ ចូលឈានសមាបត្តិ ៩ ដោយឆ្លងទៅតាមលំដាប់នៃឈាន ។

៨. **កសិណុក្កន្តកតោ** គឺ ចូលឈានដោយឆ្លងទៅតាមលំដាប់ ។

៩. **ឈានកសិណុក្កន្តកតោ** គឺ ចូលឈានដោយឆ្លងទាំងឈានទាំងកសិណទៅតាមលំដាប់ ។

១០. **អង្គសង្កន្តិតោ** គឺ ចូលរូបឈាន ៥ ដោយប្តូរអង្គ ។

១១. **អារម្មណសង្កន្តិតោ** គឺ ចូលឈានដោយប្តូរអារម្មណ៍ ។

១២. **អង្គារម្មណសង្កន្តិតោ** គឺ ចូលឈានដោយប្តូរទាំងអង្គទាំងអារម្មណ៍ ។

១៣. **អង្គវវដ្ឋាបនតោ** គឺ ចូលឈានដោយកំណត់អង្គឈានសមាបត្តិ ៥។

១៤. **អារម្មណវវដ្ឋាបនតោ** គឺ ចូលឈានដោយកំណត់អារម្មណ៍ឈានសមាបត្តិ ៥។

កាលឈានលាភីបុគ្គលហ្វឹកហាត់ចិត្ត ដើម្បីធ្វើឱ្យអភិញ្ញាចិត្តមានសភាពជំនាញហើយ ពេលប្រាថ្នានឹងញ៉ាំងអភិញ្ញាចិត្តណានីមួយឱ្យកើតឡើង រមែងបដិបត្តិដូច្នេះ គឺ ÷

១. ចូលរូបាវចរបញ្ចមជ្ឈានមុន ដើម្បីជាបាទឱ្យអភិញ្ញាចិត្តកើត វិថីចិត្តនេះ ហៅថា បាទកឈានវិថី មានសភាពយ៉ាងនេះ គឺ.-

ភ. ន. ទ. ម. បរិ. ឧប. អនុ. គោ. ឈ. ឈ. ឈ. ឈ. ឈ. ភ.

២. ចេញចាកបាទកឈានហើយ អធិដ្ឋានឱ្យអភិញ្ញាណាមួយកើត វិថីនេះ ជាកាមវិថី មានសភាពដូច្នេះ គឺ ÷

ភ. ន. ទ. មនោ. ជ. ជ. ជ. ជ. ជ. ជ. ជ. ភ.

៣. កាលអធិដ្ឋានហើយ ក៏ត្រឡប់ចូលរូបាវចរឈាន ដែលជាបាទទៀត (ដូចគ្នានឹងខទី ១) ។

## អធិប្បាយអភិញ្ញាវិថី

ព្រះយោគាវចរនោះ ពេលចូលឈានដែលជាបាទនៃអភិញ្ញាហើយ ចេញចាកឈាននោះហើយ ត្រូវការឱ្យខ្លួនបែកជាមនុស្ស ១០០ នាក់ ក៏បរិកម្មថា **សតំ ហោមិ សតំ ហោមិ** (យើងចូរជាមនុស្ស ១០០ នាក់ ៗ)

ដូច្នេះ ហើយចូលឈានដែលជាបាទទៀត ចេញចាកឈានហើយ ព្រមគ្នានឹងចិត្តតាំងមាំនោះឯង លោកក៏ជាមនុស្ស ១០០ នាក់តាមដែលប្រាថ្នា ប្រសិនបើគ្រានេះមិនទាន់បានជាមនុស្ស ១០០ នាក់ ក៏គប្បីបរិកម្មហើយចូលឈានក្នុងវារៈទី ២ ចេញចាកឈានហើយ អធិដ្ឋានទៀត ព្រោះក្នុងអដ្ឋកថាសំយុត្តនិកាយពោលទុកថា ចូលមួយវារៈ ឬពីរវារៈក៏គួរ តែក្នុងមហាដីកាពោលថា ៣ វារៈ ឬច្រើនជាងនោះក៏បាន ព្រោះការចម្រើនអភិញ្ញា ក៏មានសភាពដូចនឹងការចម្រើនឈាន។ សូម្បីក្នុងអភិញ្ញាដទៃៗមានទិព្វសោតៈជាដើមក៏មានន័យដូចគ្នា។

ម្យ៉ាងទៀត ក្នុងការអធិដ្ឋាននោះ ចិត្តក្នុងឈានដែលជាបាទ ជាចិត្តសម្បយុត្តដោយរូបាវចរបញ្ចមជ្ឈាន មានបដិភាគនិមិត្តជាអារម្មណ៍ ចំណែកចិត្តដែលបរិកម្មថា យើងចូរជាមនុស្ស ១០០ នាក់ ដែលមានមនុស្សចំនួនច្រើនជាអារម្មណ៍ ហើយអារម្មណ៍ទាំងនោះត្រឹមតែជាពណ៌ (វណ្ណៈ) បញ្ញត្តិថាជាមនុស្សពិតៗ ក៏មិនមែន និងចិត្តដែលអធិដ្ឋាននោះជាចិត្តមួយដួងប៉ុណ្ណោះ កើតតអំពីគោត្រភូ មានសភាពដូចអប្បនាវិថីដែលបានពោលទុកហើយ។ អភិញ្ញាវិថីកើតឡើងដូច្នេះ គឺ ÷

ភ. ន. ទ. ម. បរិ. ឧប. អនុ. គោ. អភិញ្ញា. ភ.

ខណៈដែលអំណាចរបស់អភិញ្ញាចិត្តកំពុងប្រព្រឹត្តទៅនោះ មនោទ្វារវិថីរមែងកើតតអំពីអភិញ្ញាវិថី មនោទ្វារនោះជាកាមវិថី មានជវនៈជាមហាកុសល ឬមហាកិរិយា តាមគួរដល់បុគ្គលដែលធ្វើអភិញ្ញានោះ។

## លោកិយអភិញ្ញា ៥ យ៉ាង

១. ឥទ្ធិវិធិអភិញ្ញា អភិញ្ញាដែលសម្ដែងឫទ្ធិបានផ្សេងៗ

២. ទិព្វសោតអភិញ្ញា អភិញ្ញាដែលធ្វើឱ្យកើតត្រចៀកទិព្វ ។

៣. ចេតោបរិយអភិញ្ញា អភិញ្ញាដែលកំណត់ដឹងចិត្តអ្នកដទៃ ។

៤.បុព្វេនិវាសានុស្សតិអភិញ្ញា អភិញ្ញាដែលឱ្យរលឹកដល់ជាតិមុនបាន ។

៥. ទិព្វចក្ខុអភិញ្ញា អភិញ្ញាដែលឱ្យកើតភ្នែកទិព្វ ។

អភិញ្ញាទាំង ៥ នេះ ចំពោះទិព្វចក្ខុអភិញ្ញា ចែកចេញជា ២ អភិញ្ញាទៀត គឺ យថាកម្មូបគអភិញ្ញា បានដល់បញ្ញាដែលដឹងកម្មរបស់សត្វទាំងឡាយ និងអនាគតង្សអភិញ្ញា បានដល់បញ្ញាដឹងអនាគត ចំណែកលោកុត្តរអភិញ្ញាមានតែម្យ៉ាង គឺ អាសវក្ខយអភិញ្ញា បានដល់អភិញ្ញាដែលឱ្យអាសវៈអស់ទៅ ។

ចប់អភិញ្ញាវិថី ។

## ៣. និរោធសមាបត្តិវិធី[១]

និរោធសមាបត្តិវិធី ជាវិធីសមាបត្តិ ដែលរលត់សញ្ញាវេទនារបស់ព្រះអនាគាមី និងព្រះអរហន្តអ្នកបានឈានសមាបត្តិ៨។ និរោធ-សមាបត្តិនេះ មិនគួរពោលថាជាសង្ខតៈ ឬ អសង្ខតៈ ជាលោកិយៈ ឬ លោកុត្តរៈ ព្រោះនៅក្នុងបឋមសមន្តប្បាសាទិកាអដ្ឋកថាព្រះវិន័យពណ៌នាចតុត្ថបារាជិក ពោលទុកថា "សូម្បីកាលភិក្ខុពោលថា ខ្ញុំព្រះករុណាចូលនិរោធសមាបត្តិបាន ឬ ខ្ញុំព្រះករុណាបាននិរោធសមាបត្តិ" ដូច្នេះ លោកក៏មិនត្រូវបារាជិក ព្រោះនិរោធសមាបត្តិមិនបានពោលថាជាលោកិយ ឬ លោកុត្តរៈ។ សូម្បីថា សមាបត្តិនេះ នឹងមិនមែនលោកុត្តរៈនិញ្វនក៏ពិតដល់យ៉ាងនោះ អ្នកដែលអាចចូលសមាបត្តិនេះបាន រមែងមានសេចក្តីសុខស្ងប់ដ៏ប្រណីតក្រៃលែងដូចនិញ្វន ទើបលោកហៅនិរោធសមាបត្តិនេះថា និញ្វនក្នុងបច្ចុប្បន្នជាតិនេះ។

អ្នកដែលចូលសមាបត្តិនេះបានរមែងប្រកបដោយគុណធម៌ ៤ គឺ.-

១/ ជាព្រះអនាគាមី ឬជាព្រះអរហន្ត។

២/ ជាអ្នកបានឈានសមាបត្តិ ៨។

៣/ មានវសី ៥ រហ័សរហួន និងជំនាញ (ចរិយៈ) សម្បទា សេចក្តីដល់ព្រម) ៤ គឺ.-

(១) ជំនាញក្នុងសមថពលៈ និងវិបស្សនាពលៈ។

---

១. សេចក្តីពិស្តារ មាននៅក្នុង ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ។

(២) ជំនាញក្នុងការរំងាប់វចីសង្ខារ កាយសង្ខារ និងចិត្តសង្ខារ ។

(៣) ជំនាញក្នុងញាណចរិយា ១៦ គឺ.-

១. អនិច្ចានុបស្សនា ២. ទុក្ខានុបស្សនា ៣. អនត្តានុបស្សនា ៤. និព្វិទានុបស្សនា ៥. វិរាគានុបស្សនា ៦. និរោធានុបស្សនា ៧. បដិនិស្សគ្គានុបស្សនា ៨. វិវដ្តានុបស្សនា ៩. សោតាបត្តិមគ្គ ១០. សោតាបត្តិផលសមាបត្តិ ១១. សកទាគាមិមគ្គ ១២. សកទាគាមិផលសមាបត្តិ ១៣. អនាគាមិមគ្គ ១៤. អនាគាមិផលសមាបត្តិ (ព្រះអនាគាមី មាន ១៤) ១៥. អរហត្តមគ្គ ១៦. អរហត្តផលសមាបត្តិ ។

(៤) ជំនាញក្នុងសមាធិចរិយា ៩ គឺ ក្នុងបឋមជ្ឈាន ទុតិយជ្ឈាន ។ល។ នេវសញ្ញានាសញ្ញាយតនជ្ឈាន រួមជា ៨ និងឧបចារសមាធិរបស់ឈាននោះៗ ដែលហៅថាចរិយា ១ ទៀត ជា ៩ ។

៤/ ព្រះអរិយបុគ្គលក្នុងបញ្ចវោការភូមិប៉ុណ្ណោះ ដែលចូលនិរោធសមាបត្តិបាន ចំណែកក្នុងចតុវោការភូមិនោះចូលនិរោធសមាបត្តិមិនបានទេ ព្រោះមិនមានរូបសមាបត្តិ មានបឋមជ្ឈានជាដើម ជាអនុបុព្វនិរោធ ការរលត់សង្ខារដោយលំដាប់ និងជាអនុបុព្វសមាបត្តិ តែអាចារ្យពួកខ្លះពោលថា ព្រោះមិនមានវត្ថុ គឺ ករជកាយ ។

★គប្បីជ្រាបការចូលនិរោធសមាបត្តិ ដូចតទៅនេះ.-

ភិក្ខុក្នុងព្រះសាសនានេះ មានសេចក្តីនឿយណាយក្នុងការប្រព្រឹត្តទៅ និងសេចក្តីបែកធ្លាយនៃសង្ខារទាំងឡាយ ទើបគិតថា "យើងនឹងជា

អ្នកមិនមានចិត្ត បន្ទុះសេចក្តីរលត់ ស្រដៀងនឹងព្រះនិព្វាន នៅជាសុខក្នុងបច្ចុប្បន្នជាតិនេះ" ដូច្នេះ ទើបចូលនិរោធសមាបត្តិ លោកចូលបឋមជ្ឈានដោយកម្លាំងនៃសមថៈ ចេញចាកបឋមជ្ឈាននោះហើយ ក៏ពិចារណាសង្ខារទាំងឡាយក្នុងឈាន[១] ដោយសេចក្តីជា អនិច្ចំ ទុក្ខំ និងអនត្តាដោយកម្លាំងនៃវិបស្សនា។

វិធីនៃបឋមជ្ឈាន មានដូច្នេះ គឺ.-

ភ. ន. ទ. ម. បរិ. ឧប. អនុ. គោ. ឈាន. ភ.

វិធីនៃវិបស្សនា[២] មានដូច្នេះ គឺ.-

ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ជ. ជ. ភ.

សូម្បីក្នុងទុតិយជ្ឈាន តតិយជ្ឈាន ។ល។ ក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ក៏ពិចារណាដោយន័យនេះឯង កាលចេញចាកអាកិញ្ចញ្ញាយតនជ្ឈានហើយ មិនត្រូវពិចារណាសង្ខារទាំងឡាយ តែប្តូរមកជាអធិដ្ឋានដើម្បីធ្វើបុព្វកិច្ច (កិច្ចខាងដើម) ៤ យ៉ាង បើមិនធ្វើបុព្វកិច្ចជាមុន ចូលនេវសញ្ញានាសញ្ញាយតនជ្ឈានទៅហួស រមែងមិនអាចនឹងរំលត់ សញ្ញាវេទនា (សេចក្តីជាអ្នកមិនមានចិត្ត) ហើយឈានដែលចូលនោះ ក៏នឹងថយត្រឡប់មកតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានដូចដើម។

---

*១. គប្បីជ្រាបការពិចារណាសង្ខារទាំងឡាយ ក្នុងអនុបទសូត្រ តាមដែលព្រះសារីបុត្រពិចារណាក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈនោះផងចុះ។*

*២. វិបស្សនាមាន ៣ គឺវិបស្សនាកំណត់សង្ខារ ១ វិបស្សនាដែលជាផលសមាបត្តិ ១ និង វិបស្សនាដែលជានិរោធសមាបត្តិ ១ (អដ្ឋកថាបដិសម្ភិទាមគ្គ)។*

## អធិដ្ឋានធ្វើបុព្វកិច្ច ៤ គឺ ÷

១. នានាពទ្ធអវិកោបនំ សូមមិនឱ្យរបស់របរផ្សេងៗ ដែលទាក់ទងនឹងភិក្ខុបាត់បង់ ។

២. សង្ឃបដិមាននំ ការរង់ចាំរបស់សង្ឃ (នឹងចេញភ្លាម) ។

៣. សត្ថុបក្កោសនំ ការទទួលតម្រាស់ហៅរបស់ព្រះសាស្តា ។

៤. អទ្ធានបរិច្ឆេទោ កំណត់កាលវេលា គឺកំណត់កាលរបស់ជីវិតថា នឹងប្រព្រឹត្តទៅបានរហូត ៧ ថ្ងៃឬអត់ បើមិនប្រព្រឹត្តទៅបាន ក៏មិនចូល បើប្រព្រឹត្តទៅបានក៏នឹងចូល ព្រោះនិរោធមិនអាចហាមសេចក្តីស្លាប់បាន ហើយក្នុងនិរោធនេះ ក៏មិនមានចិត្តធ្វើចុតិកិច្ច កាលវេលាអស់អាយុហើយ និរោធនេះក៏នឹងចេញទៅក្នុងរវាងដោយកម្លាំងនៃកម្ម កាលជ្រាបដល់វត្ថុដែលគួរហើយ ទើបចូលនិរោធសមាបត្តិ ដោយកំណត់វេលាចេញ។ កាលធ្វើបុព្វកិច្ចហើយ ទើបចូលនេវសញ្ញានាសញ្ញាយតនៈ កាលឈានចិត្តនេះកើតឡើង ១ ឬ ២ ខណៈចិត្ត ហើយជាអ្នកមិនមានចិត្តសម្មស្សនិរោធ ពេលចេញចាកនិរោធ ផលចិត្តរមែងកើត ១ ខណៈ ហើយជាភវង្គ។ មានសភាពនិរោធសមាបត្តិ ដូច្នេះគឺ.-

## និរោធសមាបត្តិវិធី

ក្នុងវិថីនៃនិរោធសមាបត្តិនោះ មាននេវសញ្ញានាសញ្ញាយតនជ្ឈានកើតឡើងមុន ដូចសភាពវិថីតទៅនេះ គឺ.-

១. ភវង្គចលនៈ ១ ខណៈ

២. ភវង្គុបច្ឆេទៈ ១ ខណៈ

៣. មនោទ្វារាវជ្ជនៈ ១ ខណៈ ១ វិថី

៤. បរិកម្ម ១ ខណៈ ១ វិថី

៥. ឧបចារៈ ១ ខណៈ ១ វិថី

៦. អនុលោម ១ ខណៈ ១ វិថី

៧. គោត្រភូ ១ ខណៈ ១ វិថី

៨-៩.នេវសញ្ញា- ២ ខណៈ ១ វិថី

១០. និរោធ រលត់សញ្ញាវេទនា (មិនមានចិត្តកើត)

១១. ផលចិត្ត ១ ខណៈ ១ វិថី (ចេញចាកនិរោធ)

១២. ភវង្គបាតៈ ប្រព្រឹត្តទៅក្នុងភវង្គដើម ។

វិថីនៃនិរោធសមាបត្តិនេះ បើជាវិថីរបស់ព្រះអរិយបុគ្គល ដែលជាខិប្បាភិញ្ញា មិនមានបរិកម្ម បើជាព្រះអរិយបុគ្គលដែលជាទន្ធាភិញ្ញា ក៏ត្រូវមានបរិកម្មផង ។ ក្នុងវិថីនោះ កាលនេវសញ្ញានាសញ្ញាយតនជ្ឈាន ២ ខណៈរលត់ហើយ និរោធក៏នឹងប្រព្រឹត្តទៅ ៧ ថ្ងៃ ឬតាមដែលប្រាថ្នាកាល គ្រប់រយៈពេលដែលបានអធិដ្ឋានទុកហើយ ផលចិត្តរបស់ព្រះអនាគាមី ឬ របស់ព្រះអរហន្ត រមែងកើតឡើង ១ ខណៈមុន តពីនោះចិត្តក៏ប្រព្រឹត្តទៅ ក្នុងភវង្គដើម ។ ចំណែកសភាវៈដែលមិនរលត់ក្នុងសមាបត្តិនោះ បានដល់កម្មជរូប ឧតុជរូប និងអាហារជរូប សភាពធម៌ទាំង ៣ នេះរមែងកើត ប្រព្រឹត្តទៅតាមប្រក្រតី ។

ចប់និរោធសមាបត្តិវិថី ។

## មរណាសន្នវិថី

មរណាសន្នវិថី បានដល់វិថីចិត្តដែលកើតឡើងក្នុងវេលាជិតស្លាប់ ក្នុងវិថីនេះមានជវនៈកើតបានត្រឹមតែ ៥ ខណៈ ព្រោះចិត្តមានកម្លាំងចុះខ្សោយ បន្ទាប់អំពីកម្មដែលនាំឱ្យកើតនោះជិតនឹងអស់អំណាចហើយ និងហទយវត្ថុដែលជាទីអាស្រ័យកើតកំពុងតែអន់ថយចុះគ្រប់ខណៈ ដូច្នោះ កម្លាំងរបស់ជវនៈទើបមានត្រឹមតែ ៥ ខណៈប៉ុណ្ណោះ ដូចចង្កៀងភ្លើងជិតអស់ប្រេង ឬប្រឆេះដែលជិតនឹងអស់ ភាពភ្លឺស្វាងរបស់ដួងភ្លើងក៏នឹងព្រឹម ៗ ចុះ ព្រោះអស់បច្ច័យ កាលចុតិចិត្តរបស់សត្វនោះរលត់ហើយ ភ្លាមនោះឯង បដិសន្ធិក៏នឹងកើតឡើង ដោយមិនមានអ្វីកើតខណ្ឌ ព្រោះនៅមានបោនោព្ភវិកាតណ្ហា។

## មរណៈ ៤ យ៉ាង

១. **អាយុក្ខយមរណំ** ស្លាប់ព្រោះអស់អាយុ( មិនទាន់អស់កម្ម)

២. **កម្មក្ខយមរណំ** ស្លាប់ព្រោះអស់កម្ម( មិនទាន់អស់អាយុ)

៣. **ឧភយក្ខយមរណំ** ស្លាប់ព្រោះអស់ទាំងអាយុអស់ទាំងកម្ម

៤. **ឧបច្ឆេទមរណំ** ស្លាប់ព្រោះត្រូវកម្មដទៃកាត់ផ្ដាច់ ។

ក្នុងវេលាជិតស្លាប់ សត្វនោះនឹងមានអារម្មណ៍យ៉ាងណាមួយ ក្នុងអារម្មណ៍ទាំង ៣ យ៉ាង គឺ កម្ម, កម្មនិមិត្ត និងគតិនិមិត្ត។ បណ្ដាអារម្មណ៍ទាំង ៣ នោះ កម្ម បានដល់ កុសលកម្ម និងអកុសលកម្ម ដែលសត្វនោះធ្វើទុកក្នុងអតីតៈ ចំណែកកុសលកម្ម មានការឱ្យទាន រក្សាសីល និងចម្រើន

ភាវនាជាដើម ។ ចំណែកអកុសលកម្ម មានការសម្លាប់សត្វ និងលួចទ្រព្យជាដើមយ៉ាងណាមួយ នឹងមកប្រាកដចំពោះមុខ ដោយសញ្ញាដែលធ្លាប់ធ្វើទុកក្នុងកាលមុន ហាក់បីដូចជាថា កម្មនោះកំពុងកើតឡើងជាមួយនឹងខ្លួន ដោយប្រាកដតាមមនោទ្វារប៉ុណ្ណោះ កម្មនេះទើបជាអតីតអារម្មណ៍។

**កម្មនិមិត្ត** បានដល់ និមិត្តដែលជាហេតុនៃការប្រព្រឹត្តធ្វើកម្ម គឺ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ជាហេតុឱ្យធ្វើកម្មដោយកាយ វាចា និងចិត្ត ក្នុងវេលាជិតស្លាប់ កម្មនិមិត្តនេះ រមែងជាអារម្មណ៍ប្រាកដ ក្នុងទ្វារទាំង ៦ ទ្វារណាមួយ។ ចំណែកកុសលបានឃើញព្រះពុទ្ធបដិមា បានធ្វើការបូជាដោយផ្កាឈើ បានឮសម្លេងព្រះ-ធម៌បានដឹងក្លិនគ្រឿងក្រអូបដែលបូជាធម៌ជាដើមដែលកំពុងប្រព្រឹត្តទៅ ។ ចំណែកអកុសល មានការឃើញសត្វដែលខ្លួនសម្លាប់ ឃើញគ្រឿងស្រោសម្រាប់សម្លាប់ជាដើមកំពុងប្រព្រឹត្តទៅ កម្មនិមិត្តនេះ ទើបជាអារម្មណ៍ដែលជាអតីតៈ និងបច្ចុប្បន្ន ព្រោះប្រព្រឹត្តទៅក្នុងទ្វារ ៦។

**គតិនិមិត្ត** បានដល់ និមិត្តជាហេតុនឹងទៅកើតក្នុងភពមុខ ក្នុងបាលីបរិច្ឆេទទី ៥ ពោលថា "**ឆទ្វារគ្គហិតំ កម្មនិមិត្តំ គតិនិមិត្តញ្ច បច្ចុប្បន្នមតីតារម្មណំ ឧបលព្ភតិ** ប្រែថា កម្មនិមិត្ត និងគតិនិមិត្ត ដែលទ្វារ ៦ កាន់យកហើយ (ជាអារម្មណ៍) ប្រព្រឹត្តទៅជាបច្ចុប្បន្ន និងអតីតៈ។ ចំណែកកម្ម ជាអតីតារម្មណ៍ ហើយប្រព្រឹត្តទៅតាមមនោទ្វារប៉ុណ្ណោះ។

ក្នុងធម្មបទភាគ ១ ពោលថា ធម្មិកឧបាសកឈឺ ដេកស្តាប់ ព្រះ-

សង្ឃស្វាធ្យាយសតិប្បដ្ឋានសូត្រ ។ល។ ខណៈនោះឯង រថទិព្វ ៦ គ្រឿង មកអំពីទេវលោក ៦ ជាន់ ទេវតាដែលឈរលើរថផ្សេងក៏គោរពអញ្ជើញ ដោយពាក្យថា "យើងនឹងនាំលោកទៅក្នុងទេវលោករបស់យើង លោកដ៏ចម្រើន លោកចូរកើតក្នុងរថនេះ ចូររីករាយក្នុងទេវលោករបស់យើង" ដូច្នេះ។

រឿងមួយទៀត កាលព្រះបាទទុដ្ឋគាមិណីអភយរាជ(១) ទ្រង់ប្រឈួនជិតនឹងសោយទីវង្គត ។ល។ ពួកព្រះភិក្ខុបានធ្វើការស្វាធ្យាយធម៌ឱ្យទ្រង់ស្តាប់ ក្នុងខណៈនោះឯង ទេវតា ៦ ជាន់ នាំរថទិព្វ ៦ គ្រឿង មកអណ្តែតនៅក្នុងអាកាស ស្រែកអញ្ជើញឱ្យស្តេចឡើងរថ មានប្រការដូចដែលបានពោលហើយនោះឯង ។

ដោយរឿងដែលលើកមកនេះសំដែងថា គតិនិមិត្តជាបច្ចុប្បន្នកាលនៃមរណាសន្នវិថីមុនហើយជាអតីតកាលនៃមរណាសន្នវិថីក្នុងខាងក្រោយ ដូច្នោះ ព្រះដីកាចារ្យទាំងឡាយ ទើបពោលថា គតិនិមិត្តជាអតីតកាលបាន ចំណែកព្រះអដ្ឋកថាចារ្យ លោកជ្រើសរើសយកសំដែងចំពោះសន្តតិ ដែលជាបច្ចុប្បន្នប៉ុណ្ណោះ ទើបពោលថា គតិនិមិត្តជាបច្ចុប្បន្នកាល (ដោយន័យដែលប្រព្រឹត្តទៅដោយច្រើន) ។

បើសត្វនឹងទៅកើតក្នុងសុគតិភូមិ គតិនិមិត្ត ក៏នឹងប្រាកដជាប្រាសាទ វិមានទិព្វ ទេវបុត្រ ទេវធីតាជាដើមក្នុងស្ថានសួគ៌ ជាទេវភូមិ ។

---

១. ក្នុងគម្ពីរមហាវង្សក្បាលទី ១ បរិច្ឆេទទី ៣២ ពោលថា ព្រះបាទទុដ្ឋគាមិណីអភយរាជ នឹងបានជាព្រះអគ្គសាវ័កទី ១ ព្រះបាទសទ្ធាតិស្សៈជាព្រះអនុជ នឹងជាព្រះអគ្គសាវ័កទី ២ របស់ព្រះអរិយមេត្រីយ ។

បើកើតក្នុងមនុស្សក៏ឃើញគភ៌មាតា អារាម ផ្ទះ ឃើញមនុស្ស ឃើញភិក្ខុសាមណេរជាដើម ក្នុងភូមិមនុស្ស។ បើនឹងទៅកើតក្នុងទុគ្គតិភូមិ ក៏ឃើញសត្វផ្សេងៗ មានសេះ ដំរីជាដើម ដែលជាភូមិរបស់សត្វតិរច្ឆាន, បើឃើញប្រេត អសុរកាយ ឃើញព្រៃក្រាស់ ឃើញជ្រោះជាដើម ដែលជាភូមិរបស់ប្រេត និងអសុរកាយ, ក៏នឹងកើតជាប្រេតនិងអសុរកាយ បើឃើញគ្រឿងប្រហារផ្សេងៗ និងឃើញនាយនិរយបាលជាដើមក៏នឹងកើតក្នុងនិរយភូមិ។

អារម្មណ៍ទាំង ៣ មានកម្មជាដើម រមែងកើតឡើងដោយអំណាចកម្ម ៤ យ៉ាងគឺ.-

១. គរុកម្ម　　កម្មធ្ងន់ (ទាំងកុសល ទាំងអកុសល)

២. អាសន្នកម្ម　កម្មដែលធ្វើក្នុងវេលាជិតស្លាប់

៣. អាចិណ្ណកម្ម　កម្មដែលធ្វើរឿយៗ

៤. កដត្តាកម្ម　　កម្មដែលធ្វើតិចតួច។

## មរណាសន្នវិថី ៩ ប្រភេទ

១. ចុតិ ចាក កាមភូមិ ១១ ហើយបដិសន្ធិក្នុងកាមភូមិ ១១

២. ចុតិ ចាក សុគតិកាមភូមិ ៧ ហើយបដិសន្ធិក្នុងរូបភូមិ ១៦

៣. ចុតិ ចាក កាមសុគតិភូមិ ៧ ហើយបដិសន្ធិក្នុងអរូបភូមិ ៤

៤. ចុតិ ចាក រូបភូមិ ហើយបដិសន្ធិក្នុងរូបភូមិ

៥. ចុតិ ចាក រូបភូមិ ហើយបដិសន្ធិក្នុងកាមសុគតិភូមិ

៦. ចុតិ ចាក រូបភូមិ ហើយបដិសន្ធិក្នុងអរូបភូមិ

៧. ចុតិ ចាក អរូបភូមិ ហើយបដិសន្ធិក្នុងអរូបភូមិ

៨.ចុតិ ចាក អរូបភូមិ ហើយបដិសន្ធិក្នុងកាមសុគតិភូមិ

៩.ចុតិរបស់ព្រះអរហន្តមាន ៥ យ៉ាង ចុតិហើយមិនមានបដិសន្ធិ ។

## ការចុតិមាន ២ យ៉ាង

១. បញ្ចទ្វារ ២០ វិថី

២. មនោទ្វារ ៤ វិថី

មរណាសន្នវិថីតាមបញ្ចទ្វារ ទ្វារនីមួយៗ មាន ៤ វិថី គឺ.-

១. តី. ន. ទ. ប. វិ. ស. ណ. វោ. ជ. ជ. ជ. ជ. ជ. ត. ត. ភ. ចុតិ.

២. តី. ន. ទ. ប. វិ. ស. ណ. វោ. ជ. ជ. ជ. ជ. ជ. ត. ត. ចុតិ.

៣. តី. ន. ទ. ប. វិ. ស. ណ. វោ. ជ. ជ. ជ. ជ. ជ. ភ. ចុតិ.

៤. តី. ន. ទ. ប. វិ. ស. ណ. វោ. ជ. ជ. ជ. ជ. ជ. ចុតិ.

វិថីទី ១-២ ជាអតិមហន្តារម្មណ៍ វិថីទី ៣-៤ ជាមហន្តារម្មណ៍ ។

មរណាសន្នវិថីតាមមនោទ្វារ ៤ វិថី គឺ.-

១. ន. ទ. មនោ. ជ. ជ. ជ. ជ. ជ. ត. ត. ភ. ចុតិ.

២. ន. ទ. មនោ. ជ. ជ. ជ. ជ. ជ. ត. ត. ចុតិ.

៣. ន. ទ. មនោ. ជ. ជ. ជ. ជ. ជ. ភ. ចុតិ.

៤. ន. ទ. មនោ. ជ. ជ. ជ. ជ. ជ. ចុតិ.

វិថីទី ១-២ ជាវិភូតារម្មណ៍ វិថីទី ៣-៤ ជាអវិភូតារម្មណ៍ ។

កាមចុតិ និងបដិសន្ធិក្នុងភពថ្មី មានដូច្នេះ គឺ.-

តី. ន. ទ. ប. វិ. ស. ណ. វោ. ជ. ជ. ជ. ជ. ជ. ត. ត. ភ. ចុតិ. បដិ. ភ. ភ. ភ. ភ. (ភវង្គតចាកបដិសន្ធិទៅ ១៦ ដួង) ហើយជាភវង្គចលនៈ ភវង្គុបច្ឆេទៈ មនោទ្វារាវជ្ជនៈ ជវនៈសោយអារម្មណ៍ ហើយភវង្គបាតៈប្រព្រឹត្តទៅ។

## អធិប្បាយមរណាសន្នវិថី_បដិសន្ធិ

បណ្ដាសត្វទាំងឡាយ អ្នកនៅមិនទាន់អស់កិលេស កាលស្លាប់ហើយ ក៏នឹងត្រូវកើតទៀតដោយកម្លាំងនៃកម្មដែលនាំឱ្យកើត ៤ យ៉ាង មានគរុកម្មជាដើម កម្មណាមួយ កាលវិថីជិតស្លាប់មកដល់ហើយ សត្វនោះនឹងមានអារម្មណ៍ ៣ យ៉ាង គឺ កម្ម កម្មនិមិត្ត និងគតិនិមិត្តណាមួយជាបុណ្យ ឬបាបកើតឡើងក្នុងជវនវិថី ៥ ខណៈ តែបុណ្យ-បាប ៥ ខណៈនេះ មិនជាជនកកម្មឱ្យសត្វបដិសន្ធិក្នុងភពថ្មីទេ ព្រោះបុណ្យ-បាប ៥ ខណៈនោះ មានកម្លាំងខ្សោយ កើតឡើងទទួលអារម្មណ៍ តែមិនគ្រប់អង្គរបស់កម្មបថ ទើបមិនអាចនាំឱ្យកើតបាន ចំណែកបដិសន្ធិដែលកើតឡើងនោះ រមែងកើតឡើងដោយកម្លាំងរបស់បុណ្យ-បាប ដែលជាជនកកម្ម ៤ មានគរុកម្មជាដើមយ៉ាងណានីមួយ ដែលជាជវនៈដួងទី ៧ ប៉ុណ្ណោះ ដែលខ្លួនបានធ្វើទុកហើយ។

កាមចុតិ និងកាមបដិសន្ធិ បានដល់សត្វដែលកើតក្នុងកាមភូមិ ១១ កាលចុតិអំពីកាមភូមិនេះហើយ ក៏បដិសន្ធិក្នុងកាមភូមិ ១១ ទៀត (កើតក្នុងភូមិដដែល១) កាលពោលដោយវិថី មរណាសន្នវិថីនេះ រមែង

ប្រព្រឹត្តទៅបានទាំងបញ្ចទ្វារវិថី និងមនោទ្វារវិថី។ កាលអារម្មណ៍ប្រាកដតាមបញ្ចទ្វារវិថី សត្វនោះក៏នឹងស្លាប់តាមបញ្ចទ្វារវិថី បើអារម្មណ៍មកប្រាកដតាមមនោទ្វារ សត្វនោះក៏ស្លាប់តាមមនោទ្វារវិថី។ កាលពោលដោយជវនៈ ក៏ជាកាមជវនៈ ៥ ខណៈ គឺ ជាលោភជវនៈ ទោសជវនៈ មោហជវនៈ ឬជាមហាកុសលញ្ញាណវិប្បយុត្ត ៤ ជាមហាកុសលញ្ញាណ-សម្បយុត្ត ៤ ស្រេចហើយតែកុសល ឬអកុសលដែលកើតឡើង។

ក្នុងកាមចុតិ ដែលមានអារម្មណ៍ជាអតិមហន្តារម្មណ៍ផ្លូវបញ្ចទ្វារដែលជាវិថីជិតស្លាប់នេះ នឹងមានវិថីកើតតាមលំដាប់ដូច្នេះ គឺ ភវង្គដើម និងភវង្គចុងនៃអតិមហន្តារម្មណ៍នោះ បានដល់ កាមភវង្គ ១០ ដួង។ កាលភវង្គដើមវិថីរលត់ហើយ បញ្ចទ្វារាវជ្ជនៈក៏កើតប្រព្រឹត្តទៅតាមលំដាប់រហូតដល់ចុតិចិត្តកើតឡើង។ កាលចុតិចិត្តរលត់ហើយ បដិសន្ធិក៏កើតឡើង ១ ខណៈ បន្ទាប់មកភវង្គក៏កើតជាប់តគ្នាទៅរហូតដល់ភវង្គុបច្ឆេទៈតអំពីនោះ ចិត្តនឹងឡើងកាន់មនោទ្វារវិថី កាលវិថីដំបូង គឺ មនោទ្វារា-វជ្ជនៈរលត់ហើយ ភវនិកន្តិលោភជវនៈក៏នឹងស្ទុះទៅក្នុងអារម្មណ៍ ហើយចិត្តក៏ប្រព្រឹត្តទៅក្នុងភវង្គ។

ក្នុងអតិមហន្តារម្មណ៍ ដែលមាននិមិត្តជាបច្ចុប្បន្នអារម្មណ៍ ចុតិចិត្តនឹងរលត់ទៅព្រមជាមួយនិមិត្តដែលជាបច្ចុប្បន្នអារម្មណ៍ ពេលចុតិរលត់ហើយ បដិសន្ធិក្នុងភពថ្មី ក៏ទទួលយកបច្ចុប្បន្នអារម្មណ៍ដែលរលត់ទៅហើយ ជាអារម្មណ៍តទៅ សូម្បីភវង្គ និងចុតិចិត្តតទៅ ក៏មានអារម្មណ៍

ដូចគ្នានឹងបដិសន្ធិនោះឯង។ ចំណែកមនោទ្វារវិថី ភវង្គកន្លិលោភជវនៈ ក្នុងភពថ្មីនោះ ចាប់យកនាម-រូបដែលកើតឡើង មានសេចក្ដីពេញចិត្តក្នុង អត្តាដែលកើតឡើងជាអារម្មណ៍។ វិថីនេះ បដិសន្ធិ និងភវង្គ មាន អារម្មណ៍ជាអតីតៈ។ ចំណែកវត្ថុដែលជាទីអាស្រ័យកើតឡើងរបស់ចិត្ត នោះ រមែងអាស្រ័យហទយវត្ថុរូបដែលកើតឡើងក្នុងឧបាទខណៈរបស់ បុរិមចិត្ត គឺចិត្តដួងមុននោះឯង។

## សភាពមរណាសន្នវិថីទី ២

សភាពមរណាសន្នវិថីទី ២ អតិមហន្តារម្មណ៍ផ្លូវបញ្ចទ្វារវិថីដែល មានកម្មនិមិត្ត ឬគតិនិមិត្តជាបច្ចុប្បន្នអារម្មណ៍ ដោយចាប់ផ្ដើមតាំងអំពី អតីតភវង្គ និងភវង្គចលនៈជាដើម ប្រព្រឹត្តទៅរហូតដល់ចុតិចិត្តរលត់ ហើយ តែអារម្មណ៍នោះនៅប្រាកដនៅឡើយ បដិសន្ធិចិត្តក៏កើតឡើង ទទួលអារម្មណ៍នោះជាបន្ត បដិសន្ធិចិត្តនេះទើបមានអារម្មណ៍ជាបច្ចុប្បន្ន។

ក្នុងអភិធម្មត្ថសង្គហៈ ពោលថា.-

**យទា បច្ចុប្បន្នាលម្ពណេសុ អាបាថមាគតេសុ ធរន្តេស្វេវ មរណំ ហោតិ តទា បដិសន្ធិភវង្គានម្បិ បច្ចុប្បន្នារម្មណតា លព្ភតិ។** ប្រែថា ក្នុង កាលណា បច្ចុប្បន្នអារម្មណ៍មកកាន់គន្លង ហើយប្រាកដនៅនោះឯង មានការស្លាប់ក្នុងកាលនោះ បដិសន្ធិនិងភវង្គរមែងបានបច្ចុប្បន្នអារម្មណ៍។ (ចំពោះកម្ម ជា អតីតអារម្មណ៍តែម្យ៉ាង)។

## វិថីទី ៣ អាគន្តុកចុតិ

អាគន្តុកចុតិ បានដល់វិថីចិត្តដែលមានអាគន្តុកភវង្គកើតមុនហើយទើបចុតិ។ ធម្មតាសត្វដែលបដិសន្ធិដោយកាមសោមនស្ស ៤ ដួង១ ណាមួយ កាលទទួលបញ្ចារម្មណ៍ដែលជាអតិឥដ្ឋារម្មណ៍ដែលល្អក្រៃលែង តែបុគ្គលអ្នកបដិសន្ធិមកដោយកាមសោមនស្សនេះ មិនកើតសេចក្តីរីករាយត្រឡប់ជាកើតទោសៈ ដូចពួកតិរ្ថិយមានមិច្ឆាទិដ្ឋិ ឃើញរូបព្រះសម្មាសម្ពុទ្ធ ដែលជាអតិឥដ្ឋារម្មណ៍ គួរនឹងសោមនស្សរីករាយ ក៏មិនរីករាយពេញចិត្ត ត្រឡប់ជាកើតទោសជវនៈ សេចក្តីខូចចិត្ត កាលទោសជវនៈកើតហើយ តទាលម្ពណៈសោមនស្ស ឬមូលភវង្គរបស់ខ្លួន ដែលជាកាម-សោមនស្សនោះ នឹងទទួលអារម្មណ៍តមិនបាន ព្រោះវេទនាជាបដិបក្ខនឹងគ្នាគឺជវនៈដួងទី ៥ នោះ ជាទោមនស្សវេទនា ចំណែកតទាលម្ពណៈនិងភវង្គដើមជាសោមនស្សវេទនា ក្នុងករណីនេះ នឹងត្រូវមានអាគន្តុកភវង្គ (ភវង្គដែលត្រាច់មក) កើតខ័ណ្ឌ ១ ខណៈមុនហើយ មូលភវង្គទើបកើតឡើង។ អាគន្តុកភវង្គនោះ បានដល់ កាមឧបេក្ខា ៦ គឺ ឧបេក្ខាអហេតុកសន្តីរណ-វិបាក ២ និងឧបេក្ខាកុសលវិបាក ៤។ វិថីចិត្តតាមបញ្ចទ្វារ ដែលមានអាគន្តុកភវង្គនេះ កើតបានទាំងអតិមហន្តារម្មណ៍ ទាំងមហន្តារម្មណ៍ កើតទាំងបវត្តិកាល ទាំងចុតិកាល តែក្នុងទីនេះ សម្ដែងចំពោះតែអាគន្តុកភវង្គដែលកើតជិតវេលាចុតិ ហៅថា អាគន្តុកចុតិ ដែលជាវិថីទី ៣ ដូច្នេះ គឺ.-

តី. ន. ទ. ប. វិ. ស. ណ. វោ. ជ. ជ. ជ. ជ. ជ. អាគន្តុកចុតិ.-បដិសន្ធិ.

ភវង្គដើមនិងភវង្គចុងវិថី ជាកាមសោមនស្ស ៤ ដួង ជវនៈ ៥ ដួង ជាទោសជវនៈ ពេលជវនៈដួងទី ៥ រលត់ហើយ ក៏ជាបច្ច័យឱ្យកើតអាគន្តុកភវង្គ ១ ខណៈ ហើយចុតិចិត្តទើបកើតឡើងធ្វើកិច្ច។ ចំណែកអារម្មណ៍ជិតស្លាប់ បើជាអតិមហន្តារម្មណ៍ និមិត្តដែលជាបច្ចុប្បន្នអារម្មណ៍កើតព្រមនឹងឧប្បាទខណៈរបស់អតីតភវង្គនោះ នឹងរលត់ចុះព្រមគ្នាជាមួយបឋមភវង្គដែលបដិសន្ធិក្នុងភពថ្មី ព្រោះក្នុងវិថីនេះ ជាទោសជវនៈ ៥ ខណៈ បុគ្គលនេះនឹងកើតក្នុងអបាយភូមិ បដិសន្ធិក្នុងភពថ្មីរបស់គេ នឹងជាឧបេក្ខាអហេតុកអកុសលវិបាកបដិសន្ធិ ១ ដួង។

## វិថីតាមបញ្ចទ្វារទី ៤

តី. ន. ទ. ប. វិ. ស. ណ. វោ. ជ. ជ. ជ. ជ. ជ. ចុតិ. បដិ. ភ.

វិថីនេះ ភវង្គដើមនិងភវង្គចុង ជាកាមភវង្គ ១០ ដួង។ ជវនៈ ៥ ជាមហាកុសល ៨, អកុសលចិត្ត ១២ ដួង។ និមិត្តបច្ចុប្បន្នអារម្មណ៍ ជិតស្លាប់ កើតព្រមនឹងអតីតភវង្គ ហើយទៅរលត់ចុះព្រមគ្នានឹងភវង្គក្រោយនៃបដិសន្ធិចិត្តក្នុងភពថ្មី។

## មរណាសន្នវិថីផ្លូវមនោទ្វារ

មរណាសន្នវិថីផ្លូវមនោទ្វាររបស់អ្នកចុតិចាកកាមភូមិ ១១ ហើយនឹងកើតក្នុងកាមភូមិ ១១ មាន ២ វិថី គឺ.-

១. វិភូតារម្មណ៍ (អារម្មណ៍ដែលប្រាកដច្បាស់)

២. អវិភូតារម្មណ៍ (អារម្មណ៍ដែលមិនប្រាកដច្បាស់)

មនោទ្វារវិថីទាំង ២ នោះ មានសភាពវិថី ៤ គឺ.-

១. ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ត. ត. ភ. ចុតិ-បដិសន្ធិ. ភ. ភ. ភ. ភ.

២. ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ត. ត. ចុតិ-បដិសន្ធិ. ភ.

៣. ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. អាគន្តុក ចុតិ-បដិសន្ធិ. ភ.

៤. ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ចុតិ-បដិសន្ធិ. ភ.

## កាមចុតិ-បដិសន្ធិក្នុងរូបព្រហ្ម ១៦

មានវិថីប្រព្រឹត្តទៅដូច្នេះ គឺ.-

ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ភ. ចុតិ-បដិសន្ធិ.

ពោលដោយវិថី ប្រព្រឹត្តទៅបានទាំងវិភូតារម្មណវិថី ទាំងអវិភូតារម្មណវិថី ។ ភវង្គ ជាតិហេតុកភវង្គ ។ ជវនៈ ៥ បានដល់មហាកុសលដែលជាកាមជវនៈ មិនមានតទាលម្ពណៈ ។ ជាធម្មារម្មណ៍តែម្យ៉ាង ។ ពោលដោយអារម្មណ៍និមិត្តជិតស្លាប់ មានបញ្ញត្តិកម្មនិមិត្តធម្មារម្មណ៍ មានកសិណជាដើម ជាអារម្មណ៍ ។ កាមចុតិ អរូបបដិសន្ធិក្នុងភូមិ ៤ ក៏ន័យនេះឯង ចំណែក ដែលផ្សេងគ្នាមានបន្តិចបន្តួច ។

## ព្រហ្មចុតិ-ព្រហ្មបដិសន្ធិ

រូបព្រហ្ម, អរូបព្រហ្ម អស់កម្មហើយក៏ត្រូវចុតិ បើនឹងបដិសន្ធិក្នុងព្រហ្មនោះៗ ទៀត រមែងប្រព្រឹត្តទៅតាមហេតុបច្ច័យ ក្នុងជវនៈ ៥ ក៏ជាកាមជវនៈតាមដែលពោលហើយនោះឯង ។

## រូបាវចរចុតិ_កាមបដិសន្ធិ

រូបព្រហ្ម (វៀរសុទ្ធាវាសភូមិ ៥) ចុតិចាកព្រហ្មភូមិហើយ នឹងបដិសន្ធិក្នុងកាមភូមិ ៧ ដោយមហាវិបាក ៨ ដួង១ ណាមួយ។ ភវង្គប្រព្រឹត្តទៅតាមគួរដល់ភូមិ។ មរណាសន្នវិថី រមែងកើតបានទាំងតាមបញ្ចទ្វារ និងមនោទ្វារវិថី។ ជវនៈ ៥ ខណៈ ជាកាមជវនៈ ដូចគ្នានឹងកាមបុគ្គល ដែលចុតិហើយបដិសន្ធិក្នុងកាមភូមិនោះឯង។ វិថីតាមចក្ខុទ្វារ និងសោតទ្វារមានសភាពដូច្នេះ គឺ.-

តី. ន. ទ. បញ្ច. វិ. ស. ណ. វោ. ជ. ជ. ជ. ជ. ជ. ភ. ចុតិ-បដិសន្ធិ.

តី. ន. ទ. បញ្ច. វិ. ស. ណ. វោ. ជ. ជ. ជ. ជ. ជ. ចុតិ-បដិសន្ធិ.

**វិថីតាមមនោទ្វារ គឺ.-**

ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ភ. ចុតិ-បដិសន្ធិ.

ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ចុតិ-បដិសន្ធិ.

អរូបព្រហ្មចុតិត្រឡប់មកបដិសន្ធិក្នុងកាមភូមិ ៧ ទៀត វិថីចិត្តជាមនោទ្វារប៉ុណ្ណោះ ក្រៅអំពីនោះមានសភាពដូចចុតិរបស់រូបព្រហ្មនោះឯង។ បដិសន្ធិដោយមហាវិបាកញាណសម្បយុត្ត ៤ ដួង១ ណាមួយ។

## ព្រះអរហន្តចុតិ ៥ ន័យ មិនមានបដិសន្ធិ

១. កាមជវនមរណាសន្នវិថី មរណាសន្នវិថី តអំពីកាមជវនៈ។

២. ឈានសមនន្តរវិថី មរណាសន្នវិថី តអំពីឈាន។

៣. បច្ចវេក្ខណសមនន្តរវិថី មរណាសន្នវិថី តអំពីការ

ពិចារណាអង្គឈាន។

៤. អភិញ្ញាសមនន្តរវិថី មរណាសន្នវិថី តអំពីអភិញ្ញាវិថី។

៥. ជីវិតសមសីសីវិថី មរណាសន្នវិថី តអំពីការពិចារណាមគ្គផលនិព្វាន និងកិលេសដែលលះហើយ។ វិថីចិត្តរមែងប្រព្រឹត្តទៅតាមមនោទ្វារតែមយ៉ាង គឺ.-

វិភូតារម្មណ៍វិថី ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ត. ត. ភ. ចុតិ.

អវិភូតារម្មណ៍ ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ភ. ចុតិ.

និង ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ចុតិ.

ព្រះអរហន្តក្នុងកាមភូមិចុតិ អារម្មណ៍ក្នុងមរណាសន្នវិថី ៥ ខណៈជាមហាកិរិយាចិត្ត ៤ ពិចារណានាមរូបជាត្រៃល័ក្ខណ៍។ វត្ថុដែលអាស្រ័យកើតរបស់ចិត្ត បានដល់ ហទយវត្ថុដែលកើតឡើងព្រមគ្នានឹងឧប្បាទចិត្តដួងទី ១៧ រាប់ថយក្រោយអំពីចុតិចិត្ត។

មរណាសន្នវិថី តអំពីឈាន គឺ.-

ភ. ន. ទ. ម. បរិ. ឧប. អនុ. គោ. ណ. ណ. ណ. ណ. ណ. ភ. ចុតិ.

ក្នុងវិថីនេះ ភវង្គមុខ និងក្រោយ ជាតិហេតុកភវង្គ។ កាមជវនៈមុខមហគ្គតកិរិយា បើជាតិក្ខបុគ្គល កើត ៣ ខណៈ បើជាមន្ទបុគ្គល កើត ៤ ខណៈ។ វិថីមួយទៀត មិនមានភវង្គ។

មរណាសន្នវិថី តអំពីបច្ចវេក្ខណវិថី គឺការពិចារណាអង្គឈានព្រះអរហន្តឈានលាភី ចេញចាកឈានសមាបត្តិហើយ ក៏ពិចារណាអង្គ

ឈាន ពេលបច្ចវេក្ខណៈដួងទី ៥ រលត់ហើយ ភវង្គកើតឡើង ១ ខណៈ ឬមិនមានភវង្គកើតឡើងក៏ដោយ ចុតិចិត្តក៏កើតឡើងធ្វើចុតិ កិច្ច។ បច្ចវេក្ខណៈ ជាកាមវិថី។ ប្រព្រឹត្តទៅ ២ វិថី ដូច្នេះ គឺ.-

**មនោទ្វារវិថី** ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ភ. ចុតិ.

ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ចុតិ.

មរណាសន្នវិថី តអំពីអភិញ្ញាវិថី ជាវិថីចិត្តរបស់ព្រះអរហន្តឈានលាភីអ្នកបានអភិញ្ញា លោកសំដែងអភិញ្ញាមុនហើយបរិនិព្វាន មាន ២ វិថី គឺ.-

**មនោទ្វារវិថី** ភ. ន. ទ. ម. បរិ. ឧប. អនុ. គោ. កិរិយាអភិញ្ញា. ភ. ចុតិ.

ភ. ន. ទ. ម. បរិ. ឧប. អនុ. គោ. កិរិយាអភិញ្ញា. ចុតិ.

មរណាសន្នវិថី តអំពីបច្ចវេក្ខណៈ ជាវិថីចិត្តរបស់ព្រះអរហន្តដែលជា **ជីវិតសមសីសី**។ ក្នុងគម្ពីរបុគ្គលប្បញ្ញត្តិ ពោលទុកថា "ការអស់ទៅនៃអាសវៈ និងការអស់ទៅនៃជីវិត មានមិនមុន មិនក្រោយគ្នា បុគ្គលនេះ ហៅថា **សមសីសី** មាន ៣ ប្រភេទ គឺ ឥរិយាបថសមសីសី ១ រោគសមសីសី ១ និងជីវិតសមសីសី ១"។ មរណាសន្នវិថីរបស់ព្រះអរិយបុគ្គលជាជីវិតសមសីសី តអំពីមគ្គវិថី បានដល់បច្ចវេក្ខណវិថី ពិចារណា មគ្គ ផល និព្វាន និងកិលេសដែលលះហើយ មានសភាពដូច្នេះ គឺ.-

**មគ្គវិថី** ភ. ន. ទ. ម. បរិ. ឧប. អនុ. គោ. មគ្គ. ផ. ផ. ភ. ភ. ភ.

**បច្ចវេក្ខណវិថី** ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ភ. ចុតិ.

និង ភ. ន. ទ. ម. ជ. ជ. ជ. ជ. ជ. ចុតិ.

ចប់មរណាសន្នវិថីដោយសង្ខេប ។

# តទាលម្ពណនិយម

តទាលម្ពណនិយម បានដល់ការកំណត់អារម្មណ៍របស់តទា-លម្ពណៈ។ គឺវិបាកចិត្តទាំង ១១ ដួងនេះ គឺ ឧបេក្ខាសន្តីរណអកុសល-វិបាក ១ ដួង ឧបេក្ខាសន្តីរណកុសលវិបាក ១ ដួង សោមនស្សសន្តីរណ-កុសលវិបាក ១ ដួង និងមហាវិបាក ៨ ដួង រួមគ្នាត្រូវជា ១១ ដួងទាំងនេះ ទទួលអារម្មណ៍តាមបញ្ចទ្វារវិថី និងមនោទ្វារវិថី ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៣ យ៉ាង គឺ.-

១. អនិដ្ឋារម្មណ៍ អារម្មណ៍មិនល្អ ដែលជាអកុសលវិបាក

២. ឥដ្ឋារម្មណ៍ អារម្មណ៍ល្អ ដែលជាកុសលវិបាក

៣. អតិឥដ្ឋារម្មណ៍ អារម្មណ៍ល្អក្រៃលែង ដែលជាកុសលវិបាក។

ពេល **អនិដ្ឋារម្មណ៍** ប្រាកដហើយ ឧបេក្ខាអកុសលវិបាកចិត្តទាំងនេះ គឺ បញ្ចវិញ្ញាណ, សម្បដិច្ឆន្នចិត្ត, សន្តីរណចិត្ត និងតទាលម្ពណចិត្ត កើតឡើងទទួលអារម្មណ៍ ដែលមិនល្អនោះ។ កាល **ឥដ្ឋារម្មណ៍** ប្រាកដហើយ ឧបេក្ខាកុសលវិបាកចិត្តទាំងនេះ គឺ បញ្ចវិញ្ញាណ, សម្បដិច្ឆន្នចិត្ត, សន្តីរណចិត្ត និងតទាលម្ពណចិត្ត កើតឡើងទទួលអារម្មណ៍ ដែលល្អនោះ តែតទាលម្ពណៈដែលជាកុសលវិបាកមាន ៥ គឺ ឧបេក្ខាសន្តីរណកុសល-វិបាក ១ និងមហាវិបាក ៤ ដែលកើតព្រមជាមួយឧបេក្ខា។

ពេល **អតិឥដ្ឋារម្មណ៍** អារម្មណ៍ដែលល្អក្រៃលែង ប្រាកដហើយ ក៏មានវិបាកចិត្តដែលកើតឡើង ទទួលអារម្មណ៍ដែលល្អក្រៃលែងនោះ គឺ

កុសលវិបាកដែលកើតរួមនឹងឧបេក្ខា បានដល់បញ្ចវិញ្ញាណ និងសម្បដិច្ឆន្ន-ចិត្ត ចំណែកសន្តីរណៈ ជាសោមនស្សសន្តីរណចិត្ត និងតទាលម្ពណៈ ៥ ដួង១ ណាមួយ គឺ សោមនស្សសន្តីរណចិត្ត ១ និងសោមនស្សមហាវិបាក ៤ ដួង កើតឡើងធ្វើតទាលម្ពណកិច្ច ។ ក្នុងសង្គហគាថា លោកពោលការ កំណត់តទាលម្ពណៈទុកថា.-

**៧. កាមេ ជវនសត្តាល- ម្ពណានំ និយមេ សតិ**

**វិភូតេតិមហន្តេ ច តទាលម្ពណមីរិតំ ។**

កាលការកំណត់ជវនៈ សត្វ (បុគ្គល) និងអារម្មណ៍ មាននៅក្នុង កាមភូមិ លោកទើបពោលតទាលម្ពណៈទុក ក្នុងវិភូតារម្មណ៍ និងអតិម-ហន្តារម្មណ៍ ។

ក្នុងសង្គហគាថានេះសំដែងថា តទាលម្ពណៈនឹងកើតបាន ត្រូវ ប្រកបដោយអង្គ ៤ គឺ.-

១. ជវនៈ ជាកាមជវនៈ

២. សត្វ ជាកាមសត្វ

៣. អារម្មណ៍ ជាកាមអារម្មណ៍

៤. វិថី ជាវិភូតារម្មណ៍ ឬអតិមហន្តារម្មណ៍ ។

ពាក្យថា **ជវនៈ** បានដល់កាមជវនៈ ក្នុងបញ្ចទ្វារវិថី និងមនោទ្វា-រវិថី មិនមែនលោកិយអប្បនាជវនៈ និងលោកុត្តរអប្បនាជវនៈទេ។ ពាក្យ ថា **សត្វ** បានដល់បុគ្គលអ្នកកើតក្នុងកាមភូមិប៉ុណ្ណោះ មិនមែនអ្នកកើតក្នុង

ព្រហ្មភូមិទេ។ ពាក្យថា **អាលម្ពណៈ** បានដល់កាមអារម្មណ៍ដែលជាបរមត្ថ មិនមែនជាបញ្ញត្តិអារម្មណ៍មហគ្គតអារម្មណ៍និងលោកុត្តរអារម្មណ៍ឡើយ។ ពាក្យថា **វិធី** បានដល់វិភូតារម្មណ៍ដែលកើតតាមមនោទ្វារវិថីនិងអតិមហន្តារម្មណ៍តាមបញ្ចទ្វារវិថី កាលគ្រប់អង្គ ៤ នេះ តទាលម្ពណៈរមែងកើតឡើង។ តែក្នុងករណីខ្លះ តទាលម្ពណៈបានអង្គ ៤ ហើយក៏កើតឡើងមិនបាន ព្រោះសេចក្តីវិបល្លាសរបស់សត្វទាំងឡាយ។ ដូចពួកតិរ្ថិយខ្លះដែលបដិសន្ធិដោយកាមសោមនស្ស ៤ ដួង ឃើញព្រះឆវីវណ្ណ ឬបានស្តាប់ព្រះសូរសៀងរបស់ព្រះមានព្រះភាគហើយ ត្រឡប់ជាកើតទោសៈក្នុងជវនៈទើបជាទោសជវនៈ។

ក្នុងករណីនេះ តទាលម្ពណៈដែលជាកាមសោមនស្សនោះ នឹងកើតតអំពីទោសជវនៈមិនបាន ព្រោះវេទនាជាបដិបក្ខនឹងគ្នា ទាំងមូលភវង្គរបស់គេក៏កើតមិនបាន ដោយហេតុនោះ ទើបមានអាគន្តុកភវង្គកើតឡើងជាអនន្តរប្បច្ច័យឱ្យមូលភវង្គកើតតទៅ។

## អាគន្តុកភវង្គវិធី

**អតិមហន្តារម្មណ៍ ដែលមានអាគន្តុកភវង្គ គឺ.-**

តី. ន. ទ. បញ្ច. វិ. ស. ណ. វោ. ជ. ជ. ជ. ជ. ជ. ជ. ជ. អា. ភ.

**មហន្តារម្មណ៍ ដែលមានអាគន្តុកភវង្គ គឺ.-**

តី. ន. ទ. បញ្ច. វិ. ស. ណ. វោ. ជ. ជ. ជ. ជ. ជ. ជ. ជ. អា. ភ.

**អធិប្បាយៈ** ភវង្គមុខនិងភវង្គក្រោយជាកាមសោមនស្ស ៤។

អារម្មណ៍ ជាអតិឥដ្ឋារម្មណ៍។ ជវនៈ ជាទោសជវនៈ តទាលម្ពណៈកើត មិនបាន។ ក្នុងអភិធម្មត្ថសង្គហៈពោលទុកថា "ក្នុងកាលនោះ ឧបេក្ខា-សន្តីរណចិត្ត រមែងប្រារព្ធយកកាមអារម្មណ៍ណាមួយ ដែលធ្លាប់សន្សំទុក កើតឡើង" ដូច្នេះ សំដៅយកអាគន្តុកភវង្គ (ភវង្គដែលត្រាច់មក) មិនមែនភវង្គដើម (មូលភវង្គ) ទេ អាគន្តុកភវង្គនេះ រមែងទទួលអារម្មណ៍ ៦ ទាក់ទងនឹងកាមារម្មណ៍ណាមួយ ដែលជំនាញហើយតាំងពីអតីតភព កើតឡើងធ្វើកិច្ច ដើម្បីឱ្យចិត្តជាអនន្តរប្បច្ច័យ បានដល់ឧបេក្ខាសន្តីរណ-កុសលវិបាក និងឧបេក្ខាមហាវិបាកដួងណាមួយ កើតមុនហើយ ភវង្គដើម ទើបកើតបាន។ ក៏អាគន្តុកភវង្គ រមែងកើតក្នុងកាមសុគតិភូមិ ៧ ក្នុង បុគ្គល ៤ ចំពូក គឺ ទ្វិហេតុកបុគ្គល ១ តិហេតុកបុគ្គល ១ ព្រះសោតាបន្នបុគ្គល ១ និងព្រះសកទាគាមិបុគ្គល ១។ អាគន្តុកភវង្គ មិនកើតក្នុងទុគ្គតិបុគ្គល និង សុគតិបុគ្គល ព្រោះបដិសន្ធិដោយអហេតុក-បដិសន្ធិ និងមិនកើតដល់ព្រះ អនាគាមី ព្រះអរហន្ត ព្រោះមិនមាន ទោសជវនៈ។

ចប់តទាលម្ពណនិយម។



# ជវននិយម

ជវននិយម បានដល់ការកំណត់ជវនចិត្ត។ ដោយសង្ខេប ជវនចិត្ត មាន ៥៥ ដួង គឺ កាមជវនៈ ២៩ មហគ្គតជវនៈ ១៨ លោកុត្តរជវនៈ ៨ (ដោយពិស្តារ ៤០)។ បណ្តាជវនៈទាំងនោះ ជវនៈក្នុងកាមវិថី ដោយប្រក្រតី ស្ទុះទៅ ៧ ខណៈ តែក្នុងវេលាប្រព្រឹត្តទៅនៃជវនចិត្ត ដែលមានកម្លាំងខ្សោយ ព្រោះហទយវត្ថុខ្វះកម្លាំង មានក្នុងវេលាជិតស្លាប់ជាដើម ខណៈនោះកើតបាន ៥ ខណៈខ្លះ ៦ ខណៈខ្លះ ក្នុងវេលាដែលព្រះមានព្រះភាគទ្រង់សម្តែងយមកប្បាដិហារ្យ ចូលឈានជាបាទជាផ្នែក១ ចេញចាកឈានដែលជាបាទ នឹកគិតដល់ឈានធមិ តែម្យ៉ាង១ ដើម្បីឱ្យធារទឹក និងទភ្លើងប្រព្រឹត្តទៅ ខណៈនោះ បច្ចវេក្ខណជវនចិត្ត កើតឡើង ៤ ឬ ៥ ខណៈ។ ក្នុងមហគ្គតជវនៈដែលបន្ទុះឈាន (អាទិកម្មិកឈានវិថី) គ្រប់១ ឈាន មហគ្គតជវនៈកើតតែ ១ ខណៈ។ ក្នុងអភិញ្ញាវិថី ជាកុសលជវនៈ ឬកិរិយាជវនៈក្តី ក្នុងមគ្គវិថីទាំង ៤ ក្តី ជវនៈក៏កើតឡើងតែ ១ គ្រា។ ក្នុងលោកុត្តរវិបាក ជវនៈកើតឡើង ២-៣ ខណៈ។ ក្នុងពេលមុនចូលនិរោធសមាបត្តិ អរូបឈានទី ៤ កើតឡើង ២ ខណៈ ក្នុងវេលាចេញចាកនិរោធសមាបត្តិ ផលចិត្តរបស់លោកកើតឡើង ១ ខណៈ។ តែក្នុងផលសមាបត្តិក្តី ក្នុងឈានសមាបត្តិក្តី ជវនចិត្តរមែងកើតរាប់ប្រមាណមិនបាន មិនមានការកំណត់ជវនវិថី ដូចក្រសែនៃភវង្គដែលប្រព្រឹត្តទៅ។ ក្នុងគាថាសម្តែងទុកថា.-

## សង្គហគាថា

៨. សត្តក្ខត្តុំ បរិត្តានិ  មគ្គាភិញ្ញា សកឹ មតា
អវសេសានិ លព្ភន្តិ  ជវនានិ ពហូនិបិ ។

កាមាវចរជវនៈ បណ្ឌិតពោលទុក ៧ គ្រា មគ្គជវនៈ និងអភិញ្ញា-ជវនៈ ពោលទុកតែ ១ គ្រា តែជវនៈដែលនៅសល់ រមែងកើតបានសូម្បីច្រើន។

## សម្ដែងការកើតជវនៈដោយពិស្ដារ

**ជវនចិត្តកើត ១ ខណៈ បានដល់ចិត្ត ២៦ ដួង គឺ.-**

១. មហគ្គតកុសលជវនៈ ៩ ដួង ដែលកើតក្នុងអាទិកម្មិកឈានវិថី

២. មហគ្គតកិរិយាជវនៈ ៩ ដួង ដែលកើតក្នុងអាទិកម្មិកឈានវិថី

៣. អភិញ្ញាជវនៈ  ២ ដួង ដែលកើតក្នុងអភិញ្ញាវិថី

៤. មគ្គជវនៈ  ៤ ដួង ដែលកើតក្នុងមគ្គវិថី

៥. អនាគាមិផលជវនៈ ១ ដួង ដែលកើតភ្លាមទាន់ពេលដែលចេញចាកនិរោធសមាបត្តិ

៦. អរហត្តផលជវនៈ ១ ដួង ដែលកើតភ្លាមទាន់ពេលដែលចេញចាកនិរោធសមាបត្តិ ។

**ជវនចិត្តកើតបាន ២ ខណៈ បានដល់ចិត្ត ៦ ដួង គឺ.-**

១. នេវសញ្ញានាសញ្ញា ២ ដួង កើតមុននិរោធសមាបត្តិ

២. ផលជវនចិត្ត  ៤ ដួង ក្នុងមគ្គ(វិថី) ៤ របស់មន្ទបុគ្គល

**ជវនចិត្តកើតបាន ៣ ខណៈ បានដល់ចិត្ត ១២ ដួង គឺ.-**

១. មហាកុសលញ្ញាណសម្បយុត្តជវនៈ ៤ ដួង កើតក្នុងអប្បនាវិថីរបស់តិក្ខបុគ្គល

២. មហាកិរិយាញ្ញាណសម្បយុត្តជវនៈ ៤ ដួង កើតក្នុងអប្បនាវិថីរបស់តិក្ខបុគ្គល

៣. ផលជវនៈ ៤ ដួង កើតក្នុងមគ្គវិថីរបស់តិក្ខបុគ្គល ។

**ជវនចិត្តកើតបាន ៤ ខណៈ បានដល់ចិត្ត ៨ ដួង គឺ.-**

១. មហាកុសលញ្ញាណសម្បយុត្តជវនៈ ៤ ដួង កើតក្នុងវិថីរបស់មន្ទបុគ្គល មាននាទីជាឧបចារៈ

២. មហាកិរិយាញ្ញាណសម្បយុត្តជវនៈ ៤ ដួង កើតក្នុងវិថីរបស់មន្ទបុគ្គល មាននាទីជាឧបចារៈ ។

ក្នុងគ្រាធ្វើយមកប្បាដិហារ្យ អដ្ឋកថាចារ្យពោលថា បច្ចវេក្ខណចិត្តរបស់ព្រះមានព្រះភាគកើតឡើង ៤-៥ ខណៈ ។ ក្នុងព្រះដីកាចារ្យពោលថា ៤ ខណៈរបស់ព្រះមានព្រះភាគ ៥ ខណៈរបស់ព្រះអរិយៈអ្នកជំនាញ មានព្រះសារីបុត្រជាដើម ។

**ជវនចិត្តកើតបាន ៥ ខណៈ បានដល់ចិត្ត ២៨ ដួង គឺ.-**

កាមជវនចិត្ត ២៨ ដែលកើតក្នុងមរណាសន្នវិថី (វេរ្យហសិតុប្បាទ) ។

កន្លែងខ្លះពោលថា ជវនចិត្ត ដែលកើតក្នុងមរណាសន្នកាល

(វេលាជិតស្លាប់) ក្នុងមុច្ឆាកាល (វេលាវង្វេង) ក្នុងវិសញ្ញីភូតកាល (វេ-លាសន្លប់) អតិតរុណកាល (វេលាដែលកម្មជរូបមានកម្លាំងខ្សោយ គឺខណៈកើតដំបូង) រួម ៤ កាលនេះ ជវនចិត្ត កើតបាន ៥ ខណៈ ។

**ជវនចិត្តកើតបាន ៦ ខណៈ** បានដល់ កាមចិត្ត ដែលកើតឡើងក្នុងវេលាសន្លប់ ឬក៏អាចកើតបានក្នុងវេលារាងកាយចុះខ្សោយអស់កម្លាំងមិនប្រក្រតី ។

**ជវនចិត្តកើតបាន ៧ ខណៈ** បានដល់កាមជវនចិត្ត ២៩ ដួង ។

**ជវនចិត្តកើតបានច្រើនជាង ៧ ខណៈ** បានដល់ចិត្ត ២២ ដួង គឺ.-

១. មហគ្គតកុសលជវនៈ ៩ ដួង ក្នុងវេលាចូលឈានសមាបត្តិ

២. មហគ្គតកិរិយាជវនៈ ៩ ដួង ក្នុងវេលាចូលឈានសមាបត្តិ

៣. ផលចិត្ត ៤ ដួង ក្នុងវេលាចូលផលសមាបត្តិ

ចប់ជវននិយម ។

## ចែកវិថីចិត្តតាមប្រភេទបុគ្គល

ពេលនេះ ជាការកំណត់វិថីចិត្តរបស់បុគ្គល ១២ ប្រភេទ តាម ដែលកើតបាន និងវៀរចិត្តដែលកើតមិនបាន ក្នុងបុគ្គលទាំងនោះ ដោយសង្ខេបតទៅ ។

បុគ្គលទាំងអស់ ១២ ពួក គឺ **បុថុជ្ជន ៤ ពួក** បានដល់ អបាយិក-អហេតុកបុគ្គល ១ សុគតិអហេតុកបុគ្គល ១ ទុហេតុកបុគ្គល ១ តិហេតុកបុគ្គល ១ **ព្រះអរិយបុគ្គល ៨ ពួក** គឺ បុគ្គលអ្នកតាំងនៅក្នុងមគ្គមាន ៤ ពួក និងបុគ្គលអ្នកតាំងនៅក្នុងផលមាន ៤ ពួក រួមជា ១២ ពួក ។

## អធិប្បាយបុគ្គល ១២

១. **អបាយិកអហេតុកបុគ្គល** បានដល់បុគ្គលដែលបដិសន្ធិដោយឧបេក្ខាសន្តីរណអកុសលវិបាក មាន ១ ដួងដែលកើតក្នុងអបាយភូមិ ៤ គឺ នរក ប្រេត អសុរកាយ និងសត្វតិរច្ឆាន ។

២. **សុគតិអហេតុកបុគ្គល** បានដល់បុគ្គលដែលបដិសន្ធិ ដោយឧបេក្ខាសន្តីរណកុសលវិបាក ១ ដួង ជាអ្នកមានបុណ្យតិច កើតក្នុងមនុស្សភូមិ និងក្នុងសួគ៌ជាន់ចាតុម្មហារាជិកា ជាអ្នកពិការរាងកាយ និងចិត្ត មានការឆ្កួត គ ខ្វាក់ ថ្លង់តាំងអំពីកំណើតជាដើម ។

៣. **ទ្វិហេតុកបុគ្គល** បានដល់ បុគ្គលអ្នកបដិសន្ធិដោយមហាវិបា-កញ្ញាណវិប្បយុត្ត ៤ ដួង ក្នុងកាមសុគតិភូមិ ៧ ជាអ្នកមិនមានបញ្ញា មិនអាចធ្វើឈានអភិញ្ញា មគ្គ ផល និព្វានឱ្យកើតបានឡើយ ។

៤. **តិហេតុកបុគ្គល** បានដល់ បុគ្គលអ្នកបដិសន្ធិដោយ វិបាកចិត្ត ១៣ ដួង គឺ មហាវិបាកញ្ញាណសម្បយុត្ត ៤ ដួង កើតក្នុងកាមសុគតិ ៧ និងមហគ្គតវិបាក ៩ ដួងដែលកើតក្នុងរូបភូមិ ១០ ភូមិ និងអរូបភូមិ ៤ រួមជា ១៣ ដួង ជាអ្នកមានបុណ្យច្រើន ។

៥. **សោតាបត្តិមគ្គបុគ្គល** បានដល់បុគ្គលអ្នកតាំងនៅក្នុងមគ្គ ត្រឹមតែមួយខណៈចិត្តប៉ុណ្ណោះ បន្ទះជាព្រះអរិយបុគ្គលបានក្នុងកាមសុគតិភូមិ ៧ និងក្នុងរូបភូមិ ១០ ( វៀរអសញ្ញសត្តាភូមិ និងសុទ្ធាវាសភូមិ ៥ ) ។

៦. **សោតាបត្តិផលបុគ្គល** បានដល់បុគ្គលអ្នកបន្ទះជាព្រះសោតាបន្នបានក្នុងភូមិ ២១ គឺ កាមសុគតិភូមិ ៧ រូបភូមិ ១០ ( វៀរអសញ្ញសត្តាភូមិ និងសុទ្ធាវាសភូមិ ) និងក្នុងអរូបភូមិ ៤ ។

| | |
|---|---|
| ៧. **ព្រះសកទាគាមិមគ្គបុគ្គល** | រួមទាំង ៣ ពួក រមែងបន្ទះជាព្រះ |
| ៨. **ព្រះសកទាគាមិផលបុគ្គល** | អរិយបុគ្គលបានក្នុងភូមិ ២១ដូចគ្នា |
| ៩. **ព្រះអនាគាមិមគ្គបុគ្គល** | នឹងព្រះសោតាបត្តិផលបុគ្គលនោះឯង ។ |

១០. **ព្រះអនាគាមិផលបុគ្គល** បានដល់បុគ្គលអ្នកបន្ទះជាព្រះអរិយៈបានក្នុងភូមិ ២៦ គឺ ក្នុងកាមសុគតិភូមិ ៧ រូបព្រហ្មភូមិ ១៥ ( វៀរអសញ្ញសត្តាភូមិ) និងក្នុងអរូបព្រហ្មភូមិ ៤ ។

| | |
|---|---|
| ១១. **ព្រះអរហត្តមគ្គបុគ្គល** | រមែងបន្ទះបាន ២៦ ភូមិ ដូចគ្នានឹង |
| ១២. **ព្រះអរហត្តផលបុគ្គល** | ព្រះអនាគាមិផលបុគ្គលនោះឯង ។ |

ក៏ក្នុងវិថីសង្គហៈនេះ គប្បីជ្រាបថា កិរិយាជវនវិថី រមែងមិនមាន

ដល់អហេតុកបុគ្គល និងទ្វិហេតុកបុគ្គលទេ។ម្យ៉ាងទៀត មហាវិបាកចិត្ត (តទាលម្ពណចិត្ត) ដែលប្រកបដោយញ្ញាណ (បញ្ញា) រមែងមិនមានដល់សុគតិអហេតុកបុគ្គលទេ។ មហាវិបាកចិត្ត (តទាលម្ពណចិត្ត) ដែលជាញ្ញាណវិប្បយុត្ត ក៏រមែងមិនមានដល់ទុគ្គតិអហេតុកបុគ្គលដែរ។

ម្យ៉ាងទៀត បណ្ដាតិហេតុកបុគ្គលទាំងឡាយ ព្រះខីណាស្រព រមែងមិនមានកុសលជវនៈ និងអកុសលជវនៈ។ ក៏កិរិយាជវនៈ រមែងមិនមានដល់ព្រះសេក្ខៈ និងបុថុជ្ជន។ បដិឃជវនៈ រមែងមិនកើតដល់ព្រះអនាគាមី។ លោកុត្តរជវនៈ រមែងកើតដល់ព្រះអរិយបុគ្គលប៉ុណ្ណោះតាមសមគួរដល់ខ្លួន។

## សង្គហគាថា

*៩. អសេក្ខានំ ចតុច្ចត្តា- ឡីស សេក្ខានមុទ្ទិសេ*
*ឆប្បញ្ញាសាវសេសានំ ចតុប្បញ្ញាស សម្ភវា។*

បណ្ឌិត សម្ដែងវិថីចិត្ត របស់ព្រះអសេក្ខៈទុក ៤៤ ដួង របស់ព្រះសេក្ខៈ ៥៦ ដួង របស់បុគ្គលដែលសល់ ៥៤ ដួង តាមសមគួរដល់ការកើត។

អធិប្បាយក្នុងគាថានេះ លោកសម្ដែងវិថីចិត្តរបស់បុគ្គល ៣ ពួក គឺ របស់ព្រះអសេក្ខបុគ្គល ១ ពួក របស់ព្រះសេក្ខបុគ្គល ១ ពួក និងរបស់បុថុជ្ជនទាំងអស់ ១ ពួកទៀត។ ម្យ៉ាងទៀត ក្នុងទីនេះ លោកមិនមានបំណងសម្ដែងវិថីមុត្តចិត្ត ដូច្នេះគប្បីជ្រាបវិថីចិត្តរបស់លោកទាំងនោះ ដូច

តទៅនេះ.-

១/ ព្រះអសេក្ខបុគ្គល ដែលជាកាមបុគ្គល គឺអ្នកកើតក្នុងកាមសុគតិភូមិ ទាំងដែលជាសមថយានិក ទាំងដែលជាវិបស្សនាយានិក មានវិថីចិត្តតាមដែលកើតបាន ៤៤ ដួងនោះគឺ.-

១. អហេតុកចិត្ត ១៨ ដួង

២. មហាកិរិយាចិត្ត ៨ ដួង

៣. មហាវិបាកចិត្ត ៨ ដួង

៤. មហគ្គតកិរិយាចិត្ត ៩ ដួង

៥. អរហត្តផលចិត្ត ១ ដួង

ចិត្តដែលសល់ ៤៥ ដួង ជាចិត្តផុតវិថី គឺ.-

១. អកុសលចិត្ត ១២ ដួង

២. កុសលចិត្ត ២១ ដួង

៣. ផលចិត្តផ្នែកទាប ៣ ដួង

៤. មហគ្គតវិបាកចិត្ត ៩ ដួង

២/ ព្រះសេក្ខៈ គឺ ព្រះសោតាបន្ន ព្រះសកទាគាមី និង ព្រះអនាគាមី មានវិថីចិត្តតាមគួរដល់ការកើត ៥៦ ដួង គឺ.-

១. អកុសលចិត្ត ៧ ដួង (វៀរទិដ្ឋិគតៈ ៤ វិចិកិច្ឆា ១)

២. អហេតុកចិត្ត ១៧ ដួង (វៀរហសិតុប្បាទៈ)

៣. មហាកុសលចិត្ត ៨ ដួង

៤. មហាវិបាកចិត្ត ៨ ដួង

៥. មហគ្គតកុសលចិត្ត ៩ ដួង

៦. លោកុត្តរចិត្ត ៧ ដួង (វៀរអរហត្តផល)

វៀរចិត្ត ៣៣ ដួង ដែលសល់កើតមិនបាន គឺ.-

១. កិរិយាជវនចិត្ត ១៨ ដួង

២. ចិត្តសហគតដោយទិដ្ឋិ ៤ ដួង

៣. វិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង

៤. អរហត្តផលចិត្ត ១ ដួង

៥. មហគ្គតវិបាកចិត្ត ៩ ដួង

*ដោយចែកប្រភេទបុគ្គល*

**ព្រះសោតាបន្ន និងព្រះសកទាគាមី មានវិថីចិត្ត**

៥០ ដួង គឺ.-

១. អកុសលចិត្ត ៧ ដួង វៀរទិដ្ឋិគតៈ ៤ វិចិកិច្ឆា ១

២. អហេតុកចិត្ត ១៧ ដួង

៣. មហាកុសលចិត្ត ៨ ដួង

៤. មហាវិបាកចិត្ត ៨ ដួង

៥. មហគ្គតកុសលចិត្ត ៩ ដួង

៦. សោតាបត្តិផល ឬ សកទាគាមិផល ១ ដួង

**វៀរចិត្តដែលសល់កើតមិនបាន ៣៩ ដួង គឺ.-**

១. លោភទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង

២. វិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង

៣. ហសិតុប្បាទចិត្ត ១ ដួង

៤. មហាកិរិយាចិត្ត ៨ ដួង

៥. មហគ្គតវិបាកចិត្ត ៩ ដួង

៦. មហគ្គតកិរិយាចិត្ត ៩ ដួង

៧. លោកុត្តរចិត្ត ៧ ដួង

**ព្រះអនាគាមី** មានវិថីចិត្តកើតបាន ៤៨ ដួង គឺ.-

១. លោភទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង

២. ឧទ្ធច្ចសម្បយុត្តចិត្ត ១ ដួង

៣. អហេតុកចិត្ត ១៧ ដួង

៤. មហាកុសលចិត្ត ៨ ដួង

៥. មហាវិបាកចិត្ត ៨ ដួង

៦. មហគ្គតកុសលចិត្ត ៩ ដួង

៧. អនាគាមិផលចិត្ត ១ ដួង

ចិត្តដែលសល់ ៤១ ដួង កើតមិនបាន គឺ.-

១. លោភទិដ្ឋិសម្បយុត្តចិត្ត ៤ ដួង

២. ទោសមូលចិត្ត ២ ដួង

៣. វិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង

៤. ហសិតុប្បាទចិត្ត ១ ដួង

៥. មហាកិរិយាចិត្ត ៨ ដួង

៦. មហគ្គតវិបាកចិត្ត ៩ ដួង

៧. មហគ្គតកិរិយាចិត្ត ៩ ដួង

៨. លោកុត្តរចិត្ត ៧ ដួង

៣/ បុគ្គល ៤ ប្រភេទ គឺ.-

តិហេតុកបុគ្គល មានវិថីចិត្តកើតបាន ៥៤ ដួង កើតមិនបាន ៣៥ ដួង ។

ទ្វិហេតុកៈ និងសុគតិអហេតុកបុគ្គល មានវិថីចិត្តកើតបាន ៤១ ដួង កើតមិនបាន ៤៨ ដួង ។

អបាយិកអហេតុកសត្វ មានចិត្តកើតបាន ៣៧ ដួង កើតមិនបាន ៥២ ដួង ។

តិហេតុកបុគ្គល មានចិត្តកើតបាន ៥៤ ដួង គឺ.-

១. អកុសលចិត្ត ១២ ដួង

២. អហេតុកចិត្ត ១៧ ដួង

៣. មហាកុសលចិត្ត ៨ ដួង

៤. មហាវិបាកចិត្ត ៨ ដួង

៥. មហគ្គតកុសលចិត្ត ៩ ដួង

ចិត្តកើតមិនបាន ៣៥ ដួង គឺ.-

១. ហសិតុប្បាទចិត្ត ១ ដួង

២. មហាកិរិយាចិត្ត ៨ ដួង

៣. មហគ្គតវិបាកចិត្ត ៩ ដួង

៤. មហគ្គតកិរិយាចិត្ត ៩ ដួង

៥. លោកុត្តរចិត្ត ៨ ដួង

**ទ្វិហេតុកៈ និង សុគតិអហេតុកបុគ្គល មានចិត្តកើតបាន ៤១ ដួង គឺ.-**

១. អកុសលចិត្ត ១២ ដួង

២. អហេតុកចិត្ត ១៧ ដួង

៣. មហាកុសលចិត្ត ៨ ដួង

៤. មហាវិបាកញ្ញាណវិប្បយុត្ត ៤ ដួង

**ចិត្តដែលសល់ ៤៨ ដួង កើតមិនបាន គឺ.-**

១. ហសិតុប្បាទចិត្ត ១ ដួង

២. មហាវិបាកញ្ញាណសម្បយុត្ត ៤ ដួង

៣. មហាកិរិយាចិត្ត ៨ ដួង

៤. មហគ្គតចិត្ត ២៧ ដួង

៥. លោកុត្តរចិត្ត ៨ ដួង

**អបាយិកអហេតុកបុគ្គល មានចិត្តកើតបាន ៣៧ ដួង គឺ.-**

១. អកុសលចិត្ត ១២ ដួង

២. អហេតុកចិត្ត ១៧

៣. មហាកុសលចិត្ត ៨ ដួង

**ចិត្តកើតមិនបាន ៥២ ដួង គឺ.-**

១. ហសិតុប្បាទចិត្ត ១ ដួង

២. មហាវិបាកចិត្ត ៨ ដួង

៣. មហាកិរិយាចិត្ត ៨ ដួង

៤. មហគ្គតចិត្ត ២៧ ដួង

៥. លោកុត្តរចិត្ត ៨ ដួង

សេចក្តីផ្សេងគ្នានៃចិត្ត ប្រព្រឹត្តទៅដោយអំណាចសេចក្តីផ្សេងគ្នានៃបុគ្គល ។ វិថីចិត្តទាំងអស់ រមែងកើតបាន ព្រោះសេចក្តីប្រព្រឹត្តទៅនៃទ្វារ ៦ និងបុគ្គលទាំងអស់ក្នុងកាមាវចរភូមិនោះ ដូច្នេះឯង ។

ចប់ការចែកវិថីចិត្តតាមប្រភេទបុគ្គល ។

## ភូមិវិភាគ

(ការចែកវិថីចិត្តក្នុងភូមិផ្សេងៗ)

បណ្តាភូមិទាំង ៣ កាមភូមិមាន ១១ រូបភូមិមាន ១៥ (វៀរអសញ្ញសត្តាភូមិ) និងអរូបភូមិមាន ៤ រួមជា ៣០ ភូមិ ។

វិថីចិត្តទាំងអស់នេះ រមែងកើតបានក្នុងកាមាវចរភូមិតាមគួរ កាលវៀរបដិឃជវនៈ និងតទាលម្ពណៈហើយ វិថីចិត្តដែលសល់ រមែងកើតក្នុង**រូបាវចរភូមិ** និង**វៀរបឋមមគ្គ រូបាវចរៈ ហសិតុប្បាទចិត្ត** និង**អរូបវិបាកហើយ** វិថីចិត្តដែលសល់ រមែងកើតបានក្នុង **អរូបាវចរភូមិ** ។ម្យ៉ាងទៀត វិថីចិត្តដែលប្រព្រឹត្តទៅក្នុងទ្វារនោះៗ រមែងមិនកើតដល់បុគ្គលអ្នកមិនមានបសាទនោះៗ សូម្បីក្នុងទីគ្រប់ស្ថាន ។ ចំណែកអសញ្ញសត្វ មិនមានចិត្តណាៗ ដោយប្រការទាំងពួង ។

## សង្គហគាថា

១០. *អសីតិ វីថិចិត្តានិ　　កាមេ រូបេ យថារហំ*

*ចតុសដ្ឋី តថារូបេ　　ទ្វេចត្តាឡីស លព្ភរេ ។*

ក្នុងកាមភូមិ មានវិថីចិត្តកើតបាន ៨០ ដួង ក្នុងរូបភូមិ មានវិថីចិត្តកើតបាន ៦៤ ដួង និងអរូបភូមិ មានវិថីចិត្តកើតបាន ៤២ ដួងតាមគួរ ។

## អធិប្បាយសង្គហគាថា

**កាមភូមិ ១១** មានវិថីចិត្តកើតបាន ៨០ ដួង (វៀរមហគ្គតវិបាក ៩) គឺ.-

១. អកុសលចិត្ត ១២ ដួង

២. អហេតុកចិត្ត ១៨ ដួង

៣. កាមាវចរសោភណចិត្ត ២៤ ដួង

៤. មហគ្គតកុសលចិត្ត ៩ ដួង

៥. មហគ្គតកិរិយាចិត្ត ៩ ដួង

៦. លោកុត្តរចិត្ត ៨ ដួង

រូបភូមិ ១៥ មានវិថីចិត្តកើតបាន ៦៤ ដួង គឺ.-

១. លោភមូលចិត្ត ៨ ដួង

២. មោហមូលចិត្ត ២ ដួង

៣. អហេតុកចិត្ត ១២ ដួង

៤. មហាកុសលចិត្ត ៨ ដួង

៥. មហាកិរិយាចិត្ត ៨ ដួង

៦. មហគ្គតកុសលចិត្ត ៩ ដួង

៧. មហគ្គតកិរិយាចិត្ត ៩ ដួង

៨. លោកុត្តរចិត្ត ៨ ដួង

វៀរវិថីចិត្តកើតមិនបាន ២៥ ដួង គឺ.-

១. ទោសមូលចិត្ត ២ ដួង

២. ឃាន- ជីវ្ហា-កាយវិញ្ញាណ ៦ ដួង

៣. មហាវិបាកចិត្ត ៨ ដួង

| | |
|---|---|
| ៤. មហគ្គតវិបាកចិត្ត | ៩ ដួង |

**អរូបភូមិ ៤ មានវិថីចិត្ត កើតបាន ៤២ ដួង គឺ.-**

| | |
|---|---|
| ១. លោភមូលចិត្ត | ៨ ដួង |
| ២. មោហមូលចិត្ត | ២ ដួង |
| ៣. មនោទ្វារាវជ្ជនចិត្ត | ១ ដួង |
| ៤. មហាកុសលចិត្ត | ៨ ដួង |
| ៥. មហាកិរិយាចិត្ត | ៨ ដួង |
| ៦. អរូបាវចរកុសលចិត្ត | ៤ ដួង |
| ៧. អរូបាវចរកិរិយាចិត្ត | ៤ ដួង |
| ៨. លោកុត្តរចិត្ត | ៧ ដួង |

**វៀរវិថីចិត្ត កើតមិនបាន ៤៧ ដួង គឺ.-**

| | |
|---|---|
| ១. ទោសមូលចិត្ត | ២ ដួង |
| ២. អហេតុកចិត្ត | ១៧ ដួង |
| ៣. មហាវិបាកចិត្ត | ៨ ដួង |
| ៤. រូបាវចរចិត្ត | ១៥ ដួង |
| ៥. អរូបាវចរវិបាកចិត្ត | ៤ ដួង |
| ៦. សោតាបត្តិមគ្គចិត្ត | ១ ដួង |

សេចក្តីប្រព្រឹត្តទៅនៃចិត្តក្នុងទ្វារ ៦ ដែលខណ្ឌទុកដោយភវង្គចិត្ត តាមដែលកើត រមែងប្រព្រឹត្តទៅមិនដាច់ខ្សែ ដរាបដល់អស់អាយុដូច្នេះឯង ។

## អវសានគាថា

*ឥច្ចានុរុទ្ធ រចិតេ អភិធម្មត្ថសង្គហេ*

*ចតុត្ថោ បរិច្ឆេទោយំ សមាសេនេវ និដ្ឋិតោ ។*

បរិច្ឆេទទី ៤ នេះ ឈ្មោះវិថីសង្គហវិភាគ ក្នុងបករណ៍ដែលរូបរួមនូវសេចក្តីនៃអភិធម្ម ដែលព្រះអនុរុទ្ធាចារ្យរចនាទុកដោយសង្ខេប ចប់ហើយ ដោយប្រការដូច្នេះ ។

# អ្នកមានឧបការៈក្នុងការរៀបចំសៀវភៅនេះ

ភិក្ខុ សុវណ្ណត្ថេរោ **ខឿ ឆំព័រ**

ព្រះធម្មាចារ្យ គម្ភីរបញ្ញោ **ទូច សុធី**

ព្រះឱវាទាចារ្យ សីលសំវរោ **ស៊ូ សាមុត**

ព្រះឧទ្ទេសាចារ្យ ធម្មជោតិកោ **អែ សារ៉ាត់**

សាមណេរ សុមនត្ថេរោ **ខ៊ែត តក្កី**

សាមណេរ ឥន្ទ្រិយសំវរោ **សេន ហុក**

សាមណេរ សន្តញ្ញាណោ **សុខ ខាសនា**

សាមណេរ ខន្តិធរោ **ជឹម បូរិន**

ឧបាសិកា **គាំង ឡេងហ៊ាង**

ឧបាសិកា **ជា កែវមុនី**

ឧបាសិកា **ឆេង អៀង**

ឧបាសិកា ឧបដ្ឋាយិកា **តាំង ឈន់**